# ម៉ូឌុល ២
## តម្រាសម្រាប់អ្នកសម្របសម្រួល

### វគ្គបេសកកម្មពហុគុណ
ការដាំក្រុមជំនុំដែលមានសុខភាពល្អ

revised 3/4/19

# បេសកកម្មពហុគុណ
## ទិដ្ឋភាពទូទៅនៃកម្មវិធីសិក្សាអំពីការដាំក្រុមជំនុំ

| | ម៉ូឌុល ១ ការដាំក្រុមជំនុំ ដែលមានសុខភាពល្អ | ម៉ូឌុល ២ ការត្រៀមរៀបចំដើម្បី ចែកចាយដំណឹងល្អ | ម៉ូឌុល ៣ ការយល់ដឹងផែនការ របស់ព្រះ | ម៉ូឌុល ៤ ការចែកចាយ ដំណឹងល្អ | ម៉ូឌុល ៥ នាំមនុស្សឆ្ពោះ ទៅរកជំនឿ | ម៉ូឌុល ៦ ការធ្វើឲ្យសិស្ស រីកចម្រើន |
|---|---|---|---|---|---|---|
| ការចាប់ផ្ដើមជាមួយព្រះ | គ្រឹះនៅក្នុងព្រះគម្ពីរសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ | គ្រឹះខាងទេវសាស្ត្រសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ | គ្រឹះខាងបេសកកម្មសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ | គ្រឹះយុទ្ធសាស្ត្រសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ | ការរស់នៅតាមដំណឹងល្អ | ការរីកចម្រើនរបស់គ្រិស្តបរិស័ទ: ព្រះគ្រិស្តជាចំណុចផ្ដោតអារម្មណ៍ (ឬព្រះគ្រិស្តជាចំណុចកណ្ដាល) |
| ម៉ោងទី ១ | **តើក្រុមជំនុំដែលមានសុខភាពល្អមានន័យយ៉ាងដូចម្ដេច?** | **ការធ្វើជំនេទីខាងវិញ្ញាណ: គោលការណ៍នៃការស្រាវជ្រាវ** | **អ្វីដែលព្រះកំពុងតែបង្ហាញខ្ញុំ: ការចែកចាយការស្រាវជ្រាវរបស់លោកអ្នក** | **ការប្រោសចុះបានសុចរិតដោយសារជំនឿ** | **ឧបសគ្គរារាំងដល់ការផ្សាយដំណឹងល្អ** | **មហាបេសកកម្ម និងការដាំក្រុមជំនុំ** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | បេសកកម្ម អត្ថបទ និងបរិបទ | និមិត្ត អត្ថបទ និងបរិបទ | ត្រូវបានបញ្ជាក់នៅក្នុងការត្រាស់ហៅរបស់ព្រះ | ការផ្សាយដំណឹងល្អ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស |
| ម៉ោងទី ២ | **តើអ្នកដាំក្រុមជំនុំដែលមានសុខភាពល្អមានន័យយ៉ាងដូចម្ដេច?** | **នេះជាអ្វីដែលព្រះយេស៊ូបានធ្វើសម្រាប់ខ្ញុំ! ការអភិវឌ្ឍន៍ និងការចែកចាយទីបន្ទាល់ផ្ទាល់ខ្លួន** | **អ្វីដែលព្រះកំពុងតែបង្ហាញខ្ញុំ: ការចែកចាយទីបន្ទាល់របស់លោកអ្នក និងការដើរអធិស្ឋាន** | **គោលការណ៍ដឹកនាំនៅក្នុងព្រះគម្ពីរ** | **ដំណើរការនៃការប្រែចិត្ត I** | **គន្លឹះទៅរកភាពជោគជ័យក្នុងការបង្កើតសិស្ស** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | បញ្ជាក់អះអាងនៅក្នុងការត្រាស់ហៅរបស់ព្រះ | ការផ្សាយដំណឹងល្អ | និមិត្ត អត្ថបទ និងបរិបទ | ពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការផ្សាយដំណឹងល្អ | ការបង្កើតសិស្ស |
| ម៉ោងទី ៣ | **ការគិត «អ» តើព្រះជាម្ចាស់ចង់បានអ្វី?** | **ការដឹកនាំក្រុមតូច** | **ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: ការសង្កេតស្គាល់និមិត្តរបស់ព្រះ** | **ការផ្សាយដំណឹងល្អ និងការដាំក្រុមជំនុំ** | **ដំណើរការនៃការប្រែចិត្ត II** | **ស្គាល់គោលដៅរបស់លោកអ្នក ស្គាល់មនុស្សរបស់លោកអ្នក** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ ការបង្កើតសិស្ស និងការពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ | ការផ្សាយដំណឹងល្អ | ការបង្កើតសិស្ស |
| ម៉ោងទី ៤ | **វដ្ដជីវិតនៃការដាំក្រុមជំនុំ** | **វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសានុមាន II: ការសង្កេតមើលព្រះបន្ទូល** | **ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: ការកំណត់បេសកកម្ម** | **ការចាប់ផ្ដើមក្រុមតូច** | **ការផ្សាយដំណឹងល្អក្រុមតូច** | **វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសានុមាន IV: ការអនុវត្តន៍ព្រះបន្ទូល** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស | ការផ្សាយដំណឹងល្អ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស |
| ម៉ោងទី ៥ | **ហេតុអ្វីក្រុមតូច?** | **របៀបបំផុសការអធិស្ឋានសម្រាប់ក្រុមជំនុំដែលលោកអ្នកបានដាំ** | **ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: ការកំណត់គុណតម្លៃ** | **ការផ្សាយដំណឹងល្អ និងការបំពេញសេចក្ដីត្រូវការរបស់សហគមន៍** | **ការអនុវត្តន៍៖ បទពិសោធន៍ក្រុមតូច** | **ការយល់ដឹងអំពីគតិលោក** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស | ការផ្សាយដំណឹងល្អ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការបម្រើ | ការផ្សាយដំណឹងល្អ | បញ្ជាក់អះអាងនៅក្នុងការត្រាស់ហៅរបស់ព្រះ |
| ម៉ោងទី ៦ | **វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសានុមាន: អនុញ្ញាតឲ្យព្រះគម្ពីរបង្រៀនយើង** | **វិធានស្ដីអំពីការអធិស្ឋានទំនុកដម្កើង ៩៥** | **ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: ការកំណត់យុទ្ធសាស្ត្រ** | **វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសានុមាន III: ការបកស្រាយព្រះបន្ទូល** | **ការធ្វើបទបង្ហាញផែនការមេ** | **វិធានស្ដីអំពីការអធិស្ឋានអរព្រះគុណដល់ព្រះសម្រាប់សេចក្ដីស្មោះត្រង់របស់ព្រះអង្គ** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស | ការថ្វាយបង្គំ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស | ការធ្វើសំយោគគំនិត | ការថ្វាយបង្គំ |

| | ម៉ូឌុល ៧ ការសង់ក្រុម | ម៉ូឌុល ៨ ការសង់ក្រុម | ម៉ូឌុល ៩ ការថែទាំមនុស្ស | ម៉ូឌុល ១០ ការបង្កើតឲ្យមានក្រុមជំនុំ | ម៉ូឌុល ១១ ការរៀបចំផែនការសម្រាប់ពេលអនាគត | ម៉ូឌុល ១២ ឆ្ពោះទៅមុខដោយការរួបរួម |
|---|---|---|---|---|---|---|
| ការចាប់ផ្តើមជាមួយព្រះ | ត្រូវបានបំផ្លាស់បំប្រែដោយសារដំណឹងល្អ | ព្រះគុណមានសម្រាប់អ្នកបន្ទាបខ្លួន | សេចក្តីស្រឡាញ់ គ្រឹះនៃព័ន្ធកិច្ច | ដើម្បីឲ្យលោកិយបានជឿ យ៉ូហាន ១៧ | ការរាប់តម្លៃ | រហូតដល់លោកិយទាំងមូលឮ! |
| **ម៉ោងទី ១** | **គ្រឹះនៅក្នុងព្រះគម្ពីរសម្រាប់ក្រុមជំនុំ** | **ក្រុមការងារៈ ការធ្វើការយ៉ាងមានប្រសិទ្ធភាពជាមួយអ្នកដទៃ** | **ការផ្សាយដំណឹងល្អតាមរយៈទំនាក់ទំនង** | **តួនាទីរួមរបស់ក្រុមជំនុំ** | **សេចក្តីផ្តើមអំពីភាពជាអ្នកមើលខុសត្រូវ** | **ការដោះស្រាយជម្លោះ** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការធ្វើសំយោគគំនិត | ការពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការថែទាំសមាជិកក្រុមតូច | ការធ្វើសំយោគគំនិត | ភាពជាអ្នកមើលខុសត្រូវលើធនធាន | ការប្រកបគ្នា |
| **ម៉ោងទី ២** | **ក្រុមជំនុំៈ សរីរាង្គដែលមានជីវិត** | **ការអភិវឌ្ឍន៍ក្រុម** | **ការប្រកបគ្នា** | **ព័ន្ធកិច្ចតាមរយៈអំណោយទានខាងវិញ្ញាណ** | **ភាពជាអ្នកមើលខុសត្រូវផ្នែកហិរញ្ញវត្ថុ** | **ការប្រែចិត្តជាមាគ៌ានៃជីវិត** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការធ្វើសំយោគគំនិត | ការពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការប្រកបគ្នា | ការបំផុសរូបកាយស្របទៅតាមអំណោយទានខាងវិញ្ញាណ | ភាពជាអ្នកមើលខុសត្រូវលើធនធាន | ការប្រកបគ្នា |
| **ម៉ោងទី ៣** | **តើក្រុមមនុស្សក្លាយជាក្រុមជំនុំនៅពេលណា?** | **ភាពរស់រវើកនៃការពិភាក្សានៅក្នុងក្រុមតូច** | **ការថែទាំសហគមន៍របស់យើង** | **របៀបប្រើការស្វែងរកអំណោយទានខាងវិញ្ញាណ** | | **ការប្រែចិត្ត និងការស្តារឡើងវិញៈ វិន័យក្រុមជំនុំ** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការធ្វើសំយោគគំនិត | ការបង្កើតសិស្ស | ការផ្សាយដំណឹងល្អ អត្ថបទ និងបរិបទ | ការបំផុសរូបកាយស្របទៅតាមអំណោយទានខាងវិញ្ញាណ | | ការប្រកបគ្នា |
| **ម៉ោងទី ៤** | **វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសនុមាន V: របៀបប្រើការសិក្សាព្រះគម្ពីរបែបវិសេសានុមាន** | **ការហ្វឹកហ្វឺនអ្នកដឹកនាំថ្មីរបស់ក្រុមតូច** | **លក្ខណៈរបស់ក្រុមជំនុំដែលរីកចម្រើន** | **ភាពរស់រវើកនៃសង្គ្រាមខាងវិញ្ញាណ** | | **ការបញ្ជូនអ្នកដទៃឲ្យទៅធ្វើព័ន្ធកិច្ច** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការបង្កើតសិស្ស | ការបង្កើតសិស្ស ការពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការធ្វើសំយោគគំនិត | ការប្រកបគ្នា | ការជួបជុំពិភាក្សាអំពី ការរៀបចំផែនការយុទ្ធសាស្ត្រ I | ការពង្រឹងសមត្ថភាពអ្នកដឹកនាំ |
| **ម៉ោងទី ៥** | **ប្រវត្តិអ្នកដឹកនាំគ្រិស្តបរិស័ទ** | **របៀបទំនាក់ទំនង** | **ការដឹកនាំបែបបម្រើ** | **របៀបដឹកនាំក្រុមជំនុំនៅក្នុងការថ្វាយបង្គំ** | | **ក្រុមជំនុំរបស់យើង និងរូបកាយព្រះគ្រិស្តដែលធំជាង** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ពង្រឹងសមត្ថភាពអ្នកដឹកនាំ | ពង្រឹងសមត្ថភាពអ្នកដឹកនាំ | ពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការថ្វាយបង្គំ | | ការប្រកបគ្នា |
| **ម៉ោងទី ៦** | **ការអធិប្បាយតាមព្រះគម្ពីរ I: ការយល់អំពីរាជសារ** | **ការអធិប្បាយតាមព្រះគម្ពីរ II: ការយល់អំពីអ្នកស្តាប់** | **វិធានស្តីអំពីការអធិស្ឋានៈ អេភេសូរ ៣–៥** | **ការអធិប្បាយតាមព្រះគម្ពីរ III: ការយល់អំពីខ្លួនឯង** | | **វិធានស្តីអំពីការអធិស្ឋានៈ អធិស្ឋានដើម្បីផ្សព្វផ្សាយដំណឹងល្អ** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការថ្វាយបង្គំ | ការថ្វាយបង្គំ | ការប្រកបគ្នា | ការថ្វាយបង្គំ | ភាពជាអ្នកមើលខុសត្រូវលើធនធាន, ការប្រព្រឹត្តចំពោះនិមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ |

បេសកកម្មពហុគុណ
ម៉ូឌុលការដាំក្រុមជំនុំដែលមានសុខភាពល្អ
ព័ន្ធកិច្ចបណ្ដាញពហុគុណ
ក្រុមជំនុំកាន់តែច្រើន / ក្រុមជំនុំកាន់តែរឹងមាំ
**រក្សាសិទ្ធិ © ២០១៥**

មេរៀនហ្វឹកហ្វឺនអ្នកដាំក្រុមជំនុំនេះ គឺជាការរួមបញ្ចូលគ្នានៃវគ្គសិក្សាអាល់ប្រ៊ិឌ អូមេហ្គា និងមេរៀនការដាំក្រុមជំនុំដែលមានសុខភាពល្អរបស់ព័ន្ធកិច្ចបណ្ដាញពហុគុណ (MNM)។

MNM បានទទួលការអនុញ្ញាតពីមជ្ឈមណ្ឌលហ្វឹកហ្វឺនអ្នកដាំក្រុមជំនុំ និងពីព័ន្ធកិច្ច Wolrd Ministires ដើម្បីបោះពុម្ពមេរៀននេះឲ្យក្រុមជំនុំប្រើ។

លោកអ្នក**ត្រូវបានអនុញ្ញាត និងលើកទឹកចិត្តឲ្យបោះពុម្ព និងចែកចាយមេរៀននេះ** តាមទម្រង់ណាមួយដែល: (១) ឲ្យតម្លៃប្រភពដើម (២) បញ្ជាក់ប្រាប់ ប្រសិនបើមានការកែសម្រួល (៣) មិនត្រូវយកថ្លៃហួសពីការចំណាយបោះពុម្ព និង (៤) មិនត្រូវថតចម្លង លើសពី ១,០០០ ច្បាប់។

វគ្គអូមេហ្គា:
ការហ្វឹកហ្វឺនអ្នកដាំក្រុមជំនុំ

រក្សាសិទ្ធិ © 2000, 2006 United World Mission.
មេរៀននេះរក្សាសិទ្ធិដើមដោយ The Alliance for Saturation Church Planting ហើយបានរៀបចំឡើងដោយភាពជាដៃគូសហការជាមួយ Peter Deyneka Russian Ministries, Project 250។

ប្រសិនបើលោកអ្នកចង់ដាក់មេរៀននេះនៅលើអ៊ិនធើណេត ឬប្រសិនបើលោកអ្នកមានបំណងចង់ប្រើខុសពីអ្វីដែលបានរៀបរាប់ខាងលើ សូមទំនាក់ទំនង United World Mission, ATTN: Jay Weaver/Omega, 9401-B Southern Pine Blvd., Charlotte, NC 28273-5596, ឬ omega_course@alliancescp.org។

ការបកប្រែ និងការផ្លាស់ប្ដូរស្របតាមបរិបទរបស់លោកអ្នក ក៏ត្រូវបានលើកទឹកចិត្តឲ្យធ្វើផងដែរ។

យើងខ្ញុំសូមអរគុណដល់លោកបណ្ឌិត Jerry Wofford និងលោកបណ្ឌិត Jeff Hale សម្រាប់ការរួមចំណែកដ៏មានតម្លៃរបស់ពួកលោក ក្នុងការរៀបចំមេរៀននេះ។
Gary Teja and John Wagenveld បណ្ណាធិការមេរៀនបេសកកម្មពហុគុណ
**www.multiplicationnetwork.org**

| | គំរូហ្វឹកហ្វឺនសម្រាប់ម៉ូឌុល ២ រយៈពេលមួយថ្ងៃ | |
|---|---|---|
| | សេចក្ដីផ្ដើមអំពីម៉ូឌុល ២ | ៨:០០ |
| | ចាប់ផ្ដើមជាមួយព្រះគ្រីះខាងទេវសាស្ត្រសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ | ៨:១៥ |
| | ការធ្វើបាយការណ៍ | ៨:៣០ |
| ម៉ោង ទីមួយ | ការធ្វើផែនទីខាងវិញ្ញាណ: គោលការណ៍អំពីការស្រាវជ្រាវ | ៩:០០ |

| | | |
|---|---|---|
| | សម្រាក | ១០:០០ |
| ម៉ោង ទីពីរ | នេះជាអ្វីដែលព្រះយេស៊ូបានធ្វើសម្រាប់ខ្ញុំ! ការអភិវឌ្ឍន៍ និងការចែកចាយទីបន្ទាល់ផ្ទាល់ខ្លួន | ១០:១៥ |
| ម៉ោង ទីបី | ការដឹកនាំក្រុមតូច<br>ល្បែងកម្សាន្តក្នុងការជួបប្រជុំក្រុមតូច | ១១:១៥ |
| | អាហារថ្ងៃត្រង់ | ១២:១៥ |
| ម៉ោង ទីបួន | វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសានុមាន ២: ការសង្កេតមើលព្រះបន្ទូលរបស់ព្រះ | ១:១៥ |
| ម៉ោង ទីប្រាំ | របៀបបំផុសការអធិស្ឋានសម្រាប់ក្រុមជំនុំដែលលោកអ្នកបានដាំ | ២:១៥ |
| | សម្រាក | ៣:១៥ |
| ម៉ោង ទីប្រាំមួយ | ការប្រគំតន្ត្រីអធិស្ឋាន: មក ចូរយើងឱនកាយក្រាបថ្វាយបង្គំ ដោយផ្តែកលើទំនុកតម្កើង ៩៥ | ៣:៣០ |
| | ការបញ្ចប់ | ៤:៣០ |
| | បិទបញ្ចប់ថ្ងៃនោះ | ៤:៤៥ |

# ការរៀបចំដើម្បីចែកចាយដំណឹងល្អ
# ម៉ូឌុល ២

កម្មវត្ថុមេរៀន: សិក្ខាកាមនឹងអាចប្រាប់បានតាមពាក្យរបស់ខ្លួន:
- ហេតុផលខាងទេវសាស្ត្រពិសេសសម្រាប់ការដាំក្រុមជំនុំ
- ការធ្វើផែនទីខាងវិញ្ញាណគឺជាអ្វី ហើយហេតុអ្វីបានជាសំខាន់
- កត្តាបួនរបស់ការជួបប្រជុំក្រុមតូច និងលំដាប់លំដោយធម្មតារបស់ក្រុមតូច
- អត្ថន័យនៃការចូលរួមនៅក្នុងបំណែកសង្កេតមើលរបស់ការសិក្សាព្រះគម្ពីរបែបវិសេសានុមាន
- វិធីអនុវត្តជាក់ស្តែងដែលអ្នកដាំក្រុមជំនុំអាចបំផុសការអធិស្ឋានសម្រាប់ការខិតខំប្រឹងប្រែងដាំក្រុមជំនុំរបស់ពួកគេ និង
- ដំណើរការជាមូលដ្ឋានគ្រឹះរបស់ការដាំក្រុមជំនុំដែលមានសុខភាពល្អ

សេចក្តីផ្តើមអំពីម៉ូឌុល ២

ការណែនាំសម្រាប់អ្នកសម្របសម្រួល (២ នាទី)
- ស្វាគមន៍សិក្ខាកាមដោយភាពកក់ក្តៅ រាក់ទាក់ និងភាពសាទរ។
- នាំមុខសិក្ខាកាមអធិស្ឋានខ្លីជាមួយគ្នា ថ្វាយថ្ងៃនោះជាសិរីល្អដល់ព្រះ។

សកម្មភាពខ្សឹបត (៥ នាទី)

- ចូរសុំសិក្ខាកាមឈរតម្រង់ជួរឲ្យវែង។
- ខ្សឹបប្រយោគនេះដាក់ត្រចៀកអ្នកទីមួយ: «តុបេងលាបពណ៌ស្វាយអត់ស្អាតទេ»។
- អ្នកទីមួយនោះត្រូវបានណែនាំឲ្យខ្សឹបប្រយោគដូចគ្នានោះដាក់ត្រចៀកអ្នកបន្ទាប់នៅក្នុងជួរ ហើយបន្តរហូតដល់សារនោះទៅដល់ត្រចៀកអ្នកចុងក្រោយគេ។
- ចូរឲ្យអ្នកក្រោយគេប្រាប់សារដែលគេបានទទួល បន្ទាប់មក លោកអ្នកប្រាប់សារដំបូង។ ជាធម្មតា មានការខុសប្លែកគ្នាខ្លាំងរវាងសារដំបូង និងសារចុងក្រោយដែលបានទទួល។ ចូរសើចសប្បាយជាមួយគ្នា។

ចូរនិយាយថា: «នៅក្នុងម៉ូឌុលនេះ យើងនឹងរៀនអំពីរបៀបចែកចាយដំណឹងល្អ ដើម្បីឲ្យគេទទួលយក ហើយយល់យ៉ាងច្បាស់»។

តម្លៃរបស់ផែនទី (៨ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: សកម្មភាពនេះមានគោលបំណងជួយសិក្ខាកាមចាប់ផ្តើមគិតអំពីព័ត៌មានដែលផែនទីអាចផ្តល់ឲ្យបាន។

- ចូរចែកសិស្សជាក្រុមដែលមានគ្នា ៤-៥ នាក់។ ឲ្យក្រុមនីមួយៗមានពេល ២ នាទី ដើម្បីកត់ត្រាចំណុចសំខាន់ៗដែលមាននៅលើផែនទីប្រទេសរបស់ពួកគេ។
- ចូរឲ្យក្រុមនីមួយៗប្រាប់ការ ៣-៤ យ៉ាងដែលមាននៅលើផែនទី។
- ចូរសុំអ្នកស្ម័គ្រចិត្ត ២ នាក់ ឲ្យចែកចាយឧទាហរណ៍អំពីស្ថានភាពមួយដែលផែនទីមានប្រយោជន៍ជួយបាន (ឧទាហរណ៍ ការធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយទៀត ស្គាល់កន្លែងដើម្បីរកបានធនធានផ្សេងៗដូចជាទឹក។ល។)។

ចូរនិយាយទៅគ្រប់គ្នាថា: «ថ្ងៃនេះ យើងក៏នឹងរៀនអំពីរបៀបដែលការធ្វើផែនទីតំបន់មួយអាចមានប្រយោជន៍ដល់យើងនៅក្នុងការដាំក្រុមជំនុំផងដែរ»។

# ការចាប់ផ្តើមជាមួយព្រះ
## គ្រឹះខាងទេវសាស្ត្រសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ (១៥ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរនិយាយថា៖ «ថ្ងៃនេះ យើងនឹងមើលបទគម្ពីរបួន ដើម្បីឃើញរបៀបដែលសកម្មភាពរបស់ព្រះមានឥទ្ធិពលលើការងាររបស់អ្នកដាំក្រុមជំនុំ និងរបៀបដែលលោកអ្នកអាចចូលរួមជាមួយព្រះអង្គនៅក្នុងសកម្មភាពនេះបាន»។
ចូរដឹកនាំក្រុមបំពេញប្រឡោះសម្រាប់សេចក្តីផ្តើម។

សេចក្តីផ្តើម

- ព្រះជាម្ចាស់កំពុងតែផ្សះផ្សាស្នាព្រះហស្តទាំងអស់នឹងព្រះអង្គទ្រង់នៅក្នុងព្រះគ្រិស្តយេស៊ូ។
- ព្រះវិញ្ញាណបរិសុទ្ធប្រទានអំណាចឲ្យក្រុមជំនុំដើម្បីធ្វើជាស្រមោលនៃព្រះរាជ្យរបស់ព្រះដែលនឹងមកដល់ ដែលនៅគ្រង់នេះរួចហើយ គ្រាន់តែមិនទាន់ពេញលេញមួយរយភាគរយ។
- ក្រុមជំនុំប្រៀបបីដូចជា«កន្លែងបង្ហាញចេញជាក់ស្តែង»ពីសេចក្តីស្រឡាញ់ដ៏ប្រោសលោះរបស់ព្រះ និងបង្ហាញឲ្យលោកិយឃើញពីរបៀបថ្មីនៃការធ្វើជាសហគមន៍ដែលមានជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់។
- ទស្សនៈដែលយើងប្រកាន់យកក្នុងនាមជាគ្រិស្តបរិស័ទគឺជាទស្សនៈរបស់ព្រះដែលពេញដោយសេចក្តីស្រឡាញ់ និងព្រះគុណជាព្រះដែលកំពុងធ្វើឲ្យអ្វីៗទាំងអស់ទៅជាថ្មីនៅក្នុងព្រះគ្រិស្ត និងអញ្ជើញប្រជារាស្ត្ររបស់ព្រះអង្គឲ្យចូលរួម ដោយចាក់គ្រឹះនៅក្នុងព្រះបន្ទូល និងដោយមានព្រះវិញ្ញាណដឹកនាំ ដើម្បីយកពិភពលោកនេះមកវិញថ្វាយព្រះយេស៊ូ ពេលដែលព្រះអង្គយាងត្រឡប់មកវិញ!

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរចែកសិក្ខាកាមទៅជាបួនក្រុម ហើយបែងចែកបទគម្ពីរឲ្យក្រុមនីមួយៗ។ ចូរឲ្យពួកគេឆ្លើយសំណួរនៅក្នុងក្រុមរបស់ពួកគេ បន្ទាប់មកប្រាប់ចម្លើយរបស់ខ្លួនដល់អ្នកដទៃទៀតនៅក្នុងក្រុម។
ចូរនិយាយថា៖ «ចូរអានបទគម្ពីររបស់លោកអ្នកឲ្យឮៗជាមួយក្រុមរបស់លោកអ្នក បន្ទាប់មកពិភាក្សាសំណួរទាំងបួនពាក់ព័ន្ធនឹងបទគម្ពីររបស់លោកអ្នក»។

បទគម្ពីរ:
១. កិច្ចការ ៣:១៧-២១
២. អេភេសូរ ១:៧-១០
៣. កូល៉ុស ១:១៦-២០
៤. រ៉ូម ៨:១៩-២៣

កំពុងផ្សះផ្សា - ព្រះអង្គទ្រង់ - ប្រទានអំណាច - ស្រមោល - ពេញលេញ - កន្លែងបង្ហាញចេញជាក់ស្តែង - លោកិយ - ជំនឿ - សេចក្តីស្រឡាញ់ - ទស្សនៈ - ពេញដោយសេចក្តីស្រឡាញ់ - ព្រះគុណ - អញ្ជើញ- ចាក់គ្រឹះ - ដឹកនាំ - យកមកវិញ

សំណួរ:
១. តើសកម្មភាពរបស់ព្រះដែលត្រូវបានពណ៌នានៅក្នុងបទគម្ពីរនេះ គឺជាអ្វី?
២. ហេតុអ្វីបានជាសកម្មភាពនេះចាំបាច់?
៣. តើសកម្មភាពនេះជះឥទ្ធិពលយ៉ាងដូចម្តេចលើការងាររបស់អ្នកដាំក្រុមជំនុំ?
៤. តើអ្នកដាំក្រុមជំនុំត្រូវមានធនធានអ្វីខ្លះ ដើម្បីចូលរួមជាមួយព្រះជាម្ចាស់នៅក្នុងផែនការប្រោសលោះរបស់ព្រះអង្គ?

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរនិយាយថា៖ «ជាអំណរខ្លាំងណាស់ដែលដឹងថា យើងកំពុងចូលរួមជាមួយព្រះនៅក្នុងកិច្ចការរបស់ព្រះអង្គដែលដាក់បញ្ចូលស្នាព្រះហស្តទាំងអស់! អ្នកដាំក្រុមជំនុំមានអភ័យឯកសិទ្ធិធ្វើតាមការដឹកនាំរបស់ព្រះវិញ្ញាណនៅក្នុងការនាំយកមនុស្សប្រុសស្រីក្មេងចាស់ទាំងអស់មករួមគ្នា ដើម្បីបង្កើតសហគមន៍ថ្មីដែលមានជំនឿ ជាអ្នកដែលបង្ហាញចេញជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់នៅក្នុងបរិបទរបស់ពួកគេ»។

ចូរសុំ ឲ្យសិក្ខាកាមពីរ ឬបីនាក់អធិស្ឋានបញ្ចប់ម៉ោងនេះ ដោយលើកឡើងពីអ្វីៗដែលបានពិភាក្សានៅ

ក្នុងការសិក្សានេះ ហើយថ្វាយម៉ោងសិក្សាដែលនៅសល់ក្នុងថ្ងៃនេះសម្រាប់ជាសិរីល្អដល់ព្រះអម្ចាស់។

ការរាយការណ៍ (៣០ នាទី)
ការណែនាំសម្រាប់អ្នកសម្របសម្រួល:

- ចូរនិយាយថា៖ «នៅក្នុងម៉ូឌុល ១ លោកអ្នកត្រូវបានប្រាប់ឲ្យធ្វើផែនការ «អ»។ សំណួរបីនៅក្នុងលំហាត់នេះបានផ្តល់ឲ្យលោកអ្នកនូវដំណើរការមួយសម្រាប់ធ្វើការស្រាវជ្រាវជាមូលដ្ឋានគ្រឹះមួយចំនួន។ មុនពេលដែលយើងចូលកាន់តែជ្រៅទៅក្នុងប្រធានបទស្រាវជ្រាវ សូមយកពេលខ្លះដើម្បីប្រាប់គំឃើញរបស់លោកអ្នកចេញពីលំហាត់នេះ» (១៥ នាទី)។
- ចូរបែងចែកជាក្រុមដែលមានគ្នា ៣ នាក់ ហើយឲ្យពេលម្នាក់ៗ ៥ នាទី ដើម្បីចែកចាយលទ្ធផលលំហាត់របស់ពួកគេ។
- ចូរដើរតាមក្រុមនីមួយៗ ដើម្បីសង្កេតមើលសកម្មភាពរបស់ពួកគេ។
- ប្រសិនបើមានអ្នកដែលមិនបានធ្វើលំហាត់នេះ ចូររកពេលនិយាយជាមួយគេផ្ទាល់ខ្លួននៅក្នុងពេលសម្រាក។ ចូរសុំឲ្យពួកគេធ្វើលំហាត់នេះ មុនការហ្វឹកហ្វឺនលើកក្រោយទៀត។
- ប្រសិនបើមានពេល ចូរសុំសិក្ខាកាម ១ ទៅ ៣ នាក់ ឲ្យចែកចាយគំឃើញរបស់ពួកគេប្រាប់ក្រុមធំ។
- ចូរពិនិត្យមើលផែនការសកម្មភាពការសិក្សាព្រះគម្ពីរបែបវិសេសានុមាន ប្រសិនបើមានពេល។

## ផែនការសកម្មភាពសម្រាប់ម៉ូឌុល ២
(មកពីម៉ូឌុល ១ ម៉ោងទី ៣)

១. ចូររៀបចំ ឬមានផែនទីក្រុង ឬភូមិរបស់លោកអ្នក ដែលលោកអ្នកមានគម្រោងនឹងដាំក្រុមជំនុំ។ ចូររកក្រុមជំនុំដំណឹងល្អឲ្យបានច្រើនតាមដែលលោកអ្នកអាចរកឃើញនៅក្នុងទីក្រុង ឬភូមិរបស់លោកអ្នក ហើយបង្ហាញប្រាប់ទំហំប្រហាក់ប្រហែលរបស់ក្រុមជំនុំទាំងនោះនៅលើផែនទី។ ចូរស្វែងរកព័ត៌មានអំពីចំនួនប្រជាជនសរុបនៅក្នុងទីក្រុង ឬភូមិនោះ។

អ្នកដឹកនាំគ្រិស្តបរិស័ទបាននិយាយថា ដើម្បីឲ្យប្រទេសមួយមានក្រុមជំនុំ«ពាសពេញ» ប្រទេសនោះត្រូវមានក្រុមជំនុំដំណឹងល្អមួយសម្រាប់រៀងរាល់មនុស្ស ១០០០ នាក់។ ប្រសិនបើយើងទទួលយកគំនិតដែលថា គួរតែមានក្រុមជំនុំមួយសម្រាប់រៀងរាល់មនុស្ស ១០០០ នាក់ តើលោកអ្នកគិតថា ត្រូវដាំក្រុមជំនុំប៉ុន្មានទៀតនៅក្នុងទីក្រុង ឬភូមិដែលលោកអ្នកចង់ដាំក្រុមជំនុំ?

២. ចូរចាប់ផ្តើមគិតអំពីផែនការសម្រាប់ការខិតខំប្រឹងប្រែងដាំក្រុមជំនុំដែលរួមបញ្ចូល: ការអធិស្ឋាន ការរួបរួមគ្នា និងសេចក្តីស្រឡាញ់ និមិត្ត ការផ្សាយដំណឹងល្អ និងការដាំក្រុមជំនុំ។ ចូរកត់ត្រាគំនិតដំបូងមួយចំនួន ហើយចែកចាយជាមួយគ្រូឧបជ្ឈាររបស់លោកអ្នក ឬជាមួយអ្នកបណ្តុះបណ្តាលនៅក្នុងម៉ោងសិក្សានេះ។

៣. ចូរគិតអំពីសហគមន៍ ភូមិ ទីក្រុង តំបន់ ឬប្រទេសរបស់លោកអ្នក។ ចូរពិចារណាចម្លើយរបស់លោកអ្នកសម្រាប់សំណួរទាំងនេះ:

- «តើព្រះជាម្ចាស់ចង់បានអ្វីសម្រាប់ _______________ (ឈ្មោះទីក្រុង ភូមិ ឬសហគមន៍ដែលលោកអ្នកមានគម្រោងដាំក្រុមជំនុំ)? ចូរសរសេរចម្លើយតែមួយកថាខណ្ឌ។
- ចូរកត់ត្រាការបីយ៉ាងដែលលោកអ្នកនឹងធ្វើ ដើម្បីមើលឃើញ «អ» កើតឡើងនៅក្នុងតំបន់របស់លោកអ្នក។

## ផែនការសកម្មភាពសម្រាប់ម៉ូឌុល ២
(មកពីម៉ូឌុល ១ ម៉ោងទី ៦)

នៅក្នុងការត្រៀមរៀបចំសម្រាប់មេរៀនការសិក្សាព្រះគម្ពីរបែបវិសេសានុមានក្រោយទៀតដែលនិយាយអំពីការសង្កេតមើល ចូរជ្រើសរើសបទគម្ពីរខ្លីមួយដើម្បីសិក្សា (កុំឲ្យច្រើនជាងមួយកថាខណ្ឌ)។ ចូរចំណាយពេលយ៉ាងហោចណាស់ ១ ម៉ោងសង្កេតមើលបទគម្ពីរនោះ ហើយសុំព្រះជាម្ចាស់ឲ្យបើកភ្នែកលោកអ្នកមើលឃើញសេចក្តីដែលលោកអ្នកមិនបានឃើញពីមុនមក។ ចូរកត់ត្រាការសង្កេតមើលរបស់លោកអ្នក តើលោកអ្នករៀនបានអ្វី? ចូរត្រៀមខ្លួនដើម្បីចែកចាយបទពិសោធន៍របស់លោកអ្នកជាមួយសហការីនៅក្នុងម៉ោងសិក្សាក្រោយទៀត។

ការណែនាំសម្រាប់អ្នកសម្របសម្រួល (១៥ នាទី)

- ចូរឲ្យសិក្ខាកាមបើកទៅទំព័រនៅក្នុងសៀវភៅលំហាត់របស់ពួកគេដែលមាន កខគ របស់អ្នកដាំក្រុមជំនុំ: របាយការណ៍ប្រចាំខែ។ ចូរពន្យល់ប្រាប់អំពីលក្ខខណ្ឌនៅក្នុងការធ្វើរបាយការណ៍សម្រាប់វគ្គសិក្សានេះ។
- ចូរពន្យល់អំពីរបៀបបំពេញទម្រង់នោះ។
- ចូរពន្យល់អំពីរបៀបដែលក្រុមនឹងរាយការណ៍ប្រាប់គ្នាទៅវិញទៅមកនៅក្នុងអំឡុងពេលម៉ោងសិក្សាអំពីការរាយការណ៍ដែលមាននៅក្នុងម៉ូឌុល ២ ដល់ទី ១២។

# របាយការណ៍ដាំក្រុមជំនុំកខគ

របាយការណ៍ប្រចាំខែ

## ព័ត៌មានទូទៅ

| | | | | |
|---|---|---|---|---|
| របាយការណ៍ខែ | | បានជួបប្រជុំជាមួយគ្រូឧបជ្ឈា | បាទ/ចាស | ទេ |

| | |
|---|---|
| ឈ្មោះអ្នកដាំក្រុមជំនុំ | |
| តំបន់របស់អ្នកដាំក្រុមជំនុំ | |
| អ្នកសម្របសម្រួលតំបន់ | |

| បុគ្គល | គោលដៅប្រចាំខែ | លទ្ធផលប្រចាំខែ |
|---|---|---|
| អ្នកថ្មីដែលត្រូវទាក់ទង<br>អ្នកដែលត្រូវបានទាក់ទងនៅក្នុងបរិបទដាំក្រុមជំនុំ ដើម្បីប្រាប់ដំណឹងល្អ | | |
| ការប្រែចិត្តថ្មី<br>អ្នកដើរតាមព្រះយេស៊ូ | | |
| អ្នកថ្មីដែលបានទទួលបុណ្យជ្រមុជទឹក<br>អ្នកដែលបានទទួលពិធីបុណ្យជ្រមុជទឹក | | |
| អ្នកដឹកនាំថ្មីដែលកំពុងទទួលការហ្វឹកហ្វឺន<br>អ្នកដែលអ្នកដាំក្រុមជំនុំកំពុងហ្វឹកហ្វឺនឲ្យធ្វើជាអ្នកដឹកនាំ | | |

| ក្រុមតូច: ជាអប្បបរិមា សិស្សថ្មីពីរនាក់ និងអ្នកដឹកនាំម្នាក់ | គោលដៅប្រចាំខែ | លទ្ធផលប្រចាំខែ |
|---|---|---|
| ក្រុមតូចថ្មី<br>ក្រុមដែលបានចាប់ផ្ដើមខែនេះ | | |
| អ្នកចូលរួមថ្មីនៅក្នុងក្រុមតូច<br>មនុស្សថ្មីដែលចូលរួមក្រុមតូចនៅខែនេះ | | |
| អ្នកដឹកនាំថ្មីដែលមានមួយក្រុម<br>អ្នកដឹកនាំថ្មីដែលមានមួយក្រុមនៅក្រោមការត្រួតពិនិត្យមើលរបស់អ្នកដាំពួកជំនុំ | | |

## សំណូមពរអធិស្ឋាន (តម្រូវឲ្យសរសេរយ៉ាងតិចពេញមួយប្រឡោះនេះ)

## ទីបន្ទាល់

ព័ន្ធកិច្ចបណ្ដាញពហុគុណ | កខគ របស់អ្នកដាំក្រុមជំនុំ

# ម៉ោងទី ១
# ការធ្វើផែនទីខាងវិញ្ញាណ:
# គោលការណ៍អំពីការស្រាវជ្រាវ (៦០ នាទី)

## ការឲ្យនិយមន័យការធ្វើផែនទីខាងវិញ្ញាណ (៣០ នាទី)

### ១. តើការធ្វើផែនទីខាងវិញ្ញាណជាអ្វី?

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរនិយាយថា៖ «នៅក្នុងដំណើរការដាំក្រុមជំនុំ យើងប្រមូលព័តមានដើម្បីប្រើសម្រាប់គោលបំណងរបស់ព្រះរាជ្យ។ ដូច្នេះហើយ ពេលខ្លះ អ្នកសិក្សាបេសកកម្មហៅការស្រាវជ្រាវប្រភេទនេះថា«ការធ្វើផែនទីខាងវិញ្ញាណ»។ នៅក្នុងការសិក្សានេះ យើងនឹងប្រើពាក្យ «ការស្រាវជ្រាវ» និង «ការធ្វើផែនទីខាងវិញ្ញាណ»។ ពាក្យទាំងពីរនេះយោងទៅរកដំណើរការប្រមូលព័ត៌មានអំពីផ្នែកចម្បងពីរដែលពាក់ព័ន្ធ»។

ចូរដឹកនាំសិក្ខាកាមបំពេញប្រឡោះខាងក្រោមនៅក្នុងសៀវភៅលំហាត់របស់ពួកគេ។

ការធ្វើផែនទីខាងវិញ្ញាណប្រមូលព័ត៌មានសម្រាប់គោលបំណងរបស់ព្រះរាជ្យពាក់ព័ន្ធនឹង:

១. វាលស្រែ: មនុស្ស និងកន្លែងដែលលោកអ្នកនឹងដាំក្រុមជំនុំ។
២. កម្លាំងច្រូត: មនុស្ស ក្រុមជំនុំ អង្គការ និងក្រុមដទៃទៀតដែលនឹងធ្វើតាមដំណើរការដាំក្រុមជំនុំ។

### ២. មូលដ្ឋានគ្រឹះនៅក្នុងព្រះគម្ពីរសម្រាប់ការធ្វើផែនទីខាងវិញ្ញាណ

ការណែនាំសម្រាប់អ្នកសម្របសម្រួល:
- ចូរចែកជាក្រុមតូច (៦ នាក់ ប្រសិនអាចធ្វើបាន)
- ចូរបែងចែកខគម្ពីរមួយក្នុងចំណោមខគម្ពីរខាងក្រោមឲ្យក្រុមនីមួយៗ។ ចូរឲ្យក្រុមអានបទគម្ពីរ ហើយកំណត់ប្រភេទព័ត៌មានដែលបានរាយការណ៍ និងមូលហេតុដែលព័ត៌មាននេះសំខាន់ចំពោះរបាយការណ៍។
- ចូរដឹកនាំថ្នាក់ទាំងមូលពិភាក្សាដោយសង្ខេបអំពីប្រភេទព័ត៌មានដែលបទគម្ពីរទាំងនេះប្រាប់ថាសំខាន់ដែលត្រូវតែមាន នៅពេលដែលដាំក្រុមជំនុំ។

១. ជនគណនា ១៣:១-៤
ប្រភេទព័ត៌មាន: អ្នកស៊ើបការណ៍ត្រូវបានចាត់ទៅឲ្យសង្កេតមើលស្រុកនោះ។

សារៈសំខាន់: ដឹងអំពីបរិបទមុនពេលចាប់ផ្តើម។
២. នេហេមា ១:៣-៤, ២:១-៦
ប្រភេទព័ត៌មាន: លោកនេហេមាបានស្រាវជ្រាវស្ថានភាពរបស់ក្រុងយេរូសាឡិម មុនពេលដែលចាប់ផ្តើម
ពត៌មាន – ព្រះរាជ្យ – វាល – កម្លាំង
ភារកិច្ចកសាងកំពែងក្រុងឡើងវិញ បន្ទាប់មក សីលធម៌របស់ប្រជាជនដែលនឹងធ្វើកិច្ចការនេះ។

សារៈសំខាន់: យល់អំពីសេចក្តីត្រូវការ និងធនធាន។

៣. ម៉ាថាយ ៩:៣៥-១០:១
ប្រភេទព័ត៌មាន: ព្រះយេស៊ូបានយាងទៅក្នុងចំណោមបណ្តាជន ហើយបានឃើញសេចក្តីត្រូវការរបស់ពួកគេ មុនពេលចាត់សិស្សរបស់ព្រះអង្គឲ្យចេញទៅធ្វើការនៅក្នុងចំណោមពួកគេ។

សារៈសំខាន់: ស្គាល់មនុស្ស និងស្ថានភាពរបស់ពួកគេ។

៤. យ៉ូហាន ៤:៣៥

ប្រភេទព័ត៌មាន: ព្រះអម្ចាស់យេស៊ូបានបង្គាប់សិស្សរបស់ព្រះអង្គឲ្យ«មើល» ឬ «សង្កេតមើល» (អត្ថន័យនៅក្នុងភាសាក្រិក) ចម្រូតដ៏ជាព្រៃលឹងមនុស្ស។

សារៈសំខាន់: ដឹងអំពីឱកាស។

៥. កិច្ចការ ១:៨
ប្រភេទព័ត៌មាន: ព្រះយេស៊ូបង្គាប់សិស្សរបស់ព្រះអង្គឲ្យផ្សព្វផ្សាយដំណឹងល្អ ដោយចាប់ផ្តើមពីទីតាំងយុទ្ធសាស្ត្រ (ក្រុងយេរូសាឡិម ជាចំណុចកណ្តាលរបស់ជនជាតិយូដា) និងនៅតាមតំបន់ដែលកាន់តែរីកធំឡើងៗ (ស្រុកយូដា ស្រុកសាម៉ារី និងចុងបំផុតនៃផែនដី)។

សារៈសំខាន់: ចាប់ផ្តើមព័ន្ធកិច្ចនៅកន្លែងដែលលោកអ្នក បន្ទាប់មកបន្តទៅក្នុងតំបន់ដទៃទៀត។

៦. កិច្ចការ ២:៤១, ៤៧, ៤:៤, ៥:១៤
ប្រភេទព័ត៌មាន: របាយការណ៍អំពីចំនួនមនុស្ស។

សារៈសំខាន់: ដឹង និងអបអរចំពោះអ្វីដែលព្រះជាម្ចាស់កំពុងធ្វើ។

៣. ហេតុអ្វីបានជាអ្នកដាំក្រុមជំនុំគួរតែធ្វើផែនទីខាងវិញ្ញាណ?
- ព័ត៌មានបំផុសចិត្តអាណិតអាសូរសម្រាប់មនុស្សនៅក្នុងតំបន់គោលដៅ។
- ព័ត៌មានបង្កើតឲ្យមានការអធិស្ឋាន។
- ព័ត៌មានបណ្តាលឲ្យមាននិមិត្តដាំក្រុមជំនុំ។
- ព័ត៌មានហ៊ឹកហ៊ឺនកម្លាំងចម្រូតឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។

៤. តើការធ្វើផែនទីខាងវិញ្ញាណគួរតែកើតឡើងនៅពេលណា?

ចិត្តអាណិតអាសូរ – ការអធិស្ឋាន – និមិត្ត – ហ៊ឹកហ៊ឺន
កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល: ផ្នែកនេះយោងទៅវដ្តនៃការដាំក្រុមជំនុំនៅក្នុងម៉ូឌុល ១។ នេះជាពេលដ៏ល្អដើម្បីពិនិត្យមើលវដ្តនៃការដាំក្រុមជំនុំឡើងវិញ ប្រសិនបើមានពេល។

វាជាការសំខាន់ណាស់ដែលការធ្វើផែនទីខាងវិញ្ញាណកើតឡើងនៅក្នុងដំណាក់កាលទី ១-ដំណាក់កាលអធិស្ឋាន។ លើសពីនេះទៅទៀត ការធ្វើផែនទីខាងវិញ្ញាណអាចមានប្រយោជន៍នៅក្នុងដំណាក់កាលទី ៤-ដំណាក់កាលជួបជុំគ្នា។ នៅក្នុងករណីនេះ ការធ្វើផែនទីខាងវិញ្ញាណត្រូវបានប្រើដើម្បីវាយតម្លៃប្រសិទ្ធភាពក្រុមជំនុំថ្មីរបស់លោកអ្នក។ ការធ្វើផែនទីខាងវិញ្ញាណក៏មានប្រយោជន៍ផងដែរនៅក្នុងដំណាក់កាលទី ៦-ដំណាក់កាលពហុគុណ ដែលជួយឲ្យក្រុមជំនុំអាចមើលឃើញតួនាទីរបស់ខ្លួននៅក្នុង«រូបភាពធំ»-កិច្ចការដ៏ធំជាងរបស់រូបកាយព្រះគ្រីស្ត។

៥. តើការធ្វើផែនទីខាងវិញ្ញាណគួរតែកើតឡើងនៅកន្លែងណា?

ការរៀបចំសម្រាប់អ្នកសម្របសម្រួល: ចូរផ្តល់ឧទាហរណ៍ឲ្យសិក្ខាកាម។ ចូរស្វែងរក ឬគូរផែនទីតំបន់គោលដៅ និងបន្ថែមព័ត៌មានអំពីតំបន់គោលដៅនោះ (រង្វង់មូល) នៅក្នុងឧទាហរណ៍របស់លោកអ្នក។ ចូរកែសម្រួលផែនទីដើម្បីបង្ហាញព័ត៌មានសំខាន់ៗដូចជាកន្លែងដែលមានក្រុមជំនុំស្ថិតនៅ ប្រភេទក្រុមជំនុំ ព្រមទាំងកន្លែងដទៃទៀតដែលសំខាន់ចំពោះភារកិច្ច (ឧទាហរណ៍ មជ្ឈមណ្ឌលសាសនា មជ្ឈមណ្ឌលនយោបាយ ផ្សារ កន្លែងប្រវត្តិសាស្ត្រ។ល។)។

ការធ្វើផែនទីខាងវិញ្ញាណមានទីតាំងជាក់លាក់ (សហគមន៍ ភូមិ ក្រុង) ឬតំបន់ទូទៅ (ប្រទេស ខេត្ត រដ្ឋ) ដែលលោកអ្នកចង់ដាំក្រុមជំនុំ។ ផែនទីនេះមានទីតាំងគោលដៅ ឬតំបន់គោលដៅរបស់លោកអ្នក។

៦. តើផែនទីខាងវិញ្ញាណគួរតែធ្វើឡើងយ៉ាងដូចម្តេច?

ចូរនិយាយថា៖ «មានវិធីសាស្ត្រផ្សេងៗដើម្បីរកឃើញព័ត៌មានសំខាន់ៗអំពីទីតាំងគោលដៅ ឬតំបន់គោលដៅរបស់លោកអ្នក»។ ចូរកត់ត្រាវិធីមួយចំនួននៅក្នុងសៀវភៅលំហាត់របស់លោកអ្នក»។

១. ការសង្កេតមើលនៅនឹងកន្លែង
២. ការសម្ភាស
៣. កម្រងសំណួរ និងការស្ទង់មតិ
៤. ព័ត៌មានរបស់រដ្ឋាភិបាលអំពីទីតាំងគោលដៅ ឬតំបន់គោលដៅរបស់លោកអ្នក
៥. ឯកសារជាលាយលក្ខណ៍អក្សរដទៃទៀត (សៀវភៅ ទិន្នានុប្បវត្តិ ។ល។) ឯកសារជាវីដេអូ និងសំឡេងអំពីទីតាំងគោលដៅ ឬតំបន់គោលដៅរបស់លោកអ្នក។

៧. ចាប់ផ្តើមជាមួយនឹងការធ្វើផែនទីខាងវិញ្ញាណ

ការណែនាំ: ទូទៅ – ការសង្កេតមើល – ការសម្ភាស – ការស្ទង់មតិ – រដ្ឋាភិបាល – វីដេអូ – សំឡេង

- ចូរឲ្យសិក្ខាកាមចាប់ដៃគូពីរនាក់ ឬបីនាក់ឆ្លើយសំណួរខាងក្រោម។
- ប្រសិនបើមានពេល ចូរឲ្យសិក្ខាកាមមួយចំនួនចែកចាយចម្លើយរបស់ពួកគេនៅក្នុងក្រុមធំ។

១. តើការចំណាយពេលរៀនអំពីតំបន់គោលដៅរបស់លោកអ្នកមានផលប្រយោជន៍អ្វីខ្លះ?

________________________________________
________________________________________
________________________________________

២. តើការស្រាវជ្រាវធ្វើឲ្យការខំប្រឹងប្រែងដាំក្រុមជំនុំរបស់លោកអ្នកកាន់តែមានប្រសិទ្ធភាពឡើងយ៉ាងដូចម្តេច?

________________________________________
________________________________________
________________________________________

៣. តើព័ត៌មានប្រាំ ឬប្រាំមួយប្រភេទដែលលោកអ្នកគិតថា លោកអ្នកត្រូវដឹងអំពីតំបន់គោលដៅរបស់លោកអ្នកដែលនឹងបង្កើនប្រសិទ្ធភាពរបស់លោកអ្នកនៅក្នុងការដាំក្រុមជំនុំ មានប្រភេទអ្វីខ្លះ?

________________________________________
________________________________________
________________________________________

៤. តើលោកអ្នកគិតថា ការស្រាវជ្រាវរបស់លោកអ្នកនឹងរកឃើញអ្វីអំពីតំបន់គោលដៅរបស់លោកអ្នក? តើអ្នកនៅក្នុងវាលស្រែរបស់លោកអ្នកត្រៀមខ្លួនរួចហើយឬនៅដើម្បីស្តាប់ព្រះដំណឹងល្អ? តើលោកអ្នកបានសង្កេតមើលឃើញអ្វីខ្លះ ដែលបង្ហាញប្រាប់លោកអ្នកថា មនុស្សបើកចំហទទួលយកដំណឹងល្អ ឬប្រឆាំងដំណឹងល្អ?

________________________________________
________________________________________
________________________________________

៥. តើនរណាគួរតែប្រមូលព័ត៌មាន? តើលោកអ្នកស្គាល់មនុស្សដែលពូកែស្រាវជ្រាវ ក្រោយពីលោកអ្នកហ្វឹកហ្វឺនពួកគេដែរឬទេ?

________________________________________
________________________________________
________________________________________

៦. តើនរណាគួរតែសង្ខេប និងធ្វើបទបង្ហាញព័ត៌មាន? អ្នកដែលសង្ខេប និងធ្វើបទបង្ហាញព័ត៌មានត្រូវតែមានសមត្ថភាពធ្វើកិច្ចការនេះតាមរបៀបផ្សេងៗដែលជំរុញឲ្យមានចិត្តអាណិតអាសូរចំពោះមនុស្សនៅក្នុងទីតាំង/តំបន់គោលដៅរបស់លោកអ្នក ហើយសង់ទំនុកចិត្តចំពោះអ្វីដែលព្រះជាម្ចាស់ចង់ធ្វើនៅក្នុងចំណោមពួកគេ។

## ផែនការសកម្មភាពសម្រាប់ម៉ូឌុល ៣: ការយល់អំពីទីតាំង/តំបន់គោលដៅរបស់លោកអ្នក តាមរយៈការធ្វើផែនទីខាងវិញ្ញាណ (១៥ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូររំឭកឡើងវិញការណែនាំខាងក្រោមសម្រាប់អ្នកដាំក្រុមជំនុំ និងដំណើរការស្រាវជ្រាវប្រាំមួយជំហានជាមួយសិក្ខាកាម ហើយឆ្លើយសំណួរពាក់ព័ន្ធនឹងលំហាត់នេះ។

មុនពេលត្រលប់មកសិក្សាម៉ូឌុល ៣ ចូរធ្វើតាមដំណើរការស្រាវជ្រាវដែលមានប្រាំមួយជំហាននៅខាងក្រោម ដើម្បីស្រាវជ្រាវទីតាំង/តំបន់គោលដៅរបស់លោកអ្នក។ លោកអ្នកប្រហែលជាចង់ផ្លាស់ប្តូរគំរូកម្រងសំណួរដែលបានផ្តល់ឲ្យនៅត្រង់នេះ ដើម្បីប្រើជាផ្នែកមួយនៃការស្រាវជ្រាវរបស់លោកអ្នក។

លំហាត់នេះមានគោលបំណងផ្តល់ឲ្យលោកអ្នកមានបទពិសោធន៍នៅក្នុងការស្រាវជ្រាវជាក់ស្តែងជាឧបករណ៍មួយសម្រាប់ការដាំក្រុមជំនុំដែលមានប្រសិទ្ធភាព។ លោកអ្នកគួរតែព្យាយាមធ្វើគ្រប់ផ្នែកទាំងអស់របស់លំហាត់នេះ។ លោកអ្នកប្រហែលជាឃើញថា សកម្មភាពខ្លះនៅក្នុងលំហាត់នេះងាយស្រួលជាងសកម្មភាពខ្លះទៀត។ ទោះជាងាយស្រួល ឬពិបាកក៏ដោយ ព្រះជាម្ចាស់មានសេចក្តីដែលត្រូវបង្រៀនអំពីមនុស្ស និងតំបន់ដែលលោកអ្នកកំពុងព្យាយាមឈោងចាប់តាមរយៈសកម្មភាពនីមួយៗរបស់លំហាត់នេះ។

លោកអ្នកមិនត្រូវធ្វើលំហាត់នេះតែម្នាក់ឯងទេ។ លោកអ្នកអាចធ្វើជាមួយអ្នកដទៃទៀតបាន។ តាមពិតទៅ លោកអ្នកគួរតែឲ្យអ្នកដទៃទៀតចូលរួម ប្រសិនបើអាចធ្វើបាន។ ចូរត្រៀមខ្លួនដើម្បីចែកចាយគំឃើញនៅក្នុងការស្រាវជ្រាវរបស់លោកអ្នកប្រាប់គ្រូបង្វឹក គ្រូឧបជ្ឈា និងអ្នកដទៃទៀត។

ចូរសុំព្រះជាម្ចាស់ឲ្យប្រើលំហាត់នេះដើម្បីឲ្យដឹងកាន់តែច្បាស់ និងមានចិត្តអាណិតអាសូរកាន់តែខ្លាំងចំពោះមនុស្សនៅក្នុងតំបន់គោលដៅរបស់លោកអ្នក។ ចូរសុំព្រះអង្គឲ្យប្រើការស្រាវជ្រាវនេះដើម្បីផ្តល់ឲ្យលោកអ្នកមានគំនិតល្អៗអំពីកន្លែង និងរបៀបចាប់ផ្តើមព័ន្ធកិច្ចដាំក្រុមជំនុំរបស់លោកអ្នកនៅក្នុងតំបន់គោលដៅ។

### ដំណើរការស្រាវជ្រាវដែលមាន ៦ ជំហាន (១៥ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរដឹកនាំសិក្ខាកាមនៅក្នុងការបំពេញជំហានទាំងប្រាំមួយរបស់ដំណើរការស្រាវជ្រាវ បន្ទាប់មក រៀបរាប់ដោយសង្ខេបពីរបៀបដែលពួកគេនឹងរាយការណ៍នៅក្នុងម៉ូឌុលលើកក្រោយ។ ចូរបង្ហាញប្រាប់គំរូកម្រងសំណួរដែលមាននៅខាងចុងម៉ូឌុលនេះ។

ជំហានទី ១: ចូរកំណត់តំបន់គោលដៅរបស់លោកអ្នក
ចូររកឲ្យបាន ឬធ្វើផែនទីភូមិ ទីក្រុង ឬតំបន់របស់លោកអ្នក។ ចូរយកផែនទីដ៏លម្អិតបំផុតដែលលោកអ្នកអាចរកបាន ដែលមានគ្រប់ទីប្រជុំជន ឈ្មោះផ្លូវ និងផ្លូវគមនាគមន៍។ ចូរគូររង្វង់ជុំវិញតំបន់គោលដៅរបស់លោកអ្នក។ នេះគឺជាតំបន់ព័ន្ធកិច្ចរបស់លោកអ្នក ជាតំបន់ដែលលោកអ្នកជឿថាព្រះជាម្ចាស់ចង់ឲ្យលោកអ្នកប្រកាសព្រះនាមរបស់ព្រះអង្គឲ្យគេបានស្គាល់ និងជាកន្លែងដែលព្រះអង្គចង់ដាំក្រុមជំនុំ។

តំបន់គោលដៅ
ជំហានទី ២: ប្រមូលព័ត៌មានអំពីកម្លាំងច្រូត
ដូចដែលបានរៀបរាប់ខាងលើរួចមកហើយ កម្លាំងច្រូតគឺជាធនធានទាំងអស់របស់ព្រះដែលកំពុងធ្វើការរួចទៅហើយនៅក្នុងតំបន់គោលដៅរបស់លោកអ្នក។ ចូរកំណត់ថាមានធនធានអ្វីខ្លះនៅក្នុងរង្វង់របស់លោកអ្នក ដោយសិក្សាចំណុចខាងក្រោម:

១. ក្រុមជំនុំមូលដ្ឋានដែលមានរួចហើយ
   ក. ដៅចំណាំគ្រប់ក្រុមជំនុំមូលដ្ឋាននៅក្នុងតំបន់របស់លោកអ្នកនៅលើផែនទី។ បង្ហាញប្រាប់ថា ពួកគេនិកាយអ្វី។

ខ. ប្រសិនបើអាចធ្វើបាន កត់ត្រាចំនួនមនុស្សពេញវ័យដែលចូលរួមថ្វាយបង្គំជាមួយពួកគេ។
គ. បង្ហាញប្រាប់ឆ្នាំដែលក្រុមជំនុំនោះត្រូវបានដាំ ឬបើកទ្វារឡើងវិញ។
ឃ. កំណត់ក្រុមមនុស្សដែលក្រុមជំនុំនីមួយៗកំពុងឈោងចាប់។ តើពួកគេជោគជ័យប៉ុនណានៅក្នុងការខំប្រឹងប្រែងរបស់ពួកគេ?
ង. តើមានទំនាក់ទំនងអ្វីខ្លះរវាងក្រុមជំនុំនៅក្នុងរង្វង់នេះ? តើពួកគេរួបរួមគ្នា ឬបែកបាក់គ្នា?
ច. តើមនុស្សកំពុងជួបជុំគ្នាដើម្បីអធិស្ឋានសម្រាប់អ្នកបាត់បង់នៅក្នុងសហគមន៍របស់ពួកគេ ឬសម្រាប់បេសកកម្មឈោងចាប់ដែរឬទេ?

២. ក្រុមបេសកកម្ម និងព័ន្ធកិច្ចក្រៅក្រុមជំនុំ
ក. កត់ត្រាក្រុមបេសកកម្ម និងព័ន្ធកិច្ចក្រៅក្រុមជំនុំទាំងអស់នៅក្នុងតំបន់គោលដៅ។
ខ. ពណ៌នាដោយសង្ខេបពីព័ន្ធកិច្ចដែលក្រុមនីមួយៗមាន (បោះពុម្ពសៀវភៅ គុក យុវជន។ល។)។
គ. តើពួកគេចាប់អារម្មណ៍ចង់សហការជាមួយលោកអ្នក ឬអ្នកដទៃទៀតនៅក្នុងការផ្សាយដំណឹងល្អ និងការខំប្រឹងប្រែងដាំក្រុមជំនុំដែរឬទេ?

៣. ប្រវត្តិជំនឿគ្រិស្តបរិស័ទ
ក. តើជំនឿគ្រិស្តបរិស័ទមកដល់តំបន់នេះលើកដំបូងនៅពេលណា ហើយត្រូវបាននាំមកយ៉ាងដូចម្ដេច? តើមនុស្សត្រូវបានបង្ខំឲ្យទទួលយកដំណឹងល្អ ឬពួកគេទទួលយកដំណឹងល្អដោយស្ម័គ្រចិត្ត?
ខ. ចូរពណ៌នាប្រវត្តិដែលនិកាយនីមួយៗចូលមកក្នុងតំបន់នេះ។
គ. តើសាសនាធំៗដទៃទៀតដែលមានឥទ្ធិពលនៅក្នុងតំបន់គោលដៅរបស់លោកអ្នក មានសាសនាអ្វីខ្លះ? តើមានសាសនាដទៃទៀតអ្វីខ្លះនៅក្នុងតំបន់របស់លោកអ្នកនៅសព្វថ្ងៃនេះ ហើយសាសនាទាំងនោះជោគជ័យប៉ុនណានៅក្នុងការទទួលបានបរិស័ទរបស់ខ្លួន?
ឃ. តើប្រវត្តិនេះមានឥទ្ធិពលយ៉ាងដូចម្ដេចលើផែនការដាំក្រុមជំនុំរបស់លោកអ្នក?

ជំហានទី ប្រមូលព័ត៌មានអំពីវាលស្រែ
វាលស្រែគឺជាក្រុមមនុស្ស ឬចំនួនប្រជាជនទូទៅដែលលោកអ្នកនឹងធ្វើការនៅក្នុងចំណោមពួកគេ និងជាកន្លែងដែលលោកអ្នកនឹងដាំក្រុមជំនុំ។ សកម្មភាពខាងក្រោមនឹងជួយលោកអ្នកដឹងអំពីវាលស្រែនៅក្នុងតំបន់គោលដៅរបស់លោកអ្នក។

១. ព័ត៌មានប្រជាសាស្ត្រ
ក. ចំនួនប្រជាជនសរុប
ខ. ចំនួន និងភាគរយនៃប្រជាជនសរុបដែលជាបុរស ស្ត្រី យុវជន កុមារ
គ. ចំនួនមនុស្សដែលមានការងារធ្វើ...រួមទាំងព័ត៌មានអំពីមុខរបរ និងកម្រិតប្រាក់ចំណូល
ឃ. ចំនួនមនុស្សចូលនិវត្តន៍ និងចាស់ជរា ព្រមទាំងមនុស្សពិការ
ង. ភាគរយ និងទីតាំងជនជាតិភាគតិច។ តើពួកគេនិយាយភាសាអ្វី?

២. ព័ត៌មានភូមិសាស្ត្រ
ការដៅភូមិសាស្ត្រអាចមានឥទ្ធិពលយ៉ាងខ្លាំងមកលើផែនការដាំក្រុមជំនុំ។ ពួកគេដើរតួនាទីប្រាប់ពីរបៀប និងកន្លែងដែលមនុស្សរស់នៅ និងមានទំនាក់ទំនងជាមួយអ្នកដទៃទៀត។ ឧទាហរណ៍ ផ្លូវរថភ្លើងរត់កាត់ទីប្រជុំជនក្នុងទីក្រុងមួយ នៅម្ខាងផ្លូវ ប្រជាជនមានខ្លាំងជាងម្ខាងទៀត។ មនុស្សមិនឆ្លងផ្លូវរថភ្លើងទេ។ ដូច្នេះហើយ ផ្លូវរថភ្លើងក្លាយជារនាំងសង្គម ហើយមនុស្សដែលនៅម្ខាងនៃផ្លូវរថភ្លើងនឹងមិនចូលទៅក្នុងក្រុមជំនុំដែលនៅម្ខាងទៀតនៃផ្លូវទេ។ ឧទាហរណ៍មួយផ្សេងទៀតគឺថា ដោយព្រោះទីក្រុងមួយមានភ្នំស្អាតៗហ៊ុំព័ទ្ធជុំវិញ ជាធម្មតា មនុស្សចេញទៅក្រៅក្រុងនៅថ្ងៃអាទិត្យ ដូច្នេះពួកគេមិនទំនងជាចូលរួមថ្វាយបង្គំក្នុងក្រុមជំនុំនៅព្រឹកថ្ងៃអាទិត្យទេ។
ក. តើកត្តាអ្វីខ្លះបំបែកតំបន់នោះ (ទន្លេ ផ្លូវរថភ្លើង ផ្លូវគោក។ល។)? តើការបែងចែកទាំងនេះមានឥទ្ធិពលលើរបៀបធ្វើដំណើរ ទំនាក់ទំនង។ល។ យ៉ាងដូចម្ដេច?
ខ. តើទីក្រុងនេះមានភ្នំហ៊ុំព័ទ្ធជុំវិញដែរឬទេ? តើមានបឹង ឆ្នេរ សួនឧស្សាន ឬកន្លែងដទៃទៀតសម្រាប់លំហែកាយនៅខាងក្រៅដែរឬទេ?
គ. ប្រសិនបើតំបន់គោលដៅរបស់លោកអ្នកគឺជាទីក្រុង ចូររកទីតាំងតំបន់ឧស្សាហកម្ម និងតំបន់លំនៅដ្ឋាននៅលើផែនទីរបស់លោកអ្នក។ តើមានតំបន់លក់ដូរពិសេសដែរឬទេ? តើមនុស្សរស់នៅជិតកន្លែងធ្វើការ ឬត្រូវធ្វើដំណើរវែងឆ្ងាយ? តើមនុស្សជួបជុំគ្នានៅកន្លែងណា? ចូរស្វែងយល់

ផងដែរពីមធ្យោបាយចម្បងនៅក្នុងការធ្វើដំណើរ។ តើមនុស្សភាគច្រើនធ្វើដំណើរដោយជិះឡាន ជិះរថយន្តក្រុង ឬដើរ?

ឃ. តើមនុស្សទៅកម្សាន្ត និងលំហែកាយនៅកន្លែងណា? តើពួកគេស្នាក់នៅក្នុងទីក្រុង ហើយទៅសួនឧស្សាហដែរឬទេ?

៣. ព័ត៌មានអំពីសង្គម និងវប្បធម៌

ដោយសារដឹងអំពីទស្សនៈរបស់មនុស្ស និងសេចក្តីត្រូវការរបស់ពួកគេ យើងអាចរកឃើញវិធីបង្ហាញសេចក្តីស្រឡាញ់របស់ព្រះយេស៊ូគ្រិស្តយ៉ាងមានអត្ថន័យដល់ពួកគេបាន។ វិធីដ៏ល្អបំផុតដើម្បីដឹងអំពីមនុស្ស គឺសួរសំណួរពួកគេ ហើយសង្កេតមើលអាកប្បកិរិយារបស់ពួកគេ។ ចូរចេញទៅក្នុងតំបន់គោលដៅរបស់លោកអ្នក ហើយនិយាយជាមួយមនុស្សឲ្យបានយ៉ាងហោចណាស់ ១៥-២០ នាក់។ ចូរព្យាយាមរៀនចំណុចខាងក្រោម:

វាល ប្រជាសាស្ត្រ - ភូមិសាស្ត្រ - សង្គម - វប្បធម៌

ក. ទស្សនៈអំពីព្រះ។ តើមនុស្សជឿលើព្រះដែរឬទេ? តើពួកគេជឿយ៉ាងដូចម្តេចអំពីព្រះ? តើពួកគេធ្លាប់បានឮអំពីព្រះយេស៊ូដែរឬទេ? តើពួកគេដឹងអ្វីខ្លះអំពីព្រះអង្គ? តើពួកគេជឿលើស្ថានសួគ៌ ឬស្ថាននរកដែរឬទេ? តើពួកគេជឿលើទេវតា ឬអារក្ស ឬសាតាំងដែរឬទេ? នៅពេលដែលពួកគេឈឺ តើពួកគេងាកទៅរកជំនួយនៅកន្លែងណា? តើពួកគេជឿលើសំណាងដែរឬទេ? តើពួកគេជឿថាពួកគេអាចគ្រប់គ្រងអនាគតខ្លួនឯង ឬធ្វើឲ្យជីវិតខ្លួនឯងកាន់តែប្រសើរសម្រាប់កូនរបស់ពួកគេដែរឬទេ? តើពួកគេជឿថា អំពើបាបគឺជាអ្វី? តើពួកគេទៅព្រះវិហារទៀងទាត់ដែរឬទេ? ប្រសិនបើទៅ តើញឹកញាប់ដែរឬទេ? ប្រសិនបើមិនទៅ ហេតុអ្វីបានជាពួកគេមិនទៅព្រះវិហារ?

ខ. តើថ្ងៃបុណ្យ ឬថ្ងៃឈប់សម្រាកធំៗនៅក្នុងតំបន់នេះ មានអ្វីខ្លះ? តើមនុស្សអបអរថ្ងៃបុណ្យទាំងនោះយ៉ាងដូចម្តេច?

គ. តើពួកគេចូលចិត្តអ្វីបំផុតអំពីជីវិតរបស់ពួកគេ? តើការមួយដែលពួកគេនឹងផ្លាស់ប្តូរគឺជាអ្វី?

ឃ. តើពួកគេចាត់ទុកអ្វីជាបញ្ហាចម្បងមួយ ឬពីរនៅក្នុងសហគមន៍របស់ពួកគេ? (ឧទាហរណ៍ ការប្រមឹក កុមារកំព្រា កង្វះខាតការថែទាំផ្នែកសុខាភិបាលឲ្យបានគ្រប់គ្រាន់ ចាស់ជរាដែលមិនបានទទួលការថែទាំ។ល។)

ង. តើរឿងបីដែលពួកគេចូលចិត្តមានរឿងអ្វីខ្លះ? តាមរយៈរឿង ជាញឹកញាប់ យើងអាចរកឃើញគំនិត និងគុណតម្លៃដែលពួកគេប្រកាន់យក ព្រមទាំងទស្សនៈរបស់ពួកគេអំពីជីវិតផងដែរ។

ច. តើនរណាជាអ្នកដឹកនាំដែលមានការទទួលស្គាល់នៅក្នុងសហគមន៍? ហេតុអ្វីបានជាពួកគេត្រូវបានចាត់ទុកជាអ្នកដឹកនាំ?

ឆ. តើនរណាត្រូវបានចាត់ទុកថាជាវីរបុរស?

ជ. ចូរកត់ត្រាការប្រាំយ៉ាងដែលមនុស្សឲ្យតម្លៃនៅក្នុងអ្នកដទៃទៀត (ឧទាហរណ៍ ភាពស្មោះត្រង់ ភាពវៃឆ្លាត ចិត្តសប្បុរស។ល។)?

ជំហានទី ៤: ការវិភាគព័ត៌មានអំពីវាលស្រែ និងកម្លាំងច្រូត

ប្រសិនបើយើងទទួលយកគំនិតថា គួរតែមានក្រុមជំនុំមួយសម្រាប់រៀងរាល់មនុស្ស ១០០០ នាក់ តើត្រូវការក្រុមជំនុំចំនួនប៉ុន្មាន ដើម្បីឲ្យគ្រប់ទាំងមនុស្សប្រុស មនុស្សស្រី និងកូនក្មេងនៅក្នុងគោលដៅនេះអាចមើលឃើញ ស្តាប់ឮ និងយល់រាជសារដំណឹងល្អតាមរបៀបដែលពាក់ព័ន្ធខាងវប្បធម៌?

នៅពេលដែលលោកអ្នកប្រមូលបានព័ត៌មាន និងឯកសារជាលាយលក្ខណ៍អក្សរទាំងអស់របស់លោកអ្នក ព្រមទាំងបានធ្វើការកត់សម្គាល់នៅលើផែនទីរបស់លោកអ្នករួចហើយ ចូរចំណាយពេលពិនិត្យមើលឡើងវិញ គិត និងអធិស្ឋានអំពីព័ត៌មាននោះ។ ចូរសុំព្រះជាម្ចាស់ប្រទានឲ្យលោកអ្នកមានគំនិតច្នៃប្រឌិតអំពីរបៀបចែកចាយសេចក្តីស្រឡាញ់របស់ព្រះអង្គជាមួយមនុស្សទាំងនេះ។ ជាផ្នែកមួយនៃដំណើរការនេះ ចូរវិភាគព័ត៌មានរបស់លោកអ្នក ដោយឆ្លើយសំណួរខាងក្រោម:

ក. តើត្រូវការក្រុមជំនុំចំនួនប៉ុន្មាន ដើម្បីសម្រេចមហាបេសកកម្មនៅក្នុងតំបន់គោលដៅរបស់លោកអ្នក? តើត្រូវការក្រុមជំនុំចំនួនប៉ុន្មាន ដើម្បីឲ្យគ្រប់ទាំងមនុស្សប្រុស មនុស្សស្រី និងកូនក្មេងនៅក្នុងតំបន់គោលដៅរបស់លោកអ្នកអាចមើលឃើញ ស្តាប់ឮ និងយល់ព្រះរាជ្យសារដំណឹងល្អតាមរបៀបដែលពាក់ព័ន្ធខាងវប្បធម៌? ចូរចាប់ផ្តើមអធិស្ឋានសុំព្រះជាម្ចាស់ឲ្យដឹកនាំលោកអ្នកនៅក្នុងការធ្វើអ្វីដែលព្រះអង្គចង់ឲ្យបានសម្រេច។

ការវិភាគ

ខ. ចូរកំណត់ចំណែករបស់លោកអ្នក: នៅក្នុងចំណោមក្រុមជំនុំទាំងនេះ តើព្រះអង្គចង់ឲ្យលោកអ្នកជឿព្រះអង្គថានឹងប្រទានឲ្យលោកអ្នកមានក្រុមជំនុំប៉ុន្មាននៅក្នុងព័ន្ធកិច្ចរបស់លោកអ្នក?

គ. ចូរជ្រើសទីតាំងចាប់ផ្តើមរបស់លោកអ្នក: តើលោកអ្នកនឹងចាប់ផ្តើមនៅកន្លែងណា? តើមនុស្សដែលទំនងជាឆ្លើយតបចំពោះដំណឹងល្អស្ថិតនៅកន្លែងណា? ជាធម្មតា លោកប៉ុលបានរកឃើញមនុស្សបើកចំហបំផុតមុនដំបូងគេនៅក្នុងសាលាប្រជុំ បន្ទាប់មកលោកបានធ្វើកិច្ចការចេញពី

កន្លែងនោះតាមរយៈបណ្ដាញទំនាក់ទំនង។

ឃ. ចូរជ្រើសរើសវិធីសាស្ត្ររបស់លោកអ្នក: តើសេចក្ដីត្រូវការធំបំផុតមួយ ឬពីររបស់មនុស្សនៅក្នុងសហគមន៍មានអ្វីខ្លះ? តើលោកអ្នកនឹងប្រើវិធីសាស្ត្រអ្វីខ្លះដើម្បីបំពេញសេចក្ដីត្រូវការរបស់មនុស្ស? តើក្រុមជំនុំដទៃទៀតមានវិធីសាស្ត្រអ្វីខ្លះ ដែលកំពុងតែមានលទ្ធផលល្អនៅក្នុងតំបន់នោះ? តើលោកអ្នកមានធនធានអ្វីខ្លះសម្រាប់វិធីសាស្ត្រទាំងនេះ? តើលោកអ្នកមានអំណោយទាន និងអាចធ្វើអ្វីបានខ្លះ?

ង. ចូរកំណត់ធនធានរបស់លោកអ្នក: តើនរណាមាននិមិត្តតែមួយដូចដែលលោកអ្នកមាន? តើមានមនុស្សដទៃទៀតដែលលោកអ្នកអាចចែកចាយនិមិត្តនេះជាមួយគេ ហើយសហការគ្នានៅក្នុងការសម្រេចគោលដៅដែរឬទេ? តើលោកអ្នកមានកម្លាំងពលកម្ម ហិរញ្ញវត្ថុ និងអ្នកមានអំណោយទានអ្វីខ្លះ? តើក្រុមជំនុំនៅក្នុងតំបន់នោះមានបំណងប្រាថ្នាចំពោះការផ្សាយដំណឹងល្អ និងការដាំក្រុមជំនុំដែរឬទេ? តើពួកគេបើកចំហចំពោះការធ្វើការជាមួយគ្នា ឬជាមួយលោកអ្នកនៅក្នុងការខំប្រឹងប្រែងរបស់លោកអ្នកដែរឬទេ? តើពួកគេបើកចំហចិត្តនឹងអធិស្ឋានសម្រាប់ការផ្សាយដំណឹងល្អ ការដាំក្រុមជំនុំ និងការប្រកាសឲ្យបានស្គាល់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់មនុស្សនៅក្នុងសហគមន៍របស់ពួកគេដែរឬទេ?

ឆ. តើមនុស្សមានការយល់ដឹង ឬជំនឿលើព្រះជាម្ចាស់ ឬព្រះយេស៊ូគ្រិស្តដែរឬទេ? នៅពេលដែលលោកអ្នកចែកចាយព្រះរាជសារដំណឹងល្អ តើលោកអ្នកត្រូវចាប់ផ្ដើមនៅត្រង់ណាក្នុងព្រះរាជសារ? (ឧទាហរណ៍ តើលោកអ្នកអាចចាប់ផ្ដើមជាមួយព្រះយេស៊ូគ្រិស្តបានដែរឬទេ ឬតើលោកអ្នកត្រូវចាប់ផ្ដើមជាមួយការគង់នៅរបស់ព្រះអាទិករដ៏ធំឧត្តម?)។

ជំហានទី ៥: មេរៀនដែលបានរៀនចេញពីដំណើការ (ធ្វើផែនទីខាងវិញ្ញាណ) ស្រាវជ្រាវ: ចូរឆ្លុះបញ្ចាំងអំពីបទពិសោធន៍របស់លោកអ្នកនៅក្នុងការធ្វើលំហាត់ (ធ្វើផែនទីខាងវិញ្ញាណ) ស្រាវជ្រាវនេះ។ តើព្រះជាម្ចាស់បានបង្រៀនអ្វីដល់លោកអ្នកតាមរយៈលំហាត់ស្រាវជ្រាវនេះអំពីខ្លួនលោកអ្នក និងបំណងប្រាថ្នារបស់លោកអ្នកដែលចង់ចូលរួមនៅក្នុងការដាំក្រុមជំនុំ? តើលោកអ្នកមានការលំបាកអ្វីខ្លះនៅក្នុងការធ្វើការស្រាវជ្រាវនេះ? តើលោកអ្នកបានយកឈ្នះការលំបាកទាំងនោះយ៉ាងដូចម្ដេច? តើមានអ្វីដែលងាយស្រួលអំពីការស្រាវជ្រាវនេះ? ប្រសិនបើលោកអ្នកត្រូវធ្វើលំហាត់នេះឡើងវិញ តើលោកអ្នកនឹងធ្វើអ្វីខុសពីមុន?

មេរៀន
ជំហានទី ៦: ការចែកចាយលទ្ធផលចេញពីការធ្វើផែនទីខាងវិញ្ញាណ

នៅក្នុងការហ្វឹកហ្វឺនលើកក្រោយទៀត ចូរត្រៀមខ្លួនផ្ដល់របាយការណ៍អំពីលទ្ធផលនៃការស្រាវជ្រាវរបស់លោកអ្នក។ របាយការណ៍របស់លោកអ្នកគួរតែមានរយៈពេលប្រហែល ១០-១៥ នាទី និងមានព័ត៌មានខាងក្រោមនេះ។

១. ផ្នែកទីមួយ—ព័ត៌មានមូលដ្ឋានគ្រឹះដែលប្រមូលបាន (៥-៧ នាទី)
ពណ៌នាតំបន់គោលដៅរបស់លោកអ្នក
តើលោកអ្នកប្រមូលបានព័ត៌មានយ៉ាងដូចម្ដេច (ការស្ទង់មតិ ការសម្ភាសក្រៅផ្លូវការ ការសង្កេតមើល/ការធ្វើផែនទីការស្រាវជ្រាវនៅក្នុងបណ្ណាល័យ។ល។)?
ចូរពិភាក្សាអំពីបញ្ហា ឬការលំបាកសំខាន់ៗដែលបានជួបប្រទះ និងរបៀបដែលបានយកឈ្នះការលំបាកទាំងនោះ។ លើកក្រោយទៀត តើលោកអ្នកនឹងធ្វើអ្វីខុសពីមុន?

២. ផ្នែកទីពីរ—ការវិភាគព័ត៌មានដែលបានមកពីការស្រាវជ្រាវ (ការធ្វើផែនទីខាងវិញ្ញាណ) (៥-៨ នាទី)
ផ្នែកដែលនៅសល់នៅក្នុងបទបង្ហាញគួរតែផ្ដោតលើលទ្ធផលនៃការស្រាវជ្រាវរបស់លោកអ្នក។ បទបង្ហាញគួរតែឆ្លើយសំណួរគន្លឹះខាងក្រោម:

- តើអ្វីជាព័ត៌មានដ៏គួរឲ្យចាប់អារម្មណ៍បំផុតដែលលោកអ្នកបានដឹងអំពីតំបន់គោលដៅរបស់លោកអ្នក និងប្រជាជនដែលកំពុងរស់នៅទីនោះ?
- តើមានព័ត៌មានដែលបានធ្វើឲ្យលោកភ្ញាក់ផ្អើលដែរឬទេ?
- តើលោកអ្នករៀនបានការជាក់លាក់អ្វីខ្លះ ដែលជួយលោកអ្នកនៅក្នុងការកំណត់ផែនការរបស់លោកអ្នកសម្រាប់ការដាំក្រុមជំនុំនៅក្នុងតំបន់គោលដៅរបស់លោកអ្នក?
- តើលោកអ្នកបានបញ្ជាក់ការពិតដ៏សំខាន់មួយសម្រាប់ការដាំក្រុមជំនុំដែលលោកអ្នកបានដឹងរួចហើយអំពីវាលស្រែនោះ តើគឺជាការពិតអ្វី?
- តើលោកអ្នកបានរកឃើញអ្វីថ្មីអំពីវាលស្រែដែលលោកអ្នកមិនបានដឹងពីមុនមក ហើយមានសារៈសំខាន់សម្រាប់ការដាំក្រុមជំនុំ?

- តើលោកអ្នកបានរកឃើញឱកាសអ្វីខ្លះជាទ្វារដែលបើកចំហសម្រាប់ដំណឹងល្អ? តើលោកអ្នកបានជួបប្រទះឧបសគ្គអ្វីខ្លះ ហើយឧបសគ្គទាំងនោះអាចយកឈ្នះបានយ៉ាងដូចម្ដេច?
- តើលោកអ្នកត្រូវធ្វើការស្រាវជ្រាវអ្វីថែមទៀត ដើម្បីអភិវឌ្ឍផែនការផ្សាយដំណឹងល្អ និងដាំក្រុមជំនុំដែលមានលក្ខណៈទូលំទូលាយសម្រាប់តំបន់គោលដៅរបស់លោកអ្នក?

គំរូកម្រងសំណួរ:
គំរូកម្រងសំណួរពីរត្រូវបានផ្ដល់ឲ្យនៅខាងក្រោម:
(១) ការស្ទង់មតិសម្រាប់គ្រប់ក្រុមជំនុំនៅក្នុងតំបន់គោលដៅ និង (២) កម្រងសំណួរសម្រាប់ស្រាវជ្រាវតំបន់គោលដៅ។ ទាំងនេះគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ ហើយអាចផ្លាស់ប្ដូរបានសម្រាប់គោលបំណងផ្ទាល់ខ្លួនលោកអ្នក។

ការចែកចាយ

## ការស្ទង់មតិក្រុមជំនុំមូលដ្ឋាន

ជីវប្រវត្តិ
ឈ្មោះក្រុមជំនុំ

________________________________________

និកាយ

________________________________________

អាសយដ្ឋានក្រុមជំនុំ / ទីតាំង

________________________________________

កន្លែងក្រុមជំនុំជួបជុំគ្នា: កម្មសិទ្ធិព្រះវិហារ ____________ ជួល ____________
កាលបរិច្ឆេទចាប់ផ្ដើម ____________ កាលបរិច្ឆេទចុះឈ្មោះ ____________
ឈ្មោះគ្រូគង្វាលក្នុងក្រុមជំនុំ /អ្នកដឹកនាំ
________________________________ អាយុ
____________
តើគ្រូគង្វាល / អ្នកដឹកនាំធ្វើការងារផ្សេងទៀតដែរឬទេ? បាទ ឬចាស ____________ ទេ ____________
ភាសាចម្បងនិយាយនៅក្នុងក្រុមជំនុំ

________________________________

ភាសាដទៃទៀត?________________________________
ចំនួនសមាជិកនៅពេលបច្ចុប្បន្ន

________________________________

ចំនួនអ្នកចូលរួមថ្វាយបង្គំជាមធ្យមភាគ

________________________________

មនុស្ស
ចូរព្យាយាមបំពេញចំនួនមនុស្សដែលត្រូវតាមប្រភេទខាងក្រោម:

| | អ្នកចូលរួមថ្វាយបង្គំ | | អ្នកជឿ | | សមាជិក | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី |
| អាយុ ០-១០ | | | | | | |
| ១១-១៧ | | | | | | |
| ១៨-២៤ | | | | | | |
| ២៥-៣០ | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៣១-៥៥ | | | | | | |
| ៥៥+ | | | | | | |

*ការប៉ាន់ស្មានអំពីក្រុមជំនុំ:*
អ្នកចូលរួមថ្វាយបង្គំទាំងអស់មិនមែនជាអ្នកជឿ / ឬសមាជិកទេ។
ចំនួនអ្នកចូលរួមថ្វាយបង្គំគួរតែខ្ពស់ជាងអ្នកជឿ និងសមាជិក។
មនុស្សអាចចូលរួមថ្វាយបង្គំ ហើយជាអ្នកជឿ ប៉ុន្តែមិនចាំបាច់តែជាសមាជិកទេ។
ចំនួនអ្នកជឿគួរតែតិចជាងចំនួនអ្នកចូលរួមថ្វាយបង្គំ ប៉ុន្តែខ្ពស់ជាងចំនួនសមាជិក។

ចំនួនអ្នកទទួលពិធីជ្រមុជទឹក: ២០១៤ ________ ១៥ ________ ១៦ ________ ១៧ ________ ១៨ ________ ១៩ ________ ២០២០ ________

ចំនួនគ្រួសារ (ប្តី / ប្រពន្ធ) ដែលចូលរួមនៅក្នុងក្រុមជំនុំ: ___________

កម្មវិធី
គូសសកម្មភាពទាំងអស់ដែលក្រុមជំនុំបានផ្តល់ឲ្យ និងកត់ត្រាចំនួនអ្នកចូលរួមនៅក្នុងសកម្មភាពទាំងនោះ។

| សកម្មភាព | គូសប្រអប់នេះ ប្រសិនបើក្រុមជំនុំផ្តល់ឲ្យ: | ចំនួនអ្នកចូលរួម |
|---|---|---|
| សាលាថ្ងៃអាទិត្យ (ក្រុមតាមអាយុ) | | |
| ការថ្វាយបង្គំ | | |
| ក្រុមយុវជន | | |
| ក្រុមកុមារ | | |
| ក្រុមស្ត្រី | | |
| ក្រុមបុរស | | |
| ក្រុមបេសកកម្ម | | |
| ការផ្សាយដំណឹងល្អ | | |
| ការហ្វឹកហ្វឺនសិស្ស | | |
| ក្រុមសិក្សាព្រះគម្ពីរតាមផ្ទះ | | |
| ការហ្វឹកហ្វឺនអ្នកជឿថ្មី | | |
| ការហ្វឹកហ្វឺនអ្នកដឹកនាំ | | |
| ការហ្វឹកហ្វឺនគ្រូបង្រៀម | | |
| ការប្រជុំអធិស្ឋាន | | |
| ក្រុមចម្រៀង | | |

| | | |
|---|---|---|
| ព័ន្ធកិច្ចយោធា | | |
| ព័ន្ធកិច្ចក្រុមជំនុំថ្មី | | |
| ព័ន្ធកិច្ចបោះពុម្ពសៀវភៅ | | |
| ព័ន្ធកិច្ចទូរទស្សន៍/វិទ្យុ | | |
| ព័ន្ធកិច្ចនៅក្នុងគុក | | |
| ព័ន្ធកិច្ចជាមួយអ្នកញៀនថ្នាំ /ស្រា | | |
| ព័ន្ធកិច្ចនៅមន្ទីរពេទ្យ | | |
| ព័ន្ធកិច្ចកុមារកំព្រា | | |
| ព័ន្ធកិច្ចមើលថែចាស់ជរា | | |
| ព័ន្ធកិច្ចអធិស្ឋាន | | |

ផែនការ

១. តើមានផែនការព័ន្ធកិច្ចជាក់លាក់សម្រាប់ឆ្នាំនេះដែរឬទេ?
បាទ ឬចាស ________ ទេ ________
តើផែនការទាំងនេះមានអ្វីខ្លះ?
______________________________________________
______________________________________________

២. តើបានចាប់ផ្ដើមផែនការសម្រាប់ឆ្នាំក្រោយហើយឬនៅ?
បាទ ឬចាស ________ ទេ ________
តើផែនការទាំងនេះមានអ្វីខ្លះ?
______________________________________________
______________________________________________

៣. តើមានក្រុមអ្នកដឹកនាំដែលរៀបចំផែនការសម្រាប់ក្រុមជំនុំដែរឬទេ?
បាទ ឬចាស ________ ទេ ________

៤. តើក្រុមជំនុំមានសេចក្ដីថ្លែងការណ៍គោលបំណងដែរឬទេ?
បាទ ឬចាស ________ ទេ ________

៥. តើក្រុមជំនុំមានផែនការហិរញ្ញវត្ថុដែរឬទេ?
បាទ ឬចាស ________ ទេ ________

៦. តើក្រុមជំនុំមានផែនការសម្រាប់ឲ្យអ្នកជឿមានការរីកចម្រើនឡើងខាងវិញ្ញាណដែរឬទេ?
បាទ ឬចាស ________ ទេ ________

៧. តើក្រុមជំនុំសហការជាមួយក្រុមជំនុំដទៃទៀតដែរឬទេ?
បាទ ឬចាស ________ ទេ ________

៨. តើក្រុមជំនុំសហការជាមួយនិកាយដទៃទៀតដែរឬទេ?
បាទ ឬចាស ________ ទេ ________

## តំបន់គោលដៅ ឬការស្ទង់មតិអំពី “រង្វង់”

**ក. នរណា?**

១. តើមានក្រុមមនុស្សពិសេសណាមួយនៅក្នុង«រង្វង់ឥទ្ធិពល»របស់ក្រុមជំនុំនេះដែរឬទេ?

________________________________________

________________________________________

២. តើមានវណ្ណៈណាមួយនៅក្នុងសង្គមដែលលេចធ្លោនៅក្នុង«រង្វង់»នេះដែរឬទេ?
បាទ ឬចាស ________ ទេ ________

ប្រសិនបើ«មាន» តើមួយណា?

________________________________________

________________________________________

**ខ. អ្វី?**

១. តើតំបន់គោលដៅនៅជុំវិញក្រុមជំនុំមានលក្ខណៈលេចធ្លោអ្វីខ្លះ?

________________________________________

________________________________________

២. តើមនុស្សនៅក្នុង«រង្វង់»នេះ មានព្រឹត្តិការណ៍ ថ្ងៃឈប់សម្រាក ឬពិធីបុណ្យអ្វីខ្លះ?

________________________________________

________________________________________

៣. តើសេចក្តីត្រូវការបន្ទាន់បំផុតរបស់មនុស្សនៅក្នុង«រង្វង់»នេះ មានអ្វីខ្លះ?
សេដ្ឋកិច្ច ________ ខាងវិញ្ញាណ ________ ខាងសីលធម៌ ________ ខាងសង្គម ________
ខាងការអប់រំ ________ ខាងវប្បធម៌ ________ គ្រួសារ ________ ខាងសាសនា ________

៤. តើមានក្រុមសាសនាប្រភេទអ្វីខ្លះ
ហើយក្រុមនីមួយៗមានក្រុមជំនុំចំនួនប៉ុន្មាននៅក្នុង«រង្វង់»នេះ?
អ័រតូដុក ________ បាប់ទីស្ទ ________ ប៉ង់តាកូស ________ រ៉ូម៉ាំង កាតូលិក ________
លូធើរិន ________ ប្រូតេស្តង់ដទៃទៀត ________ ឯករាជ្យ ________ អ៊ីស្លាម ________
ក្រុមបេសកកម្មបរទេស ________
(សូមសរសេរថា ក្រុមទាំងនេះមានក្រុមអ្វីខ្លះ)

________________________________________

៥. តើក្រុមជំនុំកំពុងព្យាយាមដោះស្រាយសេចក្តីត្រូវការរបស់មនុស្សដែរឬទេ?
បាទ ឬចាស ________ ទេ ________
ប្រសិនបើមាន តើក្រុមជំនុំកំពុងធ្វើអ្វីជាក់លាក់ ដើម្បីបម្រើសេចក្តីត្រូវការនៅក្នុង«រង្វង់»របស់ពួកគេ?

________________________________________

________________________________________

៦. តើសេចក្តីថ្លែងការណ៍គោលបំណងរបស់ក្រុមជំនុំបង្ហាញប្រាប់បំណងប្រាថ្នាចង់ដោះស្រាយសេចក្តីត្រូវការនៅក្នុង «រង្វង់»របស់ពួកគេដែរឬទេ?
បាទ ឬចាស ________ ទេ ________

៧. តើផែនការព័ន្ធកិច្ចរបស់ក្រុមជំនុំបង្ហាញប្រាប់ការយកចិត្តទុកដាក់ចំពោះការបម្រើ

សេចក្តីត្រូវការរបស់មនុស្សនៅក្នុង«រង្វង់»របស់ពួកគេដែរឬទេ?
បាទ ឬចាស ________ ទេ ________

គ. យ៉ាងដូចម្តេច?

១. តើក្រុមជំនុំមានអារម្មណ៍ជាកម្មសិទ្ធិជាមួយមនុស្សនៅក្នុង«រង្វង់»របស់ពួកគេដែរឬទេ?
បាទ ឬចាស ________ ទេ ________
ប្រសិនបើ «បាទ ឬចាស» តើយ៉ាងដូចម្តេច?

________________________________________________________________________________

________________________________________________________________________________

ប្រសិនបើ «ទេ» តើក្រុមជំនុំអាចចាប់ផ្តើមធ្វើអ្វីបាន ដើម្បីមានអារម្មណ៍ជាកម្មសិទ្ធិជាមួយមនុស្សទាំងនេះ?

________________________________________________________________________________

__________________________________________________________________________

២. តើសកម្មភាពក្រុមជំនុំត្រូវបានរៀបចំឡើង ដើម្បីឈោងចាប់«រង្វង់»របស់ខ្លួនដែរឬទេ?
បាទ ឬចាស ________ ទេ ________

៣. តើក្រុមជំនុំមានទំនាក់ទំនងជាមួយក្រុមជំនុំប្រូតេស្តង់ដំណឹងល្អដទៃទៀតនៅក្នុង«រង្វង់»របស់ខ្លួនយ៉ាងដូចម្តេច?
មានទំនាក់ទំនងល្អជាមួយក្រុមជំនុំទាំងអស់ ________
មានទំនាក់ទំនងល្អជាមួយក្រុមជំនុំខ្លះ មិនមានទំនាក់ទំនងល្អជាមួយក្រុមជំនុំខ្លះទៀត ________
មិនមានទំនាក់ទំនងល្អជាមួយក្រុមជំនុំណាទាំងអស់ ________

ខ. ធនធាន

១. តើក្រុមជំនុំមានធនធានប្រភេទអ្វីខ្លះនៅក្នុង«រង្វង់»របស់ខ្លួន? (គូររង្វង់ជុំវិញធនធានដែលមាន)
ទូរទស្សន៍/វិទ្យុ________ សៀវភៅ ________ រោងពុម្ព ________ ការអនុញ្ញាតផ្លូវការសម្រាប់ព័ន្ធកិច្ច «ជួយ» ________
ក្រុមគ្រិស្តបរិស័ទប្រូតេស្តង់ដំណឹងល្អដទៃទៀតដើម្បីធ្វើដៃគូជាមួយនៅក្នុងព័ន្ធកិច្ច (ក្រុមជំនុំមូលដ្ឋានដទៃទៀត) ________ ទីភ្នាក់ងារបេសកកម្មបរទេស/អង្គការ ________ ក្លិប ________
មជ្ឈមណ្ឌល ________ សមាគម ________ ស្ថាប័នអប់រំ ________

២. តើសព្វថ្ងៃនេះក្រុមជំនុំធ្វើជាដៃគូជាមួយក្រុមណាខ្លះនៅក្នុងគម្រោងព័ន្ធកិច្ចពិសេស?

__________________________________________________________________________

__________________________________________________________________________

៣. តើមានការខិតខំប្រឹងប្រែងដែលក្រុមជំនុំបានធ្វើឡើង ដើម្បីនិយាយជាមួយក្រុមជំនុំដទៃទៀតនៅក្នុង «រង្វង់»នេះអំពីការឈោងចាប់អ្នកមិនទាន់បានសង្គ្រោះនៅក្នុង«រង្វង់»នេះថ្វាយព្រះគ្រិស្តដែរឬទេ?
បាទ ឬចាស ________ ទេ ________

៤. តើអ្នកដឹកនាំក្រុមជំនុំព្រមធ្វើការជាមួយក្រុមជំនុំ និង អង្គការដទៃទៀតដើម្បីឈោងចាប់មនុស្សគ្រប់គ្នានៅក្នុង«រង្វង់»នេះថ្វាយព្រះគ្រិស្តដែរឬទេ?
បាទ ឬចាស ________ ទេ ________

ប្រសិនបើ «បាទ ឬចាស» តើពួកគេនឹងព្យាយាមប្រមូល«ធនធាននៅក្នុងរង្វង់»នេះ

ដើម្បីនិយាយអំពីការសម្រេចបេសកកម្មដែលផ្តោតលើព្រះគ្រិស្តនៅក្នុង«រង្វង់»របស់ពួកគេនៅពេលណា?

___

___

ប្រសិនបើ «ទេ» ហេតុអ្វីបានជា ទេ?

___

___

## ម៉ោងទី ២
## នេះជាអ្វីដែលព្រះយេស៊ូបានធ្វើសម្រាប់ខ្ញុំ! ការអភិវឌ្ឍន៍ និងការចែកចាយទីបន្ទាល់ផ្ទាល់ខ្លួន

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរដឹកនាំការពិភាក្សាជាក្រុមធំអំពីលក្ខណ:របស់ទីបន្ទាល់ ហើយ និងតម្លៃរបស់ទីបន្ទាល់។ ចូរបែងចែកបទគម្ពីរសម្រាប់ប្រធានបទនីមួយៗឲ្យសិក្ខាកាមផ្សេងៗគ្នាអាន ឮៗឲ្យក្រុមស្តាប់ ចូរអនុញ្ញាតឲ្យបទគម្ពីរទាំងនេះបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការពិភាក្សារបស់លោកអ្នក។ ចូរទុកពេល ១០ នាទីសម្រាប់ការពិភាក្សានេះ (១០ នាទី)។

លក្ខណ:របស់ទីបន្ទាល់
- ក. យើងត្រូវបានត្រាស់ហៅឲ្យធ្វើជាទីបន្ទាល់ (កិច្ចការ ១:៨)។
- ខ. យើងត្រូវបានត្រាស់ហៅឲ្យធ្វើបន្ទាល់ (កិច្ចការ ១០:៤២)។

តម្លៃរបស់ទីបន្ទាល់
- ក. យកឈ្នះការប្រឆាំងចំពោះដំណឹងល្អ (ទីបន្ទាល់ផ្ទាល់ខ្លួន កិច្ចការ ២៦:១២-១៨)
- ខ. យកឈ្នះអារក្សសាតាំងនៅក្នុងសង្គ្រាមខាងវិញ្ញាណ (វិវរណៈ ១២:១០-១២)

ការណែនាំសម្រាប់អ្នកសម្របសម្រួល:
- ចូរចែកចាយប្រាប់សិក្ខាកាមពីកត្តាគន្លឹះរបស់ទីបន្ទាល់ផ្ទាល់ខ្លួន។
- ចូរចែកជាក្រុមដែលមានគ្នាបីនាក់ ហើយឲ្យក្រុមនីមួយអានគំរូទីបន្ទាល់នៅក្នុងបទគម្ពីរខាងក្រោម។ ចូរសុំពួកគេឲ្យកំណត់អត្តសញ្ញាណកត្តាគន្លឹះដែលមាននៅក្នុងទីបន្ទាល់ក្នុងព្រះគម្ពីរទាំងនេះ (១០ នាទី)។

ការរៀបចំទីបន្ទាល់: កត្តាសំខាន់ៗ
1. តើលោកអ្នកមានជីវិតយ៉ាងដូចម្ដេច មុនពេលដែលលោកអ្នកបានជួបជាមួយព្រះគ្រិស្ត?
2. តើលោកអ្នកបានស្គាល់ព្រះគ្រិស្តដោយរបៀបណា?
3. តើការស្គាល់ព្រះគ្រិស្តបានផ្លាស់ប្តូរជីវិតរបស់លោកអ្នកយ៉ាងដូចម្ដេច?

គំរូនៅក្នុងព្រះគម្ពីរអំពីការធ្វើបន្ទាល់
- បុរសដែលកើតមកខ្វាក់ភ្នែក (យ៉ូហាន ៩:១៣-៣៤)
- ទីបន្ទាល់របស់លោកប៉ុលនៅចំពោះស្ដេចអ័គ្រីប៉ា (កិច្ចការ ២៦:១-៣១)

ការណែនាំសម្រាប់អ្នកសម្របសម្រួល:
- ចូររំឭកឡើងវិញការណែនាំខាងក្រោមសម្រាប់រៀបចំទីបន្ទាល់ខ្លួនជាមួយនឹងសិក្ខាកាម។
- ចូរអនុញ្ញាតឲ្យសិក្ខាកាមសរសេរតែម្នាក់ឯងប្រហែល ១៥ នាទីដើម្បីរៀបចំទីបន្ទាល់របស់ពួកគេ

ទីបន្ទាល់ [illegible] – ដោយរបៀបណា – បានផ្លាស់ប្តូរ
- ចូរបញ្ជាក់ប្រាប់សិក្ខាកាមថា ចំណុចសំខាន់គឺមានសេចក្ដីព្រាងដំបូងនៃទីបន្ទាល់របស់ពួកគេ។ ពួកគេនឹងមានឱកាសកែលម្អទីបន្ទាល់នោះ មុនពេលដែលពួកគេប្រើនៅក្នុងបរិបទជាក្រុមជំនុំ។
- សម្រាប់រយៈ ១៥ នាទីទៀតដែលនៅសល់ក្នុងម៉ោងសិក្សានេះ ចូរចែកថ្នាក់ទៅជាក្រុមដែលមានគ្នា ៣ នាក់ ចូរឲ្យម្នាក់ៗចែកចាយទីបន្ទាល់របស់ខ្លួនប្រាប់ក្រុមមិនឲ្យលើសពី ៥ នាទី។

ចូរសរសេរទីបន្ទាល់ផ្ទាល់ខ្លួនរបស់លោកអ្នកនៅក្នុងប្រឡោះដែលបានផ្ដល់ឲ្យ ដោយប្រើគ្រោងកត្តាគន្លឹះរបស់ទីបន្ទាល់ផ្ទាល់ខ្លួន។ ចូរឲ្យប្រាកដថា ទីបន្ទាល់របស់លោកអ្នក (១) ប្រើកត្តានីមួយៗក្នុងចំណោមកត្តាទាំង ៣ (២) ងាយយល់ (៣) ផ្ដោតលើដំណឹងល្អ (អ្វីដែលព្រះយេស៊ូបានធ្វើសម្រាប់ខ្ញុំ និងអាចធ្វើបានសម្រាប់អ្នក!) និង (៤) ខ្លី - ទីបន្ទាល់របស់លោកអ្នកមិនគួរវែងជាង ៥ នាទីទេនៅក្នុងការប្រាប់គេ។

អ្វីដែលព្រះយេស៊ូបានធ្វើសម្រាប់ខ្ញុំ: ការធ្វើបន្ទាល់ផ្ទាល់ខ្លួន

ស្ថានភាពជីវិតរបស់ខ្ញុំ មុនពេលដែលខ្ញុំបានជួបជាមួយព្រះយេស៊ូ:

របៀបដែលខ្ញុំបានស្គាល់ព្រះយេស៊ូ:

របៀបដែលការស្គាល់ព្រះយេស៊ូបានផ្លាស់ប្តូរជីវិតរបស់ខ្ញុំ:

## ផែនការសកម្មភាពសម្រាប់ម៉ូឌុល ៣: ចែកចាយទីបន្ទាល់របស់លោកអ្នកជាមួយអ្នកមិនជឿ ៥ នាក់ (៥ នាទី)

មុនដល់ការហ្វឹកហ្វឺនលើកក្រោយទៀត ចូរធ្វើជំហានសកម្មភាពខាងក្រោម:

- បន្តកែលម្អទីបន្ទាល់របស់លោកអ្នកដើម្បីឆ្លុះបញ្ចាំងឲ្យឃើញកាន់តែច្បាស់ពីការណែនាំនៅក្នុង «ការរៀបចំទីបន្ទាល់ផ្ទាល់ខ្លួនរបស់លោកអ្នក»។
- ចូរហាត់និយាយទីបន្ទាល់របស់លោកអ្នកញឹកញាប់ នៅពេលដែលលោកអ្នកនៅម្នាក់ឯង រហូតដល់លោកអ្នកត្រៀមខ្លួនរួចរាល់ដើម្បីចែកចាយប្រាប់គេ។
- ចូរសុំព្រះជាម្ចាស់ឲ្យរៀបចំ«ការណាត់ជួបមកពីព្រះ» ដើម្បីឲ្យលោកអ្នកចែកចាយទីបន្ទាល់របស់ខ្លួន (ប្រហែលជាមិនមានការប្រាប់ឲ្យដឹងទុកជាមុន) នៅក្នុងរយៈពេលបួនសប្តាហ៍បន្ទាប់។
- ចូរចែកចាយទីបន្ទាល់របស់លោកអ្នកប្រាប់គ្រិស្តបរិស័ទដទៃទៀតយ៉ាងហោចណាស់បីនាក់ ដែលនឹងជួយមើលថាតើលោកអ្នកប្រាប់ច្បាស់នៅក្នុងបទបង្ហាញរបស់លោកអ្នកដែរឬយ៉ាងណា។
- ចូរចែកចាយទីបន្ទាល់របស់លោកអ្នកប្រាប់មិត្តភក្តិដែលមិនជឿ ឬអ្នកដែលមានទំនាក់ទំនងជាមួយយ៉ាងហោចណាស់ឲ្យបានប្រាំនាក់នៅក្នុងសប្តាហ៍បន្ទាប់។ ចូរប្រាប់ទីបន្ទាល់របស់លោកអ្នកដល់អ្នកមិនជឿប្រាំនាក់ទៀតនៅក្នុងតំបន់គោលដៅសម្រាប់ក្រុមជំនុំថ្មីរបស់លោកអ្នក មុនដល់ការហ្វឹកហ្វឺនលើកក្រោយទៀត។
- ចូរនាំយកអ្នកជឿម្នាក់ទៅជាមួយលោកអ្នកធ្វើជាសិស្ស នៅពេលដែលលោកអ្នកទៅសួរសុខទុក្ខមនុស្ស។
- ចូរត្រៀមខ្លួនដើម្បីចែកចាយទីបន្ទាល់របស់លោកអ្នកម្តងទៀតនៅក្នុងអំឡុងពេលហ្វឹកហ្វឺនលើកក្រោយទៀត ឬនៅក្នុងអំឡុងពេលសិក្ខាសាលានេះ។

# ម៉ោងទី ៣
# ការដឹកនាំក្រុមតូច (៦០ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: នៅពេលដែលលោកអ្នកចែកចាយគោលគំនិតទូទៅទាំងបីអំពីការដឹកនាំនៅខាងក្រោម ចូរឲ្យសិក្ខាកាមបំពេញនៅក្នុងប្រឡោះដែលបានផ្តល់ឲ្យនៅក្នុងសៀវភៅលំហាត់របស់ពួកគេ។ សម្រាប់គោលគំនិតនីមួយៗ ចូរដឹកនាំការពិភាក្សាសង្ខេបជាក្រុមធំ ដោយប្រើសំណួរដែលបានផ្តល់ឲ្យជាមួយនឹងគោលគំនិតនីមួយៗ។

គោលគំនិតទូទៅអំពីការដឹកនាំ (២០ នាទី)

១. ធ្វើគំរូអំពីជីវិតជាគ្រិស្តបរិស័ទ
- តើការធ្វើជាគំរូមានតួនាទីយ៉ាងដូចម្តេចនៅក្នុងការដឹកនាំដែលមាននៅក្នុងសញ្ញាថ្មី? ១ ថែស្សាឡូនីច ១:៦-៧, ១ កូរិនថូស ១១:១

២. អភិវឌ្ឍអ្នកដឹកនាំថ្មី
- តើអ្នកដឹកនាំហាត់ការសម្រាប់ក្រុមតូចមានន័យយ៉ាងដូចម្តេច?
- តើអ្នកដឹកនាំក្រុមតូចគួរតែរកមើលលក្ខណៈអ្វីខ្លះនៅក្នុងការជ្រើសរើសអ្នកដឹកនាំហាត់ការ?
- តើអ្នកដឹកនាំក្រុមតូចគួរតែបែងចែកសកម្មភាព និងការទទួលខុសត្រូវឲ្យសមាជិកទាំងអស់នៅក្នុងក្រុមតូច ដោយមិនមែនឲ្យតែអ្នកដឹកនាំហាត់ការ (អ្នកដែលកំពុងទទួលការហ្វឹកហ្វឺនដើម្បីដឹកនាំក្រុមតូច) ដែរឬទេ? ហេតុអ្វីគួរ ឬហេតុអ្វីមិនគួរ?
- ក្រោយពីចាប់ផ្តើមក្រុមរួចហើយ តើអ្នកដឹកនាំក្រុមតូចគួរតែរង់ចាំយូរប៉ុនណា ទើបជ្រើសរើសអ្នកដឹកនាំហាត់ការ?
- តើអ្នកដឹកនាំក្រុមតូចអាចធ្វើសកម្មភាពប្រភេទអ្វីខ្លះជាមួយអ្នកហាត់ការ ដើម្បីរៀបចំគាត់ដឹកនាំក្រុមរបស់ខ្លួនឯង?

៣. បំពាក់បំប៉ន និងបញ្ជូនចេញទៅធ្វើព័ន្ធកិច្ច
- ក្រុមតូចជួយបំពាក់បំប៉នអ្នកដឹកនាំ ដោយផ្តល់ឱកាសសម្រាប់ការដឹកនាំនៅក្នុងក្រុមតូច។ តើអ្នកដឹកនាំថ្មីអាចរៀនបានការប្រភេទអ្វីខ្លះចេញពីការបំពេញការទទួលខុសត្រូវនៅក្នុងក្រុមតូច? ចូរឲ្យឧទាហរណ៍។

ការដឹកនាំការជួបប្រជុំក្រុមតូច (៥ នាទី)
ការណែនាំសម្រាប់អ្នកសម្របសម្រួល: ដោយប្រើរបៀបបង្រៀន ចូរឲ្យសិក្ខាកាមបំពេញប្រឡោះនៅក្នុងសៀវភៅលំហាត់របស់ពួកគេ នៅពេលដែលលោកអ្នកចែកចាយព័ត៌មានខាងក្រោម។ ចូរប្រាប់អំពីធនធានដែលបានផ្តល់ឲ្យនៅខាងចុងមេរៀនក្នុងម៉ោងសិក្សានេះ (១) ល្បែងកម្សាន្តក្នុងការជួបប្រជុំក្រុមតូច (២) សំណួរចាប់ផ្តើមការពិភាក្សាជាក្រុម និង (៣) គំរូសកម្មភាពក្រុមតូច។

ធ្វើគំរូ - អភិវឌ្ឍ - បំពាក់បំប៉ន - បញ្ជូនចេញ

ចូរនិយាយថា៖ «ការជួបប្រជុំក្រុមតូចទូទៅនឹងមានកត្តាជាច្រើនដែលនឹងកើតឡើងតាមលំដាប់លំដោយដូចជាការប្រជុំទាំងឡាយដែរ។ ឥឡូវនេះ ខ្ញុំនឹងចែកចាយប្រាប់លោកអ្នកកត្តារបស់ការជួបប្រជុំក្រុមតូចទូទៅ ហើយខ្ញុំនឹងចែកចាយតាមលំដាប់លំដោយដែលកត្តាទាំងនោះកើតឡើង»។

១. ការប្រកប និងការចែកចាយនៅក្នុងចំណោមសមាជិកក្រុម
២. ការថ្វាយបង្គំដែលរួមបញ្ចូលការអធិស្ឋាន ការច្រៀង និងការសរសើរតម្កើងដល់ព្រះ
៣. ការសិក្សាព្រះគម្ពីរ និងការពិភាក្សា
៤. ការនិមិត្តឃើញព័ន្ធកិច្ចដែលសមាជិកពិភាក្សាអំពីសកម្មភាពផ្ទាល់ខ្លួន និងជាក្រុម ដើម្បីឈោងចាប់មិត្តភក្តិ អ្នកជិតខាង ហើយប្រហែលជាក្រុមធំជាងនេះជាមួយនឹងដំណឹងល្អ។ នេះក៏ប្រហែលជារួមបញ្ចូលពេលអធិស្ឋានសម្រាប់បុគ្គលជាក់លាក់ដែលមិនទាន់បានអញ្ជើញឲ្យមកចូលរួមនៅក្នុងក្រុម។

រដ្ឋបាលក្រុមតូច (១០ នាទី)
ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរដឹកនាំក្រុមធំនៅក្នុងការពិភាក្សាសំណួរខាងក្រោម

អំពីផ្នែករដ្ឋបាលនៅក្នុងការដឹកនាំក្រុមតូច។

- ហេតុអ្វីបានជាអ្នកដឹកនាំក្រុមតូចគួរតែអភិវឌ្ឍផែនការសម្រាប់ក្រុម និងការជួបប្រជុំនីមួយៗ? ហេតុអ្វីមិនបណ្តោយឲ្យក្រុមទៅ«តាមដំណើរ»តាមទិសណាក៏ដោយដែលក្រុមចង់ទៅ?
- តើតម្រូវឲ្យមានការរៀបចំប្រភេទណា ដើម្បីឲ្យការជួបប្រជុំនីមួយៗបំពេញសេចក្តីត្រូវការខាងក្រោម?
    - ក. ទីតាំង
    - ខ. ការប្រកប
    - គ. ការថ្វាយបង្គំ
    - ឃ. ការអធិស្ឋាន
    - ង. ការពិភាក្សាព្រះគម្ពីរ
    - ច. ការបង្រៀនសិស្ស
    - ឆ. ការផ្សាយដំណឹងល្អ

- ហេតុអ្វីបានជាសំខាន់ដែលសមាជិកថ្មីម្នាក់ៗនៅក្នុងក្រុមគួរតែមាន«ឪពុកម្តាយ»ខាងវិញ្ញាណដែលនឹងបង្រៀនគេ?

សកម្មភាពក្រុមតូច (២៥ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរបែងចែកសិក្ខាកាមទៅជាក្រុមដែលគ្មាន ៥ ទៅ ៨ នាក់។ ចូរចាត់តាំងសមាជិកម្នាក់ឲ្យដើរតួជាអ្នកដឹកនាំក្រុមតូច។ ម្នាក់ទៀតដើរតួជាអ្នកហាត់ការ អ្នកដែលនៅសល់ដើរតួជាសមាជិកក្រុមតូច។ ចូរអានការណែនាំខាងក្រោមឲ្យថ្នាក់ស្តាប់។ ចូរឆ្លើយសំណួរដែលសិក្ខាកាមប្រហែលជាមាននៅពីលំហាត់នេះ។

ការប្រកប – ការថ្វាយបង្គំ – ការសិក្សាព្រះគម្ពីរ – ការនិមិត្តឃើញពន្ធកិច្ច

ការណែនាំ:

១. ដំបូង ចូរលេងល្បែង «ខ្ញុំប្រាកដថា អ្នកមិនដឹងការនេះទេ» សម្រាប់ការប្រកបនៅក្នុងក្រុមតូចចេញពីបញ្ជីល្បែងកម្សាន្តក្នុងការជួបប្រជុំក្រុមតូចដែលមាននៅខាងក្រោម។
២. បន្ទាប់មក អ្នកដឹកនាំក្រុមតូច នឹងអ្នកហាត់ការនឹងជ្រើសរើសយកសំណួរមួយចេញពីបញ្ជីការពិភាក្សាជាក្រុមដែលមាននៅខាងក្រោម (លោកអ្នកអាចប្រើប្រយោគ «តើអ្វីជាពេលដ៏រីករាយបំផុតនៅក្នុងជីវិតរបស់អ្នក?»)។
៣. ក្រោយពីលេងល្បែងកម្សាន្ត និងការពិភាក្សាជាក្រុមរួចហើយ ក្រុមតូចគួរតែមានពេលអធិស្ឋានឲ្យគ្នាទៅវិញទៅមក។
៤. ក្រុមគួរតែវាយតម្លៃ និងពិភាក្សាអំពីការជួបប្រជុំក្រុមតូច។ ប្រសិនបើមានសិស្សតិច លោកអ្នកអាចឲ្យសិស្សទាំងអស់ធ្វើលំហាត់នេះជាក្រុមមួយ។

# ល្បែងកម្សាន្តក្នុងការជួបប្រជុំក្រុមតូច

«ល្បែងកម្សាន្ត» គឺជាវិធីដែលសប្បាយ និងដែលមិនគំរាមកំហែង ដើម្បីស្គាល់មនុស្សកាន់តែច្បាស់។ ជាញឹកញាប់ សកម្មភាពទាំងនេះត្រូវបានប្រើនៅក្នុងអំឡុងពេលប្រកបគ្នារបស់ក្រុមតូច។ កំណត់សម្គាល់មួយចំនួន:

- ល្បែងកម្សាន្តគួរតែស័ក្តិសមនឹងក្រុម។ ប្រសិនបើល្បែងមានលក្ខណៈកូនក្មេងពេក មនុស្សមិនស្រួលចិត្ត។ ប្រសិនបើល្បែងមានលក្ខណៈគំរាមកំហែងពេក មនុស្សដកថយ។
- ចូរបញ្ជាក់ឲ្យច្បាស់ថា គ្រប់គ្នាត្រូវបានអញ្ជើញ និងលើកទឹកចិត្តឲ្យចូលរួម។
- ល្បែងកម្សាន្តមួយចំនួនអាចប្រើបានច្រើនជាងមួយដង។
- ចូរវាសវៃដឹងអំពីមនុស្សដែលត្រលប់ជាមិនស្រួលចិត្តជាមួយនឹងល្បែង ឬសកម្មភាព។
- ល្បែងកម្សាន្តត្រលប់ជាកាន់តែខ្លី និងកាន់តែមិនសូវសំខាន់ ពេលដែលក្រុមផ្សាភ្ជាប់គ្នាយ៉ាងស្អិតរមួតក្នុងដំណើរវដ្តជីវិតក្រុមតូចហើយនោះ។ នៅក្នុងការជួបប្រជុំពីរលើកដំបូង លោកអ្នកប្រហែលជាចំណាយពេលពាក់កណ្ដាលទៅលើល្បែងកម្សាន្ត ប៉ុន្តែពីរបីខែក្រោយមក លោកអ្នកប្រហែលជាត្រូវការចំណាយពេល ១០ ឬ ១៥ នាទីតែប៉ុណ្ណោះ។

សំណួរដើម្បីស្គាល់គ្នាទៅវិញទៅមក
នៅពេលដែលលោកអ្នកអាយុចន្លោះ ៧-១២ ឆ្នាំ...

១. តើលោកអ្នកបានរស់នៅឯណា? តើលោកអ្នកមានបងប្អូនប្រុសស្រីប៉ុន្មាននាក់?
២. តើគ្រួសាររបស់លោកអ្នកបានប្រើមធ្យោបាយធ្វើដំណើរប្រភេទអ្វី?
៣. តើមនុស្សដែលលោកអ្នកមានអារម្មណ៍ជិតស្និទ្ធបំផុតគឺជានរណា?
៤. តើព្រះជាម្ចាស់បានត្រលប់ជាការពិតសម្រាប់លោកអ្នកនៅពេលណា?

តើខ្ញុំគឺជានរណា?*
ចូរសរសេរឈ្មោះតួអង្គល្បីៗ និង / ឬតួអង្គនៅក្នុងព្រះគម្ពីរលើបំណែកក្រដាសតូចៗ។ ចូរបិតបំណែកក្រដាសទាំងនោះនៅលើខ្នងមនុស្សគ្រប់គ្នា។ គេមិនអាចមើលបំណែកក្រដាសរបស់ខ្លួនឯងបានទេ។ គេដើរជុំវិញបន្ទប់ សួរសំណួរម្ដងមួយអំពីគេជានរណា រហូតដល់គេទាយដឹងថា គេគឺជានរណា។

*សម្រាប់ប្រើតែនៅក្នុងក្រុមដែលមនុស្សទាំងអស់ស្គាល់ព្រះគម្ពីរប៉ុណ្ណោះ។

ខ្ញុំជឿប្រាកដថា អ្នកដឹងមិនដឹងរឿងនេះទេ
មនុស្សម្នាក់ៗនៅក្នុងក្រុមសរសេរនៅលើក្រដាសមួយសន្លឹកពីអ្វីមួយដែលគេគិតថា គ្មាននរណាម្នាក់នៅក្នុងក្រុមដឹងអំពីគេឡើយ។ បត់ក្រដាស ដាក់ចូលគ្នា ហើយដាក់លេខតាមលំដាប់លំដោយ។ អ្នកដែលបានទទួលបានការចាត់តាំងចាប់ផ្ដើមអាន ដោយនិយាយលេខរាងមុនគេ។ សមាជិកម្នាក់ៗនៅក្នុងក្រុមចាប់ផ្ដើមធ្វើបញ្ជីមនុស្សដែលគេគិតថាត្រូវនឹងលេខរាងរបស់សម្ងាត់កម្មនីមួយៗ។ ក្រោយពីអានសម្ងាត់កម្មចុងក្រោយរួច អ្នកដែលផ្គូផ្គងត្រូវច្រើនជាងគេបង្អស់គឺជាអ្នកឈ្នះ។

ការណែនាំ
មនុស្សគ្រប់គ្នានៅក្នុងក្រុមត្រូវបានប្រាប់ថា ពួកគេមានពេលច្រើននាទីដើម្បីគិតរកសំណួរមួយ ហើយសួរសំណួរនោះទៅមនុស្សដទៃទៀតនៅក្នុងក្រុម។ ក្រោយពីគ្រប់គ្នាបានគិតឃើញសំណួររួចហើយ ពួកគេគួរតែចាប់ផ្ដើមទៅជួបគ្នា សួរសំណួររបស់ខ្លួន។ ចូរសរសេរឈ្មោះ និងចម្លើយរបស់មនុស្សម្នាក់ៗ។ ប្រហែលជាដប់នាទីក្រោយមក ចូរត្រលប់ជារង្វង់វិញ ហើយឲ្យម្នាក់ៗប្រាប់អ្វីដែលគេបានរកឃើញអំពីមនុស្សដទៃទៀត។ សំណួរកាន់តែល្អ លោកអ្នកនឹងទទួលបានចម្លើយដែលកាន់តែមានលក្ខណៈឆ្នៃប្រឌិត និងគួរឲ្យចាប់អារម្មណ៍។

សេចក្ដីពិតពីរ និងការកុហកមួយ
គ្រប់គ្នាសរសេរការពិតពីរយ៉ាងអំពីខ្លួនឯង និងការកុហកមួយ។ បន្ទាប់មក គ្រប់គ្នាសម្រេចថា បំណែកក្រដាសមួយណាត្រូវនឹងអ្នកណា ហើយប្រយោគមួយណាជាការកុហក។ លោកអ្នកប្រហែលជាទុកចោលផ្នែកទីមួយ (ឧទាហរណ៍ គ្រប់គ្នាលើកក្រដាសខ្លួនឯងឡើង ហើយអ្នកដទៃទៀតទាយថា ប្រយោគមួយណាជា

ការកុហក)។ (វាមិនយុត្តធម៌ឡើយ ប្រសិនបើគេរើសយកការកុហកដែលស្ទើរតែដូចការពិតនោះ)។

របាយការណ៍អាកាសធាតុ
ដើរជុំវិញជារង្វង់ ដោយចាប់ផ្ដើមជាមួយនឹងអ្នកដឹកនាំ ហើយពណ៌នាពីអារម្មណ៍ដែលលោកអ្នកមាននៅពេលឥឡូវនេះ ហាក់ដូចជារបាយការណ៍អាកាសធាតុ-មានពពកខ្លះ ក្ដៅ។ល។ សិស្សអាចពន្យល់ពីមូលហេតុដែលពួកគេបានជ្រើសរើសយកអាកាសធាតុប្រភេទនោះ។ អ្នកដឹកនាំធ្វើគំរូអំពីរបៀបចែកចាយ។

ការដើរដោយទុកចិត្ត
ចែកក្រុមជាគូពីរៗនាក់។ ម្នាក់ៗនៅក្នុងគូនីមួយៗចងបិទភ្នែក។ អ្នកដែលមិនបានចងបិទភ្នែកនាំអ្នកដែលចងបិទភ្នែកដើរជុំវិញកន្លែងជួបប្រជុំ។ ចូរព្យាយាមផ្ដល់បទពិសោធន៍ផ្សេងៗឲ្យបានច្រើន-នាំឡើងកាំជណ្ដើរ ចេញទៅក្រៅ ចូលមកក្នុង ជួយពួកគេស្ទាបរបស់ផ្សេងៗ ដើរល្បឿនផ្សេងគ្នា ដើរនៅលើកន្លែងផ្សេងគ្នា (ស្មៅ ឥដ្ឋ ដី) ប៉ុន្តែកុំនិយាយអ្វីឲ្យសោះ ក្រោយពេលចាប់ផ្ដើមដើរ។ លោកអ្នកត្រូវប្រាប់សារទាំងអស់ ដោយមិនប្រើពាក្យសំដី។ ប្រហែលជា ៥ នាទីក្រោយមក ប្ដូរវេនម្ដង។ ប្រាំនាទីក្រោយទៀត ក្រុមជួបជុំគ្នាឡើងវិញ។ ចូរចែកចាយពីប្រភេទអារម្មណ៍ដែលលោកអ្នកមាន នៅពេលដែលលោកអ្នកត្រូវបានចងបិទភ្នែក និងនៅពេលដែលលោកអ្នកប៉ះរបស់ផ្សេងៗ។ តើលោកអ្នកមានអារម្មណ៍យ៉ាងដូចម្ដេចអំពីមនុស្សម្នាក់ទៀត? តើមានអារម្មណ៍យ៉ាងដូចម្ដេច ពេលដែលមិនអាចគ្រប់គ្រងបានលើអ្វីដែលកំពុងកើតឡើង? តើលោកអ្នករៀនបានអ្វីអំពីខ្លួនឯង? តើការនេះអនុវត្តយ៉ាងដូចម្ដេចចំពោះទំនាក់ទំនងរបស់លោកអ្នកជាមួយព្រះ? ជាមួយអ្នកដទៃទៀត?

ល្បែងកាក់
ពេលខ្លះ ប្រសិនបើលោកអ្នកមានអ្នកថ្មីនៅក្នុងការជួបប្រជុំរបស់លោកអ្នក លោកអ្នកប្រហែលជានឹកចាំល្បែងកាក់សម្រាប់លេងកម្សាន្ត។ ឲ្យមនុស្សគ្រប់គ្នាដប់កាក់។ គ្រប់គ្នាត្រូវប្រាប់ការមួយអំពីខ្លួនឯងដែលខុសពីអ្នកដទៃទៀត (ឧទាហរណ៍ សមាជិកក្រុមដែលចូលចិត្តដើរផ្សងព្រេងប្រហែលជានិយាយថា៖ «ខ្ញុំបានឡើងលើកំពូលភ្នំឱរ៉ាល់»)។ អ្នកនិយាយដាក់កាក់មួយនៅចំកណ្ដាល ប្រសិនបើអ្នកផ្សេងទៀតបានឡើងលើកំពូលភ្នំឱរ៉ាល់ដែរ គេអាចដាក់កាក់ចូលបានដែរ។ អ្នកទីមួយដែលអស់កាក់មុនគេគឺជាអ្នកឈ្នះ។

ក្រុមទាយតាមកាយវិការ
សម្រាប់សកម្មភាពនេះ លោកអ្នកត្រូវការពីរក្រុម និងពីរបន្ទប់។ ចូរចែកទៅជាពីរក្រុម។ ក្រុម ក គិតរកសកម្មភាពមួយឲ្យក្រុម ខ ធ្វើ (ឧទាហរណ៍ បរិភោគអាហារពេលព្រឹក) ដោយមិនឲ្យនិយាយឡើយ។ ក្រុម ក ប្រាប់មនុស្សតែម្នាក់គត់ (យើងដាក់ឈ្មោះនាងថា «គន្ធា») មកពីក្រុម ខ ពីសកម្មភាពនោះ ហើយគន្ធាមិនត្រូវបានអនុញ្ញាតឲ្យប្រាប់អ្នកផ្សេងទៀតនៅក្នុងក្រុមរបស់នាងឡើយ។ ក្រុម ខ រង់ចាំនៅក្នុងបន្ទប់ទីមួយ នៅពេលដែលគន្ធានាំយកមនុស្សម្នាក់ទៀតមកពីក្រុមរបស់នាង (យើងដាក់ឈ្មោះគាត់ «រដ្ឋា») ចូលមកក្នុងបន្ទប់ទីពីរ។ នៅក្នុងបន្ទប់ទីពីរ ក្រុម ក មើលគន្ធាធ្វើសកម្មភាពបង្ហាញរដ្ឋា (សូមចាំថា មិនឲ្យនិយាយឡើយ!)។ បន្ទាប់មក គន្ធាត្រលប់ទៅបន្ទប់ទីមួយវិញ ហើយឲ្យម្នាក់ទៀតពីក្រុម ខ ចូលមក។ បន្ទាប់មក រដ្ឋាធ្វើសកម្មភាពឲ្យអ្នកបន្ទាប់មើល រួចត្រលប់ទៅបន្ទប់ទីមួយវិញ បញ្ជូនមនុស្សម្នាក់ទៀតពីក្រុមរបស់គាត់មក។ ដំណើរការនេះបន្តរហូតដល់អ្នកចុងក្រោយនៅក្នុងក្រុម ខ មើលសកម្មភាពនោះ។ អ្នកចុងក្រោយនេះត្រូវទាយថាសកម្មភាពនោះជាអ្វី។ បន្ទាប់មក ក្រុមប្ដូរវេន គឺក្រុម ខ គិតរកសកម្មភាពឲ្យក្រុម ក ធ្វើវិញ។

ចម្លើយ និងអ្នកនិពន្ធ
នៅលើក្រដាសមួយសន្លឹក ចូរសរសេរបួន ឬប្រាំសំណួរដែលមិនបង្កឲ្យមានអារម្មណ៍មិនស្រួលចិត្ត ប៉ុន្តែបង្ហាញប្រាប់អ្វីម្យ៉ាងអំពីមនុស្សម្នាក់ (ឧទាហរណ៍ តើរបស់ដែលអ្នកពេញចិត្តជាងគេគឺជាអ្វី? តើអ្នកចង់ឲ្យខ្លួនឯងអាចធ្វើបាន ដែលអ្នកមិនអាចធ្វើបាននៅពេលឥឡូវនេះ? តើអ្នកចង់មានវិស្សមកាលយ៉ាងដូចម្ដេច?)។ មនុស្សគួរតែឆ្លើយសំណួរទាំងអស់ ឬយ៉ាងហោចណាស់បីសំណួរ ប៉ុន្តែចូរណែនាំពួកគេកុំឲ្យដាក់ឈ្មោះនៅលើក្រដាសឡើយ។ អ្នកដឹកនាំប្រមូលក្រដាស ហើយអានចម្លើយឮៗ បន្ទាប់មក គ្រប់គ្នាព្យាយាមទាយថាជាចម្លើយរបស់អ្នកណា។

អ្នកជិតខាងទាំងអស់របស់ខ្ញុំ
គ្រប់គ្នាចាប់ផ្តើមដោយអង្គុយនៅលើកៅអីដែលរៀបជារង្វង់ លើកលែងតែម្នាក់ចាប់ផ្តើមដោយឈរនៅចំកណ្តាល។ អ្នកនៅកណ្តាលត្រូវរក«អ្នកជិតខាង»មួយចំនួន។ ដើម្បីរកបាន គាត់ត្រូវនិយាយប្រយោគពិតមួយអំពីខ្លួនឯង ដែលនឹងពិតផងដែរអំពីអ្នកផ្សេងទៀតនៅក្នុងក្រុម (ឧទាហរណ៍ «អ្នកជិតខាងទាំងអស់របស់ខ្ញុំលេងព្យ៉ាណូ» ឬ «អ្នកជិតខាងទាំងអស់របស់ខ្ញុំប្រើដៃស្តាំ»)។ គ្រប់គ្នាដែលអាចនិយាយប្រយោគនេះបានត្រូវក្រោកឈរឡើង ហើយរកកៅអីអង្គុយថ្មី។ គេមិនអាចត្រលប់ទៅកៅអីដើមវិញបានទេ។ អ្នកនៅកណ្តាលក៏ត្រូវរកកៅអីអង្គុយដែរ។ ដូច្នេះ រាល់ពេលនឹងមាននៅសល់មនុស្សម្នាក់នៅកណ្តាលគ្មានកៅអីអង្គុយ។ បន្ទាប់មក អ្នកនោះត្រូវនិយាយប្រយោគពិត ហើយត្រូវរក«អ្នកជិតខាង»មួយចំនួន ដែលប្រយោគនោះពិតអំពីពួកគេផងដែរ។

ការពិភាក្សាជាក្រុម
ខាងក្រោមនេះ មានជម្រើសជាច្រើនសម្រាប់សំណួរដែលអាចត្រូវបានប្រើនៅក្នុងអំឡុងពេលល្បែងកម្សាន្ត។ សូមកត់សម្គាល់ថា សំណួរមួយចំនួនល្អសម្រាប់ក្រុមថ្មី ហើយសំណួរមួយចំនួនទៀតល្អសម្រាប់ក្រុមដែលសមាជិកក្រុមស្គាល់គ្នាបន្តិចរួចហើយ។ ជាធម្មតា ប្រើសំណួរតែមួយប៉ុណ្ណោះនៅក្នុងការជួបប្រជុំក្រុមតូចនីមួយៗ។ សំណួរអាចជ្រើសរើសបាន ពីព្រោះសំណួរនឹងជួយមនុស្សឲ្យស្គាល់គ្នាកាន់តែច្បាស់ ឬពីព្រោះសំណួរទាំងនោះផ្សាភ្ជាប់ទៅនឹងប្រធានបទរបស់ការសិក្សាព្រះគម្ពីរនៅក្នុងការជួបប្រជុំនោះ។

១. តើពេលដែលរីករាយបំផុតនៅក្នុងជីវិតរបស់លោកអ្នកគឺជាអ្វី?
២. តើការសោកស្តាយធំបំផុតនៅក្នុងជីវិតរបស់លោកអ្នកគឺជាអ្វី?
៣. តើកិច្ចការដ៏លំបាកបំផុតដែលលោកអ្នកបានធ្វើគឺជាអ្វី?
៤. តើការសរសើរដ៏អស្ចារ្យបំផុតដែលលោកអ្នកបានទទួលគឺជាអ្វី?
៥. តើមិត្តដ៏ល្អបំផុតរបស់លោកអ្នកនៅលើផែនដីគឺជានរណា?
៦. តើលោកអ្នកចូលចិត្តបន្ទប់មួយណាជាងគេនៅក្នុងផ្ទះរបស់លោកអ្នក?
៧. តើកិច្ចការមួយដែលលោកអ្នកចង់សម្រេចនៅសប្តាហ៍ក្រោយគឺជាអ្វី?
៨. កាលពីនៅក្មេង តើលោកអ្នកមានអារម្មណ៍កក់ក្តៅបំផុត និងសុវត្ថិភាពបំផុតនៅកន្លែងណា?
៩. ប្រសិនបើលោកអ្នកមានម៉ាស៊ីនពេលវេលាដែលធ្វើការបានតែមួយដង តើលោកអ្នកចង់ទៅចំណុចអ្វីនៅក្នុងពេលអនាគត ឬនៅក្នុងប្រវត្តិសាស្ត្រ?
១០. តើពេលចុងក្រោយដែលលោកអ្នកបានធ្វើកិច្ចការមួយជាលើកដំបូងគឺនៅពេលណា?
១១. ប្រសិនបើលោកអ្នកអាចលេបថ្នាំមួយគ្រាប់ដែលជួយឲ្យលោកអ្នកអាចរស់នៅដល់អាយុ ១០០០ឆ្នាំ តើលោកអ្នកនឹងលេបទេ? ហេតុអ្វី?
១២. តើលោកអ្នកចង់ដឹងកាលបរិច្ឆេទដែលលោកអ្នកត្រូវស្លាប់ដែរឬទេ?
១៣. តើសាច់ញាតិដែលលោកអ្នកត្រូវជាមួយគឺជានរណា? ហេតុអ្វី?
១៤. តើការចងចាំដ៏ល្អដែលលោកអ្នកមានជាមួយឪពុករបស់លោកអ្នកកាលពីនៅក្មេងគឺជាអ្វី? ជាមួយម្តាយរបស់លោកអ្នក?
១៥. តើព្រះជាម្ចាស់បានប្រើនរណាដើម្បីនាំលោកអ្នកមកដល់ចំណុចដែលលោកអ្នកដឹងថា លោកអ្នកត្រូវការព្រះយេស៊ូ?
១៦. ប្រសិនបើលោកអ្នកអាចប្តូរកន្លែងជាមួយតួអង្គនៅក្នុងព្រះគម្ពីរបាន តើលោកអ្នកនឹងជ្រើសរើសយកនរណា? ហេតុអ្វី?
១៧. តើកណ្ឌគម្ពីរដែលលោកអ្នកពេញចិត្តគឺជាអ្វី? ហេតុអ្វី?
១៨. ប្រសិនបើលោកអ្នកអាចទៅកន្លែងណាក៏បាននៅក្នុងពិភពលោក តើលោកអ្នកនឹងទៅកន្លែងណា?
១៩. ឧបមាថា ផ្ទះរបស់លោកអ្នកកំពុងត្រូវបានអគ្គីភ័យឆាបឆេះ ហើយគ្រួសារទាំងអស់របស់លោកអ្នកមានសុវត្ថិភាព ប៉ុន្តែលោកអ្នកមានពេលយកបានរបស់តែមួយគត់ចេញមកជាមួយ តើលោកអ្នកនឹងយកអ្វី?
២០. តើលោកអ្នកចូលចិត្តខ្សែភាពយន្តអ្វី ឬកម្មវិធីអ្វីនៅតាមទូរទស្សន៍?
២១. តើនរណាមានឥទ្ធិពលខ្លាំងបំផុតមកលើជីវិតរបស់លោកអ្នក ចាប់តាំងពីពេលដែលយើងបានជួបជុំគ្នាចុងក្រោយ?
២២. តើការដ៏ល្អបំផុតដែលបានកើតឡើងចំពោះលោកអ្នកកាលពីសប្តាហ៍មុននេះគឺជាអ្វី?
២៣. ចូរប្រាប់ឈ្មោះមនុស្សម្នាក់ដែលលោកអ្នកកោតសរសើរ ដោយព្រោះគេបានយកឈ្នះឧបសគ្គធំៗ ដើម្បីបានដូចសព្វថ្ងៃនេះ។
២៤. តើលោកអ្នកឲ្យតម្លៃអ្វីជាងគេបំផុតនៅក្នុងទំនាក់ទំនងខាងសាច់ឈាម? នៅក្នុងទំនាក់ទំនងរបស់លោកអ្នកជាមួយព្រះគ្រីស្ទ? ឪពុកម្តាយរបស់លោកអ្នក?

២៥. តើលោកអ្នកចូលចិត្តពេលណាជាងគេនៅក្នុងមួយថ្ងៃ?
២៦. (អ្នកនៅលីវ) ចូរពណ៌នាប្រភេទមនុស្សដែលលោកអ្នកចង់រៀបការជាមួយ។ (អ្នកមានប្តីប្រពន្ធ) តើអ្វី នាំលោកអ្នកឲ្យបានរៀបការជាមួយប្តី ឬប្រពន្ធរបស់លោកអ្នក?
២៧. តើលោកអ្នកនឹងមិនភ្លេចអំណោយអ្វី (ក្រៅពីការប្រែចិត្តជឿរបស់លោកអ្នក)?
២៨. តើព្រឹត្តិការណ៍ដ៏សំខាន់បំផុតនៅក្នុងជីវិតរបស់លោកអ្នកកាលពីសប្តាហ៍មុននេះគឺជាអ្វី?
២៩. ប្រសិនបើលោកអ្នកអាចជ្រើសរើសទៅកន្លែងណាក៏បាននៅក្នុងពិភពលោករយៈពេលបីថ្ងៃ តើលោកអ្នកនឹងទៅកន្លែងណា ហើយហេតុអ្វី?
៣០. ប្រសិនបើលោកអ្នកអាចជ្រើសរើសជួបនរណាក៏បានដែលរស់នៅក្នុងប្រទេសរបស់លោកអ្នក តើអ្នកនោះនឹងជានរណា ហើយហេតុអ្វីបានជាលោកអ្នកចង់ជួបគេ?
៣១. ប្រសិនបើលោកអ្នកអាចជ្រើសរើសរស់នៅកន្លែងណាក៏បាននៅក្នុងពិភពលោក តើលោកអ្នកនឹងរស់នៅកន្លែងណា ហើយហេតុអ្វី?
៣២. តើលោកអ្នកជឿថា លោកអ្នកកំពុងនាំយកអំណោយទានអ្វី (ខាងវិញ្ញាណ ខាងអារម្មណ៍ ខាងស្មារតី។ល។) មកក្នុងក្រុមនេះ? (និយាយម្យ៉ាងទៀតថា តើលោកអ្នកគិតថា លោកអ្នកកំពុងនាំយកអ្វីមកដែលរួមចំណែកលើកទឹកចិត្តអ្នកដទៃទៀត?)
៣៣. តើបទពិសោធន៍មួយនៅក្នុងជីវិតរបស់លោកអ្នកដែលបានផ្លាស់ប្តូរប្រព័ន្ធឲ្យតម្លៃរបស់លោកអ្នកគឺជាអ្វី?
៣៤. តើគោលដៅមួយចំនួនរបស់លោកអ្នកសម្រាប់ឆ្នាំខាងមុខមានអ្វីខ្លះ?
៣៥. តើឪពុកម្តាយរបស់លោកអ្នកគឺជានរណា តើពួកគេធ្វើអ្វី ហើយលោកអ្នកគោរពអ្វីជាងគេបំផុតអំពីពួកគេ?
៣៦. ប្រសិនបើលោកអ្នកអាចជ្រើសរើសការងារម្តងទៀតបាន តើលោកអ្នកនឹងធ្វើអ្វី?
៣៧. ប្រសិនបើលោកអ្នកអាចក្លាយជាអ្នកដឹកនាំប្រទេសណាក៏បាននៅក្នុងពិភពលោក តើនឹងជាប្រទេសមួយណា ហើយហេតុអ្វី?
៣៨. តើបទពិសោធន៍ល្អបំផុត និងអាក្រក់បំផុតកាលពីសប្តាហ៍មុននេះ មានអ្វីខ្លះ?
៣៩. ប្រសិនបើលោកអ្នកអាចធ្វើដំណើរកម្សាន្តពីរសប្តាហ៍ដោយអត់អស់លុយទៅកន្លែងណាក៏បាននៅក្នុងពិភពលោកនេះ តើលោកអ្នកនឹងទៅកន្លែងណា ហើយហេតុអ្វី?
៤០. ប្រសិនបើលោកអ្នកអាចនិយាយជាមួយមនុស្សណាម្នាក់ក៏បានអំពីការរស់នៅ តើអ្នកនោះនឹងជានរណា ហើយហេតុអ្វី?
៤១. ចូរឲ្យគ្រប់គ្នាក្រដាសមួយសន្លឹក ហើយសុំឲ្យពួកគេគូររូបភាពអំពីការងាររបស់ពួកគេ ឬអ្វីដែលពួកគេចង់ធ្វើជាប្រចាំថ្ងៃ។ ចូរពន្យល់ប្រាប់អំពីរូបភាពរបស់លោកអ្នក។
៤២. ហេតុអ្វីបានជាលោកអ្នករីករាយចូលរួមនៅក្នុងក្រុមតូចយប់នេះ?
៤៣. ចូរប្រាប់គ្រប់គ្នាថា ពួកគេទើបតែបានទទួលលុយមួយលានដុល្លា។ ចូរឲ្យម្នាក់ៗចែកចាយអំពីរបៀបដែលពួកគេនឹងប្រើទ្រព្យដែលពួកគេទើបតែទទួលបាននេះ។
៤៤. តើលោកអ្នកមានឈ្មោះហៅក្រៅដែរឬទេ ហើយប្រសិនបើមាន តើឈ្មោះអ្វី? តើលោកអ្នកមានឈ្មោះហៅក្រៅអ្វីខ្លះសម្រាប់ប្តី ប្រពន្ធ កូន ឬបងប្អូនបង្កើតរបស់លោកអ្នក?
៤៥. តើមានគ្រាផ្សេងនៅក្នុងប្រវត្តិសាស្ត្រដែលលោកអ្នកចង់រស់នៅដែរឬទេ? ប្រសិនបើមាន ហេតុអ្វី?
៤៦. តើក្រុមតូចនេះបានជាជំនួយដល់លោកអ្នកយ៉ាងដូចម្តេច? ចូរចែកចាយ និងអរគុណគ្នាទៅវិញទៅមក។
៤៧. ចូរប្រាប់ក្រុមតូចការបីយ៉ាងដែលលោកអ្នកសរសើរអំពីគ្រួសាររបស់លោកអ្នក និងរបៀបបីយ៉ាងដែលលោកអ្នកគិតថាជាច្រើនដងពួកគេពិបាក។
៤៨. តើការមួយដែលលោកអ្នកពិតជាចង់ឃើញកើតឡើងនៅក្នុងគ្រួសាររបស់លោកអ្នកនៅពេលឥឡូវនេះគឺជាអ្វី? ក្រុមជំនុំរបស់លោកអ្នក? ក្រុមតូចរបស់លោកអ្នក? ពិភពលោក?
៤៩. តើមិត្តភក្តិដ៏ល្អបំផុតដែលលោកអ្នកមាននៅពេលនេះនៅក្នុងជីវិតរបស់លោកអ្នកគឺជានរណា?
៥០. តើលោកអ្នកទទួលបានការឆ្លើយតបសម្រាប់ការអធិស្ឋាននៅពេលថ្មីៗនេះដែរឬទេ? ចូរចែកចាយរឿងនោះ។
៥១. តើលោកអ្នកមានមុខរបរជាអ្វី? តើលោកអ្នកចូលចិត្តអ្វីអំពីមុខរបរនោះ?
៥២. តើនរណាជាអ្នកមានឥទ្ធិពលធំជាងគេបំផុតមកលើជីវិតគ្រិស្តបរិស័ទរបស់លោកអ្នក ហើយហេតុអ្វី?
៥៣. តើសៀវភៅ ខ្សែភាពយន្ត ឬវីដេអូអ្វីដែលលោកអ្នកបានមើល / អាន ហើយចង់ណែនាំប្រាប់អ្នកដទៃទៀត? ហេតុអ្វី?
៥៤. តើលោកអ្នកគិតថា អ្វីធ្វើឲ្យព្រះជាម្ចាស់សព្វព្រះហឫទ័យលើសជាងអ្វីផ្សេងទៀតនៅក្នុងជីវិតរបស់លោកអ្នក?

៥៥. តើពាក្យដ៏លើកទឹកចិត្តបំផុតដែលបាននិយាយមកកាន់លោកអ្នកនៅសប្ដាហ៍នេះគឺជាអ្វី?
៥៦. តើលោកអ្នកបានធ្វើកិច្ចការអ្វីដែលបានលើកទឹកចិត្តដល់អ្នកដទៃទៀតនៅសប្ដាហ៍នេះ?
៥៧. តើអ្វីដែលបានធ្វើឲ្យលោកអ្នកសម្រេចចិត្តចូលរួមនៅក្នុងក្រុមជំនុំនេះ?
៥៨. តើលោកអ្នកនៅតែចង់សម្រេចអ្វីជាមួយនឹងជីវិតរបស់លោកអ្នក?
៥៩. តើលោកអ្នកអរព្រះគុណព្រះសម្រាប់អ្វី?
៦០. តើព្រឹត្តិការណ៍ដ៏ចងចាំបំផុតនៅក្នុងជីវិតរបស់លោកអ្នកគឺជាអ្វី ហើយហេតុអ្វី?
៦១. ចូរចែកចាយអំពីបទគម្ពីរដែលមានន័យខ្លាំងបំផុតចំពោះលោកអ្នក និងមូលហេតុដែលបទគម្ពីរនោះមានន័យយ៉ាងខ្លាំង។
៦២. តើជីវិតរបស់លោកអ្នកនឹងខុសប្លែកយ៉ាងដូចម្ដេច ប្រសិនបើលោកអ្នកដឹងថា ព្រះយេស៊ូនឹងយាងត្រលប់មកវិញនៅក្នុងរយៈពេលមួយសប្ដាហ៍ទៀត?
៦៣. តើមនុស្សដ៏គួរឲ្យចាប់អារម្មណ៍បំផុតដែលលោកអ្នកបានជួបគឺជានរណា?
៦៤. តើកន្លែងឈប់សម្រាកដែលលោកអ្នកចូលចិត្តបំផុតគឺជាអ្វី ហើយហេតុអ្វីបានជាលោកអ្នកចូលចិត្តកន្លែងនោះ?
៦៥. ចូរចែកចាយអំពីបទពិសោធន៍ខាងវិញ្ញាណដែលលោកអ្នកមាន។
៦៦. តើលោកអ្នកសម្រាកយ៉ាងដូចម្ដេច?
៦៧. តើលោកអ្នកចូលចិត្តតន្ត្រី / ចម្រៀង។ល។ ប្រភេទអ្វីជាងគេ?
៦៨. តើមានអ្វីដែលបានកើតឡើងចំពោះលោកអ្នកនៅក្នុងសប្ដាហ៍នេះ ដែលលោកអ្នកចង់ប្រាប់អ្នកដទៃទៀតនៅក្នុងក្រុម?
៦៩. ប្រសិនបើលោកអ្នកមិនអាចបរាជ័យបាន តើលោកអ្នកនឹងធ្វើអ្វី?
៧០. ប្រសិនបើលោកអ្នកត្រូវរស់នៅម្ដងទៀត តើលោកអ្នកនឹងផ្លាស់ប្ដូរអ្វី?
៧១. តើលោកអ្នកចង់ឲ្យគេសរសេរអ្វីនៅលើថ្មផ្នូររបស់លោកអ្នក?
៧២. តើលោកអ្នកចង់ឲ្យគេនិយាយអ្វីនៅឯពិធីបុណ្យសពរបស់លោកអ្នក?
៧៣. ប្រសិនបើលោកអ្នកត្រូវទៅរស់នៅឋានព្រះច័ន្ទ ហើយអាចយកបានរបស់តែមួយគត់ តើលោកអ្នកនឹងយករបស់អ្វី?
៧៤. តើលោកអ្នកនឹងធ្វើយ៉ាងដូចម្ដេច ប្រសិនបើលោកអ្នកឃើញ (១) មនុស្សត្រូវចោរប្លន់ (២) មនុស្សលង់ទឹក និង (៣) ភ្លើងឆេះផ្ទះ?
៧៥. តើការមួយដែលលោកអ្នកមិនយល់អំពីមនុស្សប្រុស (ប្រសិនបើលោកអ្នកជាមនុស្សស្រី) ឬអំពីមនុស្សស្រី (ប្រសិនបើលោកអ្នកជាមនុស្សប្រុស) គឺជាអ្វី?
៧៦. ប្រសិនបើលោកអ្នកមានពេលសប្ដាហ៍នេះដើម្បីធ្វើម្ដងទៀត តើលោកអ្នកនឹងធ្វើអ្វីផ្សេងពីមុន?
៧៧. ចូរពណ៌នាអំពីក្រុមតូចមួយផ្សេងទៀតដែលលោកអ្នកធ្លាប់ជាសមាជិក ខាងក្រៅក្រុមជំនុំរបស់លោកអ្នក។ ហេតុអ្វីបានជាលោកអ្នកគិតថា ក្រុមនេះជោគជ័យ (ឬមិនជោគជ័យ)? លោកអ្នកមិនត្រូវបានដាក់កំហិតឲ្យនៅក្នុងក្រុមសាសនាណាមួយទេ។ ពួកយើងភាគច្រើនជួបជុំជាក្រុមតូចនៅកន្លែងធ្វើការ?
៧៨. តើបទគម្ពីរដ៏ចងចាំបំផុតដែលលោកអ្នកបានទទួលគឺជាបទគម្ពីរអ្វី (ឧទាហរណ៍ នៅឯពិធីជ្រមុជទឹក ពិធីអាពាហ៍ពិពាហ៍ ពេលប្រែចិត្តជឿ។ល។)? ចូរប្រាប់អំពីមូលហេតុដែលបទគម្ពីរមានន័យចំពោះលោកអ្នក។
៧៩. តើការដំបូងគេដែលលេចឡើងនៅក្នុងគំនិត ពេលដែលលោកអ្នកគិតអំពីព្រះ គឺជាអ្វី?
៨០. តើសំណួរធំៗបំផុតដែលលោកអ្នកមានអំពីទំនាក់ទំនងរបស់លោកអ្នកជាមួយព្រះ មានអ្វីខ្លះ?

គំរូសកម្មភាពសម្រាប់ការជួបប្រជុំក្រុមតូច

ខាងក្រោមនេះគឺជាគំរូសកម្មភាពមួយចំនួនសម្រាប់ផ្នែកនីមួយៗនៃផ្នែកទាំងបួនរបស់ការជួបប្រជុំក្រុមតូច។ ពេលវេលាដែលត្រូវបានកំណត់ត្រាសម្រាប់គូនាទីនីមួយៗគឺប្រហាក់ប្រហែលនេះ:

| ការប្រកប | ការថ្វាយបង្គំ | ការស្អាង | ការផ្សាយដំណឹងល្អ |
|---|---|---|---|
| មនុស្សទៅមនុស្ស | មនុស្សទៅព្រះ | ព្រះទៅមនុស្ស | រូបកាយរបស់ព្រះគ្រិស្ត ទៅពិភពលោក |
| «ទៅក្នុង» | «ទៅលើ» | «ទៅក្រោម» | «ទៅក្រៅ» |
| ២០ នាទី | ២០ នាទី | ៣០ នាទី | ២០ នាទី |
| • លេងល្បែងកម្សាន្តជាមួយគ្នា<br>• បរិភោគអាហារជាមួយគ្នា<br>• ស្គាល់គ្នាកាន់តែច្បាស់<br>• លើកទឹកចិត្តគ្នាទៅវិញទៅមក<br>• ចែកចាយរឿងអំណរប្រាប់គ្នា<br>• ចែកចាយបញ្ហាប្រាប់គ្នា<br>• អធិស្ឋានឲ្យគ្នា | • ច្រៀងចម្រៀងសរសើរតម្កើងព្រះ<br>• អរគុណព្រះសម្រាប់ភាពធំឧត្តមរបស់ព្រះអង្គ<br>• អរគុណព្រះសម្រាប់អ្វីដែលព្រះអង្គបានធ្វើ<br>• អធិស្ឋានឮ ឬស្ងាត់<br>• អានបទគម្ពីរថ្វាយបង្គំ (ឧទាហរណ៍ ទំនុកតម្កើង)<br>• អានកំណាព្យគ្រិស្តបរិស័ទ | • សិក្សាបទគម្ពីរជាក្រុម<br>• អនុវត្តសេចក្ដីពិតក្នុងព្រះគម្ពីរទៅក្នុងស្ថានភាពប្រចាំថ្ងៃ<br>• ចូលរួមនៅក្នុងពិន្ទុកិច្ចជាមួយក្រុម<br>• រកឃើញ និងប្រើអំណោយទានខាងវិញ្ញាណ<br>• ទន្ទេញខគម្ពីរ | • បង្កើត«ក្រុមអធិស្ឋានដែលមានបីនាក់» ហើយអធិស្ឋានសម្រាប់មិត្តភក្តិដែលមិនទាន់បានសង្គ្រោះ<br>• អញ្ជើញអ្នកមិនជឿឲ្យចូលរួមក្រុម<br>• ជាក្រុម ចូរបំពេញសេចក្ដីត្រូវការរបស់មនុស្សដែលនៅជុំវិញលោកអ្នក<br>• បង្កើតមិត្តជាមួយអ្នកមិនជឿ<br>• ចែកចាយដំណឹងល្អអំពីព្រះគ្រិស្តជាមួយអ្នកដទៃទៀត |

អាហារថ្ងៃត្រង់ (៦០ នាទី)

## ម៉ោងទី ៤
## ការសង្កេតមើលព្រះបន្ទូលរបស់ព្រះ ដោយប្រើការសិក្សាព្រះគម្ពីរបែប វិសេសានុមាន (៦០ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរចាប់ផ្ដើមជាមួយនឹងការរំឭកឡើងវិញអំពីវិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសានុមាន។ ចូរសួរក្រុមថា: «តើសកម្មភាពទាំងបីរបស់ការសិក្សាព្រះគម្ពីរបែបវិសេសានុមាន មានអ្វីខ្លះ? តើសំណួរពាក់ព័ន្ធនឹងសកម្មភាពនីមួយៗមានអ្វីខ្លះ?»។ សិក្ខាកាមគួរតែឆ្លើយដូចខាងក្រោម:

ក. ការសង្កេតមើល – តើបទគម្ពីរប្រាប់នេះប្រាប់អំពីអ្វី?
ខ. ការបកស្រាយ – តើបទគម្ពីរនេះចង់មានន័យយ៉ាងដូចម្ដេច?
គ. ការអនុវត្តន៍ – តើខ្ញុំគួរតែធ្វើអ្វី?

ចូរនិយាយថា៖ «នៅក្នុងម៉ោងនេះ យើងនឹងរៀនថែមទៀតអំពីសកម្មភាពទីមួយ: ការសង្កេតមើល»។

ការសង្កេតមើល – តើអត្ថបទគម្ពីរនិយាយអំពីអ្វី? (២០ នាទី)
ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរដឹកនាំសិក្ខាកាមបំពេញឲ្យត្រូវតាមកន្លែងនៅក្នុងសៀវភៅលំហាត់ និងដឹកនាំការពិភាក្សាខ្លីអំពីសំណួរដែលបានផ្ដល់ឲ្យសម្រាប់ប្រធានបទនីមួយៗ។

ក. ត្រៀមសង្កេតមើលដោយប្រុងប្រយ័ត្នពីអ្វីដែលអត្ថបទគម្ពីរកំពុងប្រាប់។
- តើព្រះវិញ្ញាណបរិសុទ្ធមានតួនាទីអ្វី? ១ កូរិនថូស ២:១៤
- តើការអធិស្ឋានមានតួនាទីអ្វី? អេភេសូរ ១:១៨
- តើការត្រៀមខ្លួនរួចរាល់ដើម្បីស្ដាប់បង្គាប់មានតួនាទីអ្វី? យ៉ាកុប ១:២២-២៥
- តើការពិនិត្យមើលខ្លួនឯងដោយឆ្លុះបញ្ចាំងនឹងបទគម្ពីរដែលបានសិក្សាមានតួនាទីអ្វី? ២ កូរិន ១៣:៥
- តើការមានឆន្ទៈព្រមរៀនមានតួនាទីអ្វី? កិច្ចការ ១៧:១១

ខ. ចំណាយពេលវេលាគ្រប់គ្រាន់
- តើពេលវេលាប៉ុន្មានទើបគ្រប់គ្រាន់?
- តើពេលដ៏ល្អបំផុតសម្រាប់លោកអ្នកសិក្សាព្រះបន្ទូលព្រះដោយគ្មានការរំខានគឺនៅពេលណា?
- តើកន្លែងដ៏ល្អបំផុតសម្រាប់លោកអ្នកមានពេលសិក្សាព្រះបន្ទូលព្រះដោយគ្មានការរំខានគឺនៅកន្លែងណា?

គ. មើលអត្ថបទក្នុងព្រះគម្ពីរ (ស្ថានភាពរបស់បទគម្ពីរ)
ចូរពិនិត្យមើលចំណុចខាងក្រោម:
- តើខគម្ពីរដែលនៅខាងមុខ និងខាងក្រោយនិយាយអំពីអ្វី?
- តើកថាខណ្ឌនោះមានប្រធានបទអ្វី?

ការសង្កេត[illegible]អនុវត្តន៍ – ត្រៀម – ពេលវេលា – អត្ថបទក្នុងព្រះគម្ពីរ
- តើ[illegible]?
- តើកណ្ឌគម្ពីរនោះមានប្រធានបទ និងគោលបំណងអ្វី?

ឃ. ចូរពិនិត្យមើលរចនាសម្ព័ន្ធអត្ថបទគម្ពីរ
- តើអត្ថបទគម្ពីរជាប្រភេទអក្សរសាស្ត្រអ្វី?
- តើមានពាក្យគន្លឹះអ្វីខ្លះ?
- តើមានអ្វីប្រៀបប្រដូចគ្នា តើមានអ្វីប្រៀបធៀបគ្នា? តើគំនិតអភិវឌ្ឍឡើងយ៉ាងដូចម្ដេច នៅពេលដែលលោកអ្នកអានអត្ថបទគម្ពីរ?
- តើមានកិរិយាស័ព្ទអ្វីខ្លះ? (ពាក្យដែលប្រាប់សកម្មភាព)
- តើមានឈ្នាប់អ្វីខ្លះ និងស្ថិតនៅកន្លែងណា? (ពាក្យទាំងនោះបង្ហាញប្រាប់ការផ្លាស់ប្ដូរពីប្រធានបទមួយទៅ ប្រធានបទមួយទៀត)

- តើមានរូបភាពពន្យល់អ្វីខ្លះ?

ង. ចូរសួរសំណួរស៊ើបអង្កេតអំពីអត្ថបទគម្ពីរ
ចូរសួរសំណួរអំពីអត្ថបទគម្ពីរដែលអ្នកសារព័ត៌មាននឹងសួរសាក្សីផ្ទាល់ភ្នែកអំពីព្រឹត្តិការណ៍មួយៈ

- នរណា?
- អ្វី?
- កន្លែងណា?
- នៅពេលណា?
- យ៉ាងដូចម្តេច?
- ហេតុអ្វី?

ការសម្តែងបង្ហាញពីការសិក្សាព្រះគម្ពីរបែបវិសេសានុមាន – ការសង្កេតមើល (៤០ នាទី)
ការណែនាំសម្រាប់អ្នកសម្របសម្រួលៈ ចូរដឹកនាំសិក្ខាកាមជាក្រុមមួយទាំងមូលសិក្សាយេរេមា ១:៤-១០ ដោយប្រើគោលការណ៍សង្កេតមើលខាងលើ។ ចូរអធិស្ឋាន មុនពេលដែលលោកអ្នកចាប់ផ្តើម។ បន្ទាប់មក អានអត្ថបទគម្ពីរជាមួយគ្នា ហើយនិយាយអំពីបរិបទ និងរចនាសម្ព័ន្ធរបស់អត្ថបទគម្ពីរនោះ។ បន្ទាប់មក ដឹកនាំក្រុមឆ្លើយសំណួរខាងក្រោមនៅក្នុងផ្នែកដែលដាក់ថា «គំរូការសង្កេតមើល»។ ចូរបន្តធ្វើការសង្កេតមើលរយៈពេល ៣០ នាទី។ បន្ទាប់មក ថ្នាក់ទាំងមូលពិភាក្សាអំពីលទ្ធផលរបស់ការពិភាក្សាគ្នា។

សំណួរស៊ើបអង្កេតៈ

នរណា?
រចនាសម្ព័ន្ធសំណួរស៊ើបអង្កេត

- តើនរណាជាអ្នកនិពន្ធបំណែកបទគម្ពីរនេះ (ខ ១)?
- តើនរណាខ្លះត្រូវបានលើកឡើងនៅក្នុងបទគម្ពីរនេះ (ខ ៥)?
- តើនរណាកំពុងនិយាយនៅក្នុងខ ៥?
- តើនរណាខ្លះដែលត្រូវបានលើកឡើងនៅក្នុងបរិបទរបស់បទគម្ពីរនេះ (ខ ១-៣)?
- សំណួរដទៃទៀតដែលចាប់ផ្តើមជាមួយនឹងពាក្យ «នរណា»?

អ្វី?

- តើព្រឹត្តិការណ៍គន្លឹះនៅក្នុងបរិបទរបស់បទគម្ពីរនេះមានអ្វីខ្លះ?
- តើ«ព្រះបន្ទូលរបស់ព្រះយេហូវ៉ា»ដែលបានមកដល់លោកយេរេមាប្រាប់ថាដូចម្តេចខ្លះ (ខ ៥)?
- តើសកម្មភាពជាក់លាក់បួនដែលព្រះជាម្ចាស់បានមានបន្ទូលថាព្រះអង្គបានធ្វើនៅក្នុងខ ៥ មានអ្វីខ្លះ?
- នៅក្នុងខ ៥ តើតួនាទីរបស់លោកយេរេមាត្រូវជាអ្វី?
- តើតួនាទីរបស់លោកយេរេមាមានដែនកំណត់យ៉ាងដូចម្តេច ស្របទៅតាមខ ៥? សម្រាប់តែសាសន៍អ៊ីស្រាអែល ឬសាសន៍ដទៃទៀតច្រើនជាងនេះ?
- តើលោកយេរេមាឆ្លើយតបយ៉ាងដូចម្តេចនៅក្នុងខ ៦?
- តើព្រះជាម្ចាស់ឆ្លើយតបយ៉ាងដូចម្តេចមកលោកយេរេមានៅក្នុងខ ៧-៩?
- តើលោកយេរេមាមានជម្រើសអ្វីខ្លះ ស្របទៅតាមខ ៧?
- តើលោកយេរេមាមានអារម្មណ៍យ៉ាងដូចម្តេច ដែលព្រះជាម្ចាស់ដោះស្រាយនៅក្នុងផ្នែកដំបូងនៃខ ៨?
- តើហេតុផលពីរដែលបានឲ្យដល់លោកយេរេមាដើម្បីកុំឲ្យខ្លាច មានអ្វីខ្លះ (ខ ៨)?
- តើព្រះអម្ចាស់ធ្វើអ្វីចំពោះលោកយេរេមានៅក្នុងខ ៩?
- ខ ១០ ពណ៌នាអំពីភារកិច្ចរបស់លោកយេរេមា។ តើភារកិច្ចនោះមានធាតុអ្វីខ្លះ?
- តើព្រឹត្តិការណ៍ដែលត្រូវបានលើកឡើងនៅក្នុងខ ១០ មានលំដាប់លំដោយយ៉ាងដូចម្តេច?
- តើព្រះជាម្ចាស់ធ្វើអ្វីនៅក្នុងខគម្ពីរដែលនៅក្រោយអត្ថបទគម្ពីរនេះ (ខ ១១-១៦, ១៧-១៩)?
- សំណួរដទៃទៀតដែលមានពាក្យ «យ៉ាងដូចម្តេច?» ឬ «អ្វីខ្លះ?»

កន្លែងណា?
- តើបរិបទយោងទៅរកកន្លែងណា (ខ ១)?
- តើកន្លែងទាំងនេះស្ថិតនៅកន្លែងណា?
- តើលោកយេរេមាប្រហែលជាស្ថិតនៅកន្លែងណា ពេលដែលលោកបានទទួលការត្រាស់ហៅនេះមកពីព្រះអម្ចាស់ (ខ ១)?
- សំណួរដទៃទៀតដែលមានពាក្យ «កន្លែងណា...?»

នៅពេលណា?
- តើគ្រាដែលបានពណ៌នាសម្រាប់បរិបទទាំងមូលរបស់កណ្ឌគម្ពីរនេះគឺនៅពេលណា?
- នៅក្នុងខ ៥ តើព្រះជាម្ចាស់ស្គាល់ (ជ្រើសរើស) លោកយេរេមានៅពេលណា?
- នៅក្នុងខ ៥ តើព្រះជាម្ចាស់បានញែកលោកយេរេមាចេញសម្រាប់ព័ន្ធកិច្ចនៅពេលណា?
- សំណួរដទៃទៀតដែលមានពាក្យ «...នៅពេលណា?»

ហេតុអ្វី?
- ហេតុអ្វីបានជាព្រះជាម្ចាស់កំពុងត្រាស់ហៅលោកយេរេមា?
- ហេតុអ្វីបានជាការងាររបស់លោកយេរេមាជាហោរាមានសារៈសំខាន់?

យ៉ាងដូចម្ដេច?
- តើលោកយេរេមាត្រូវបានពណ៌នានៅក្នុងខ ១ យ៉ាងដូចម្ដេច?
- តើលោកហ៊ិគីយ៉ា ជាឪពុករបស់លោក ត្រូវបានពណ៌នាយ៉ាងដូចម្ដេចនៅក្នុងខ ៦?
- តើលោកយេរេមាឆ្លើយតបចំពោះព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងខ ៦ យ៉ាងដូចម្ដេច?
- តើព្រះជាម្ចាស់ពណ៌នាអំពីលោកយេរេមានៅក្នុងខ ១៨ យ៉ាងដូចម្ដេច?

## ផែនការសកម្មភាពសម្រាប់ម៉ូឌុល ៣: ការសិក្សាព្រះគម្ពីរបែបវិសេសានុមាន - ការសង្កេតមើល

ប្រសិនបើលោកអ្នកមិនមានពេលធ្វើលំហាត់ការសង្កេតមើល យេរេមា ១:៤-១០ ចប់ទេ សូមធ្វើឲ្យចប់មុនមេរៀនក្រោយទៀត។ ចូរមើលថាតើលោកអ្នកអាចសួរសំណួរដ៏មានប្រយោជន៍ដទៃទៀតអំពីបទគម្ពីរតែមួយនេះដែរឬយ៉ាងណា។ ចូររក្សាទុកសំណួរ និងចម្លើយទាំងនេះសម្រាប់ប្រើនៅក្នុងមេរៀនក្រោយទៀត។

## ម៉ោងទី ៥
## របៀបបំផុសការអធិស្ឋានសម្រាប់ក្រុមជំនុំដែលលោកអ្នកបានដាំ (៦០ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ប្រសិនបើផ្ទាំងក្រដាស ឬក្តារខៀនធំ ចូរសរសេរបទគម្ពីរនីមួយៗពីបញ្ជីខាងក្រោមនៅលើក្រដាសមួយសន្លឹករៀងៗខ្លួន។ ចូរបិតសន្លឹកក្រដាសទាំងនោះលើជញ្ជាំងជុំវិញបន្ទប់។ ចូរបែងចែកក្រុមសិក្ខាកាមឲ្យអានបទគម្ពីរនីមួយៗ។ ចូរឲ្យពួកគេទៅឯសន្លឹកក្រដាសរៀងៗខ្លួនអានបទគម្ពីរ ហើយសរសេរហេតុផលដែលពួកគេគិតថា ការអធិស្ឋានសំខាន់ចំពោះការផ្សាយដំណឹងល្អ និងការដាំក្រុមជំនុំនៅសន្លឹកក្រដាសនោះ។ ទុកពេលឲ្យ ៥ នាទីសម្រាប់អាន និងសរសេរ។ បន្ទាប់មកទុកពេលឲ្យក្រុមនីមួយៗ ១ នាទី ដើម្បីរាយការណ៍គំឃើញរបស់ពួកគេប្រាប់អ្នកដទៃទៀត។

ការអធិស្ឋាន: ផ្នែកដ៏សំខាន់របស់ការផ្សាយដំណឹងល្អ និងការដាំក្រុមជំនុំ (១០ នាទី)

ដោយប្រើបទគម្ពីរខាងក្រោម ចូររកឲ្យឃើញ និងពិភាក្សាអំពីហេតុផលនៅក្នុងព្រះគម្ពីរដែលការអធិស្ឋានសំខាន់ចំពោះការផ្សាយដំណឹងល្អ និងការដាំក្រុមជំនុំ។

រ៉ូម ១០:១
អេភេសូរ ៦:១៨
អេភេសូរ ៦:១៩-២០
កូល៉ុស ៤:១-៤
២ ថែស្សាឡូនីច ៣:១-៣

របៀបដាក់បញ្ចូលការអធិស្ឋានជាមួយការផ្សាយដំណឹងល្អ និងការដាំក្រុមជំនុំ (៥ នាទី)

ចូរនិយាយថា៖ «តើមានវិធីអ្វីខ្លះដែលលោកអ្នកអាចឲ្យអ្នកជឿចូលរួមបាននៅក្នុងការអធិស្ឋានសម្រាប់ចលនាដាំក្រុមជំនុំរបស់លោកអ្នក?»

១. នៅក្នុងក្រុមតូច
២. ការអធិស្ឋានត្រីគុណ - អ្នកជឿបីនាក់អធិស្ឋានជាមួយគ្នា
៣. ការដើរអធិស្ឋាន - ដើរនៅជុំវិញតំបន់ដែលលោកអ្នកមានផែនការដាំក្រុមជំនុំ ដោយឈប់អធិស្ឋានស្ងៀមស្ងាត់នៅកន្លែងផ្សេងៗ។

ការពិភាក្សាអំពីការដើរអធិស្ឋាន (១៥ នាទី)
ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរអានករណីពីរខាងក្រោមជាក្រុមធំ ហើយពិភាក្សាសំណួរដែល
ក្រុមតូចនៅខាង [illegible] ការដើរអធិស្ឋាន

ករណីសិក្សាទី ១:
សហគមន៍មួយដែលល្បីថាមានបញ្ហាជាច្រើនត្រូវបានគេកំណត់យកជាគោលដៅសម្រាប់ដាំក្រុមជំនុំ។ បញ្ហាសង្គម ដូចជាការអត់មានការងារធ្វើ ការបែកបាក់គ្រួសារ ការញៀនថ្នាំ និងបទឧក្រិដ្ឋ គឺជាបញ្ហាទូទៅ។ នៅក្នុងការខិតខំប្រឹងប្រែងដាំក្រុមជំនុំដំណាក់កាលដំបូង គេបានរៀបចំផែនការដើរអធិស្ឋាននៅគ្រប់ផ្លូវទាំងអស់ក្នុងសហគមន៍។ នៅពេលដែលគ្រិស្តបរិស័ទដើរអធិស្ឋាន ពួកគេបានកត់ត្រាការបើកសម្តែងដែលព្រះវិញ្ញាណបរិសុទ្ធបានប្រទានឲ្យពួកគេ។ ក្រោយនោះមក ក៏មានការដើរអធិស្ឋានជាច្រើនទៀត។ ការដើរអធិស្ឋានខ្លះកើតឡើងនៅជុំវិញសាលារៀន ខ្លះទៀតនៅក្នុង និងនៅជុំវិញតំបន់លក់ដូរ ហើយខ្លះទៀតនោះនៅជុំវិញព្រំប្រទល់សហគមន៍។ ការដើរអធិស្ឋានមួយបានកើតឡើងនៅក្នុងព្រៃដែលមើលទៅឃើញសហគមន៍ពីលើ។ នៅក្នុងព្រៃដែលត្រូវបានគេស្គាល់ថាជាកន្លែងដោះដូរថ្នាំញៀន គេក៏បានរកឃើញនិមិត្តសញ្ញាមន្តអាគមនៅតាមដើមឈើផងដែរ។ ក្រុមដើរអធិស្ឋានបានចំណាយពេលអធិស្ឋានទាស់នឹងឥទ្ធិពលអាក្រក់ទាំងនេះ។ នៅក្នុងរយៈពេលបីឆ្នាំចាប់តាំងពីពេលដែលសហគមន៍នេះត្រូវបានគេកំណត់យកជាគោលដៅសម្រាប់ការដាំក្រុមជំនុំ បញ្ហាសង្គមបានថយចុះ បទឧក្រិដ្ឋបានថយចុះ ៤០% ហើយក្រុមជំនុំមួយដែលមនុស្ស ៧០-៨០ ត្រូវបានដាំ។ ឥឡូវនេះ មានឥទ្ធិពលវិជ្ជមានខាង

វិញ្ញាណ ដើម្បីតយុទ្ធនឹងសេចក្ដីអាក្រក់ ហើយព្រះជាម្ចាស់កំពុងតែធ្វើការនៅក្នុងជីវិតមនុស្សជាច្រើន[1] ។

- តើលោកអ្នកចង់ចែកចាយគំនិតអ្វីខ្លះ ជាការឆ្លើយតបទៅនឹងករណីសិក្សានេះ?
- តើផលប្រយោជន៍ដ៏ធំធេងបំផុតចេញពីការដើរអធិស្ឋានប្រភេទនេះ មានអ្វីខ្លះ?
- តើបញ្ហាប្រឈមដ៏ធំបំផុតគឺជាអ្វី?

ករណីសិក្សាទី ២:
អ្នកដាំក្រុមជំនុំម្នាក់ និងគ្រួសាររបស់គាត់បានរើទៅនៅក្នុងបូរីមួយក្នុងទីក្រុង ដែលពួកគេចង់ឃើញមានក្រុមជំនុំកើតឡើង។ ល្ងាចមួយ គ្រួសារនេះបានដើរនៅក្នុងបូរី។ ពួកគេបានឈរនៅមុខទ្វារផ្ទះនីមួយៗ ហើយសមាជិកគ្រួសារម្នាក់ៗអធិស្ឋានឲ្យមនុស្សនៅក្នុងផ្ទះនោះ។ កូនប្រុសអធិស្ឋានសុំឲ្យមនុស្សគ្រប់គ្នានៅក្នុងផ្ទះនោះទទួលយកព្រះយេស៊ូមកគង់នៅក្នុងចិត្តរបស់គេ។ កូនស្រីអធិស្ឋានសុំឲ្យសេចក្ដីត្រូវការផ្នែកហិរញ្ញវត្ថុរបស់គ្រួសារនោះត្រូវបានបំពេញ កូនស្រីម្នាក់ទៀតអធិស្ឋានសុំឲ្យមានទំនាក់ទំនងល្អនៅក្នុងគ្រួសារ។ ម្ដាយអធិស្ឋានសម្រាប់សុខភាពរបស់សមាជិកគ្រួសារ ហើយឪពុកអធិស្ឋានសុំព្រះជាម្ចាស់ប្រទានពរដល់គ្រួសារនោះ។ ក្រោយពីដើរអធិស្ឋានរួចហើយ អ្នកដាំក្រុមជំនុំនោះ និងគ្រួសាររបស់គាត់បានឃើញមនុស្ស ១៤ នាក់នៅក្នុងបូរីនោះបានស្គាល់ព្រះគ្រិស្ដ ហើយក្រុមជំនុំតូចមួយបានកើតឡើង។

- តើលោកអ្នកចង់ចែកចាយគំនិតអ្វីខ្លះ ជាការឆ្លើយតបទៅនឹងករណីសិក្សានេះ?
- តើផលប្រយោជន៍ដ៏ធំធេងបំផុតចេញពីការដើរអធិស្ឋានប្រភេទនេះ មានអ្វីខ្លះ?
- តើបញ្ហាប្រឈមដ៏ធំបំផុតគឺជាអ្វី?

ការណែនាំសម្រាប់អ្នកសម្របសម្រួល: សម្រាប់ប្រធានបទ «ក្រុមអធិស្ឋានគាំទ្រ» និង «ការប្រមូលព័ត៌មានសម្រាប់ការអធិស្ឋាន» ចូរប្រើសំណួរដែលបានផ្ដល់ឲ្យដើម្បីដឹកនាំការពិភាក្សាជាក្រុមធំអំពីប្រធានបទទាំងនេះ (២០ នាទី)។

ក្រុមអធិស្ឋានគាំទ្រ
- តើលោកអ្នកមានក្រុមមនុស្សដែលអធិស្ឋានសម្រាប់ព័ន្ធកិច្ចដាំក្រុមជំនុំរបស់លោកអ្នកដែរឬទេ? តើជួយលោកអ្នកប៉ុនណា? តើលោកអ្នកសុំក្រុមរបស់លោកអ្នកឲ្យអធិស្ឋានសម្រាប់អ្វី?
- តើមានវិធីអ្វីខ្លះដែលលោកអ្នកអាចឲ្យក្រុមអធិស្ឋានគាំទ្រដឹងអំពីតម្រូវការដែលត្រូវអធិស្ឋាន និងការឆ្លើយតបចំពោះការអធិស្ឋាន?
- តើលោកអ្នកគិតថា ព័ត៌មានប្រភេទណាខ្លះស័ក្ដិសមនឹងចែកចាយប្រាប់ក្រុមអធិស្ឋាន និងព័ត៌មានប្រភេទណាខ្លះដែលមិនគួរចែកចាយ?
- តើមានគំនិតដទៃទៀតអ្វីខ្លះ ដើម្បីជួយបង្កើនការអធិស្ឋានសម្រាប់ព័ន្ធកិច្ចដាំក្រុមជំនុំរបស់លោកអ្នក?

ការប្រមូលព័ត៌មានសម្រាប់ការអធិស្ឋាន
- តើព័ត៌មានប្រភេទអ្វីខ្លះអាចប្រមូលបាននៅក្នុងការស្រាវជ្រាវ ដែលនឹងមានប្រយោជន៍បំផុតសម្រាប់ការអធិស្ឋានឲ្យបុគ្គល ឬសហគមន៍?
- តើព័ត៌មានដូចជាក្រុមជំនុំនៅក្នុងតំបន់នោះ ក្រុមដែលមានចរិតសាសនា ក្រុមសាតាំង ការរីកចម្រើនឡើងរបស់ក្រុមជំនុំ និងការប្រួបរួមគ្នារបស់អ្នកជឿនឹងមានប្រយោជន៍សម្រាប់ការអធិស្ឋានរបស់លោកអ្នកដែរឬទេ? ចូរពន្យល់អំពីមូលហេតុ។

## ផែនការសកម្មភាពសម្រាប់ម៉ូឌុល ៣: ក្រុមអធិស្ឋានគាំទ្រ និងបទពិសោធន៍នៃការដើរអធិស្ឋាន

១. ប្រសិនបើលោកអ្នកមិនទាន់បានធ្វើនៅឡើយទេ ចូរបង្កើតក្រុមអធិស្ឋានគាំទ្ររបស់លោកអ្នក។ ចូរសុំយ៉ាងហោចណាស់អ្នកជឿបីនាក់ទៀតឲ្យអធិស្ឋានជារៀងរាល់សប្ដាហ៍សម្រាប់ព័ន្ធកិច្ចរបស់លោកអ្នក។ តើលោកអ្នកនឹងប្រាប់ឲ្យពួកគេដឹងសំណូមពរអធិស្ឋាន និងការឆ្លើយតបចំពោះការ

[1] DAWN Europa Prayer Manual, August 1994, pg. 13.

អធិស្ឋានយ៉ាងដូចម្ដេច?

២. ដើរអធិស្ឋានយ៉ាងហោចណាស់ឲ្យបានមួយដងក្នុងតំបន់គោលដៅរបស់លោកអ្នកជាមួយក្រុមដាំក្រុមជំនុំរបស់លោកអ្នក ឬអ្នកដទៃទៀតដែលមានបន្ទុកចង់មើលឃើញតំបន់នោះត្រូវបានឈោងចាប់ថ្វាយព្រះគ្រិស្ត។ ចូរពិភាក្សាអំពីបទពិសោធន៍នេះជាមួយគ្រូឧបជ្ឈា ឬគ្រូហ្វឹកហ្វឺនរបស់លោកអ្នក។

ការណែនាំសម្រាប់អ្នកសម្របសម្រួល: (១០ នាទី)

- ចូរអរគុណអ្នកដាំក្រុមជំនុំសម្រាប់ការងារដ៏ល្អរបស់ពួកគេ និងសម្រាប់ការចូលរួមនៅក្នុងការហ្វឹកហ្វឺននេះ។
- ណែនាំអំពីការប្រជុំអធិស្ឋាននៅពេលបញ្ចប់ម៉ោងសិក្សានេះ។ ចូរសម្រាកមួយភ្លែត ប្រសិនបើចាំបាច់ មុនពេលចាប់ផ្ដើមការប្រគំតន្ត្រីអធិស្ឋាន។

# ម៉ោងទី ៦
# ការប្រជុំអធិស្ឋាន: មកចូរយើងឱនកាយក្រាបថ្វាយបង្គំដោយផ្អែកលើទំនុកតម្កើង ៩៥ (៦០ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល:

- ការប្រគំតន្ត្រីអធិស្ឋានមិនមែនជាពេលសម្រាប់បង្រៀនទេ ប៉ុន្តែសម្រាប់នាំអ្នកដាំក្រុមជំនុំអធិស្ឋាន។ លោកអ្នកគួរតែអានទំនុកតម្កើង ៩៥ ទុកជាមុនដោយប្រុងប្រយ័ត្ន ហើយមើលរបៀបដែលជំពូកនេះបំបែកទៅជាផ្នែកៗ (មើលផ្នែកជាក់លាក់ពេលក្រោយទៀតនៅក្នុងមេរៀននេះ)។
- ពេលអធិស្ឋាន និងថ្វាយបង្គំនេះគួរតែផ្តល់ឱកាសឲ្យអ្នកដាំក្រុមជំនុំម្នាក់ៗគិតអំពីខ្លឹមសារមេរៀន ហើយបន្ទាបខ្លួនស្វែងរកការដឹកនាំរបស់ព្រះអំពីរបៀបដែលខ្លឹមសារមេរៀននេះគួរតែផ្លាស់ប្តូរជីវិត និងព័ន្ធកិច្ចរបស់គេ។
- ចូររៀបចំផែនការជាមុនអំពីរបៀបដែលលោកអ្នកនឹងបកស្រាយ រៀបចំ និងអនុវត្តទម្រង់ការប្រគំតន្ត្រី អធិស្ឋានដែលផ្តល់ជូននៅខាងក្រោម។
- ចូរឲ្យអ្នកដាំក្រុមជំនុំផ្សេងៗចូលរួមនៅក្នុងការអានបទគម្ពីរ ការនាំចម្រៀង ការអធិស្ឋាន និងការចែកចាយទីបន្ទាល់។
- ទុកពេលប្រហែល ២០ នាទីសម្រាប់ផ្នែកនីមួយៗរបស់ការប្រគំតន្ត្រីអធិស្ឋាន។

តើវិធានស្តីអំពីការអធិស្ឋានជាអ្វី?

ពាក្យ «វិធានស្តីអំពីការអធិស្ឋាន» មានមកតាំងពីដើមឆ្នាំ ១៧០០ ហើយត្រូវបានប្រើរៀងរហូតតមក ដើម្បីពណ៌នាអំពីចលនាអធិស្ឋានធំៗ មុនពេលដែលព្រះរាជ្យរបស់ព្រះគ្រិស្តមានការរីកចម្រើនថ្មីៗទៀតនៅក្នុងពិភពលោក។ នៅក្នុងសៀវភៅ *ជើងស្វាហាប់*បណ្ឌិត ជេ. អ៊ែឌវីន អ័រ សរសេរថា៖ «វិធានស្តីអំពីការអធិស្ឋានសម្រាប់ការផុសផុលនៅក្នុងឆ្នាំ ១៧៨០ នៅចក្រភពអង់គ្លេស និងនៅក្នុងឆ្នាំ ១៧៩០ នៅសហរដ្ឋអាមេរិក...ត្រូវបានបង្ហាញឲ្យឃើញយ៉ាងច្បាស់ថាជាកត្តាចម្បងនៅក្នុងការលើកទឹកចិត្ត និងការបំពាក់បំប៉នគ្រិស្តបរិស័ទ សម្រាប់ការបម្រើព័ន្ធកិច្ចនៅក្នុងចលនាទូទាំងពិភពលោក ដែលបានបំផ្លាញអំណាចយោធារបស់ប្រទេសនានាក្នុងចម្បាំងនៅវ៉ាតធើរលូ។ ដូចជានៅពាក់កណ្តាលទីមួយនៃសតវត្សនេះដែរ (ដើមឆ្នាំ ១៩៨០) គ្រប់ទាំងនិមិត្តរបស់បេសកជន (ចាប់តាំងពីឆ្នាំ ១៨៥៨ មក) ត្រូវបានចាប់ផ្តើមដោយមនុស្សដែលបានផុសផុលនៅក្នុងព្រឹត្តិការណ៍បំផុសរបស់ក្រុមជំនុំដែលបញ្ជូនបេសកជនឲ្យចេញទៅ»។

និយាយខាងឯប្រវត្តិសាស្ត្រ ការជួបប្រជុំទាំងនេះផ្តោតជាចម្បងលើរបៀបវារៈពីរ: (១) គ្រិស្តបរិស័ទអធិស្ឋានសុំឲ្យសេចក្តីពោរពេញរបស់ព្រះគ្រិស្តបង្ហាញចេញមកនៅក្នុងក្រុមជំនុំរបស់ព្រះអង្គ ដើម្បីប្រទានឲ្យពួកគេមានអំណាចសម្រេចភារកិច្ចដែលនៅចំពោះមុខពួកគេ (២) ពួកគេក៏បានអធិស្ឋានសុំការសម្រេចគោលបំណងជួយសង្គ្រោះរបស់ព្រះអង្គនៅក្នុងចំណោមជាតិសាសន៍នានា តាមរយៈក្រុមជំនុំដែលបានផុសផុល និងដែលបានញែកចេញ។ របៀបវារៈពីរយ៉ាងនេះនៅតែលេចធ្លោនៅសព្វថ្ងៃនេះ។

ដូច្នេះ «វិធានស្តីអំពីការអធិស្ឋាន» ជួយពណ៌នាអំពីគ្រិស្តបរិស័ទរួបរួមគ្នាដោយផ្អែកលើមូលដ្ឋានគ្រឹះទៀងទាត់ស្វែងរកសេចក្តីពោរពេញ និងការសម្រេច។ ការអធិស្ឋានរួមគ្នាដ៏អស្ចារ្យមិនត្រូវកំណត់ដោយគេអធិស្ឋានយូរប៉ុនណា ឬញឹកញាប់ប៉ុនណាទេ ផ្ទុយទៅវិញគឺគ្រិស្តបរិស័ទអធិស្ឋាន ពួកគេអធិស្ឋានសម្រាប់សេចក្តីដែលមាននៅក្នុងព្រះហឫទ័យរបស់ព្រះ ហើយពួកគេអធិស្ឋានបែបយ៉ាងដូច្នោះជាមួយគ្នា - «នៅក្នុងការប្រគំតន្ត្រី»[2] ។

នៅថ្ងៃនេះ «វិធានស្តីអំពីការអធិស្ឋាន»របស់យើង ផ្អែកលើទំនុកតម្កើង ៩៥។ ទំនុកនេះនាំយើងឆ្លងកាត់ជំហានទាំងបី ដូចដែលបានបង្ហាញនៅក្នុងក្រាហ្វិចខាងក្រោម:

---

[2] *The Traveling Team* (2012). "What is a 'Concert of Prayer?'" retrieved from http://www.thetravelingteam.org/ articles/concert-prayer.

| ទំនុកតម្កើង ៩៥ | |
|---|---|
| ១. ច្រៀងថ្វាយព្រះអម្ចាស់ | ខ. ១-៥ |
| ២. ក្រាបចុះនៅចំពោះព្រះអម្ចាស់ | ខ. ៦-៧ |
| ៣. ស្តាប់ព្រះអម្ចាស់ | ខ ៨-១១ |

# មក ចូរយើងឱនកាយក្រាបថ្វាយបង្គំ
# ការប្រគំតន្ត្រីអធិស្ឋាន
# ផ្អែកលើទំនុកតម្កើង ៩៥

១. អបអរព្រះអម្ចាស់: ចូរអានទំនុកតម្កើង ៩៥:១-៥

មកចុះ យើងនឹងច្រៀងថ្វាយព្រះយេហូវ៉ាដោយអំណរ

- **ច្រៀង**ចម្រៀងអរសប្បាយ
- **ឡើងសំឡេង**ដល់ថ្មដានៃសេចក្តីសង្គ្រោះរបស់យើង
- **អានជាមួយគ្នា**ដោយឮៗចេញពីទំនុកអំពីការប្រោសលោះ ទំនុកតម្កើង ១៨:១-៣, ៣០-៣៦
- **មក**នៅចំពោះព្រះយេហូវ៉ាដោយអរព្រះគុណ
- **មានពេលធ្វើទីបន្ទាល់** ជាពិសេសអរព្រះគុណព្រះជាម្ចាស់សម្រាប់អ្វីដែលព្រះអង្គកំពុងធ្វើនៅក្នុងការអធិស្ឋានត្រីគុណ និងផ្នែកដទៃទៀតរបស់ការដាំក្រុមជំនុំ
- **លើកតម្កើង**ព្រះអម្ចាស់ជាមួយតន្ត្រី ហើយនឹងចម្រៀង: មានពេលមួយផ្សេងទៀតច្រៀងសរសើរតម្កើងព្រះអម្ចាស់។
- **អានជាមួយគ្នា** ខ ៣-៥ នៅក្នុងទំនុកតម្កើង ៩៥
  **អរព្រះគុណព្រះអង្គ**សម្រាប់ការគ្រប់គ្រងដ៏ធំឧត្តមរបស់ព្រះអង្គលើចក្រវាឡ។

២. ថ្វាយបង្គំព្រះអម្ចាស់: ចូរអានទំនុកតម្កើង ៩៥:៦-៧

- **ឱនកាយ**...ថ្វាយបង្គំនៅចំពោះព្រះយេហូវ៉ា ជាព្រះដ៏បង្កើតយើង (ចូរអនុញ្ញាតឲ្យកាយវិការរបស់លោកអ្នកបង្ហាញចេញន័យអត្ថបទគម្ពីរ និងអារម្មណ៍នៅក្នុងទំនុកនេះ)។
- **លើកទឹកចិត្ត**សិស្សឲ្យបន្ទាបខ្លួនអធិស្ឋាន។ ប្រសិនបើពួកគេមានអារម្មណ៍ចង់លុតជង្គង់ លុតជង្គង់ចុះ។
- **ព្រះអង្គជាព្រះរបស់យើង...**យើងគឺជាប្រជារាស្ត្រនៅវាលស្មៅរបស់ព្រះអង្គ។
- **ទទួលស្គាល់ព្រះអង្គ**ជាអ្នកគង្វាលផ្ទាល់ខ្លួនរបស់លោកអ្នក។ ចូរសរសើរតម្កើងព្រះអង្គសម្រាប់ព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះអង្គចំពោះលោកអ្នក។
- **សុំព្រះអង្គ**ឲ្យបន្ទន់ចិត្តរបស់លោកអ្នក ដើម្បីឲ្យលោកអ្នកអាចស្តាប់ឮព្រះអង្គមានបន្ទូល។

៣. ស្តាប់ព្រះសូរសៀងរបស់ព្រះអង្គ: កុំឲ្យតាំងចិត្តរឹងរូស: ចូរអានទំនុកតម្កើង ៩៥:៨-១១

- ចូរលន់តួអំពើបាបណាមួយដែលដឹងថាមាននៅក្នុងជីវិតរបស់លោកអ្នក។ ចូរអាន ១ យ៉ូហាន ១:៩។
- ចូរចំណាយពេលស្តាប់ព្រះអម្ចាស់។ ចូរសុំព្រះអង្គឲ្យបង្ហាញប្រាប់លោកអ្នក ប្រសិនបើមានផ្នែកដែលលោកអ្នកត្រូវបោះចោលរបៀបចាស់ ទម្លាប់ចាស់ ឬវិធីសាស្ត្រដាំក្រុមជំនុំចាស់ដែលហាក់បីដូចជាលែងត្រូវសម្រាប់បរិបទរបស់លោកអ្នកទៀត ដោយព្រោះតែបទគម្ពីរដែលលោកអ្នកបានសិក្សានៅក្នុងមេរៀននេះ។ ចូរពិភាក្សាជាមួយព្រះអម្ចាស់អ្វីដែលព្រះអង្គចង់ឲ្យ

លោកអ្នកទុក និងអ្វីដែលព្រះអង្គចង់ឲ្យលោកអ្នកផ្លាស់ប្តូរនៅក្នុងជីវិត និងព័ន្ធកិច្ចរបស់លោកអ្នក។

- ចូរអានហេព្រើរ ៣:៧-១៩។ ខ ១៣ ប្រាប់ឲ្យលើកទឹកចិត្តគ្នាទៅវិញទៅមកជារៀងរាល់ថ្ងៃ។ ចូរចែកជាក្រុមដែលមានគ្នា ២ ឬ ៣ នាក់ ហើយអធិស្ឋានលើកទឹកចិត្តឲ្យគ្នាទៅវិញទៅមក។
- ចូរបញ្ចប់ជាមួយនឹងចម្រៀងមួយបទ និងអធិស្ឋានឲ្យពរដល់អ្នកដាំក្រុមជំនុំ។

# ការបញ្ចប់

តើបន្ទាប់ទៀតជាអ្វី?

ការណែនាំសម្រាប់អ្នកសម្របសម្រួល:

- ចូរសុំអ្នកស្ម័គ្រចិត្តឲ្យប្រាប់ចម្លើយរបស់ពួកគេសម្រាប់សំណួរខាងក្រោមតាមពាក្យរបស់ខ្លួន:
  ១. តើហេតុផលខាងទេវសាស្ត្របីសម្រាប់ការដាំក្រុមជំនុំមានអ្វីខ្លះ?
  ២. តើការធ្វើផែនទីខាងវិញ្ញាណគឺជាអ្វី ហើយហេតុអ្វីបានជាសំខាន់?
  ៣. តើកត្តាទាំងបួនរបស់ការជួបប្រជុំក្រុមតូចមានអ្វីខ្លះ និងមានលំដាប់លំដោយត្រឹមត្រូវយ៉ាងដូចម្តេច?
  ៤. នៅពេលដែលយើងប្រើបំណែកការសង្កេតមើលរបស់ការសិក្សាព្រះគម្ពីរបែបវិសេសានុមាន តើយើងកំពុងសង្កេតឃើញអ្វីខ្លះ?
  ៥. តើវិធីមួយចំនួនដែលលោកអ្នកអាចបំផុសការអធិស្ឋានសម្រាប់ការខិតខំប្រឹងប្រែងដាំក្រុមជំនុំរបស់លោកអ្នកមានអ្វីខ្លះ?
- ចូរសុំសិក្ខាកាមឲ្យចែកចាយសេចក្តីដែលពួកគេរៀនបាននៅក្នុងការហ្វឹកហ្វឺននេះ ដែលធ្វើឲ្យពួកគេរំភើបចិត្ត និងលើកទឹកចិត្តពួកគេសម្រាប់ការងាររបស់ពួកគេក្នុងនាមជាអ្នកដាំក្រុមជំនុំ។
- រំឭកឡើងវិញផែនការសកម្មភាពដែលត្រូវធ្វើជាការរៀបចំសម្រាប់ម៉ូឌុល ៣ ហើយឆ្លើយសំណួរណាមួយពាក់ព័ន្ធនឹងផែនការទាំងនោះ។
- ចូរឲ្យសិក្ខាកាមកំណត់គោលដៅសម្រាប់ខែនេះ។

មុនពេលដែលលោកអ្នកមករៀនម៉ូឌុលបន្ទាប់ទៀត យើងផ្តល់យោបល់ឲ្យលោកអ្នកធ្វើកិច្ចការខាងក្រោម:

- ➢ ចូរទាក់ទងមនុស្សថ្មីឲ្យបាន ១០ នាក់
- ➢ ចូរប្រាប់ដំណឹងល្អដល់មនុស្ស ៥ នាក់
- ➢ ចូរចាប់ផ្តើមក្រុមតូចថ្មីមួយ

ផែនការសកម្មភាពសម្រាប់ម៉ូឌុល # ៣: បញ្ជីត្រួតពិនិត្យ

- ➢ ចូរធ្វើផែនទីខាងវិញ្ញាណឲ្យបានចប់ (សូមមើលម៉ោងទី ១)
- ➢ ចូរអភិវឌ្ឍ និងចែកចាយទីបន្ទាល់របស់លោកអ្នកជាមួយអ្នកមិនជឿ ៥ នាក់ (សូមមើលម៉ោងទី ២)
- ➢ ប្រសិនបើលោកអ្នកមិនមានពេលសិក្សាព្រះគម្ពីរយេរេមា ១:៤-១០ តាមបែបវិសេសានុមានចប់ទេ សូមសិក្សាឲ្យបានចប់សម្រាប់ម៉ូឌុលក្រោយទៀត (សូមមើលម៉ោងទី ៤)
- ➢ ចូរកំណត់ក្រុមអធិស្ឋានគាំទ្ររបស់លោកអ្នក ហើយចេញទៅដើរអធិស្ឋាន (សូមមើលម៉ោងទី ៥)

| គោលដៅដាំក្រុមជំនុំសម្រាប់ខែនេះ | |
|---|---|
| បុគ្គល | |
| អ្នកថ្មីដែលបានទាក់ទង | ចំនួន |
| អ្នកជឿថ្មី | ចំនួន |
| អ្នកថ្មីដែលបានទទួលពិធីជ្រមុជទឹក | ចំនួន |
| អ្នកដឹកនាំថ្មីកំពុងទទួលការហ្វឹកហ្វឺន | ចំនួន |

| ក្រុមតូច | |
|---|---|
| ក្រុមតូចថ្មី | ចំនួន |
| អ្នកចូលរួមថ្មីនៅក្នុងក្រុម | ចំនួន |
| អ្នកដឹកនាំថ្មីដែលមានក្រុមតូចមួយ | ចំនួន |